ISSN 1560-7615

# ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី៨ លេខ ១ | មករា - មីនា ឆ្នាំ២០០៤ | តម្លៃ ១.៥០០៛

# ការវិវត្តន៍នៃការគ្រប់គ្រងទំនាស់ក្នុងរយៈពេលបោះឆ្នោត

**លោកស្រី Caroline Hughes ទីប្រឹក្សាខាងក្រៅរបស់ វិបសអ បានពិនិត្យពីការប្រែប្រួលក្នុងចរិតនៃទំនាស់ និងការគ្រប់គ្រងទំនាស់ក្នុងរយៈពេលបោះឆ្នោតនៅកម្ពុជា ។***

នៅប្រទេសកម្ពុជា មានការបោះឆ្នោតលើកទី៤ គិតតាំងពីឆ្នាំ១៩៩៣មក ឬការបោះឆ្នោតលើកទី៣ ដែលរៀបចំដោយស្ថាប័នរដ្ឋកម្ពុជា ។ ដើម្បីឆ្លើយតបនឹងការយកចិត្តទុកដាក់ចំពោះការសិក្សារបស់ វិបសអ ស្តីពីទំនាស់ក្នុងការបោះឆ្នោតជាទូទៅនៅឆ្នាំ១៩៩៨, មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានចាត់ចែងធ្វើការសិក្សាលើកទី២ដើម្បីផ្តល់ការវិភាគលើការវិវត្តន៍ពីមួយឆ្នាំទៅមួយឆ្នាំនៃយន្តការគ្រប់គ្រងទំនាស់ឆ្លងតាមការបោះឆ្នោតទាំង៣លើកចុងក្រោយ ។ ក្នុងការងារនេះ ក្រុមអ្នកស្រាវជ្រាវមានទិសដៅបី ។ ទី១ ការប្រៀបធៀបមើលពីចរិត និងមូលហេតុនៃការរីករាលដាលទំនាស់ និងភាពសក្តិសិទ្ធិនៃយន្តការនានាដែលបានប្រើប្រាស់ សំរាប់គ្រប់គ្រងទំនាស់ (ក្នុងឆ្នាំ១៩៩៨ និង ២០០៣) ដើម្បីកសាងគំរូមួយនៃការរីករាលដាលទំនាស់ ។ ទី២ ការពិនិត្យអង្កេតពីទំនាស់ និងការគ្រប់គ្រងទំនាស់នៅកំរិតមូលដ្ឋាន តាមរយៈការចុះសិក្សាដល់ទីកន្លែងឃុំមួយចំនួន ហើយនេះជាយុទ្ធសាស្ត្រស្រាវជ្រាវមួយដែលមិនបានអនុវត្តទេ ក្នុងការសិក្សាលើការបោះឆ្នោតនៅឆ្នាំ១៩៩៨ ។ ទី៣ ការផ្តោតលើផលប៉ះពាល់នៃដំណើរការប្រែប្រួលរយៈពេលវែងនានា ដែលបានកើតមានតាំងពីឆ្នាំ១៩៩៨ (ជាពិសេសការជួយមតិដ៏ច្រើនរបស់សង្គមស៊ីវិល វិមជ្ឈការអំណាចទៅឱ្យអាជ្ញាធរមូលដ្ឋាន និងកំណែទំរង់ គជប) ដើម្បីវាយតំលៃពីផលប៉ះពាល់ទៅលើទំនាស់ និងការគ្រប់គ្រងទំនាស់ ។ ទី៤ ការពិនិត្យពីវិស័យមួយចំនួនដែលមានកំណែទំរង់តិចតួច (ពិសេសរចនាសម្ព័ន្ធនៃលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ) និងការធ្វើអង្កេតពីភាពសក្តិសិទ្ធិនៃបណ្តាកម្មវិធីទ្រទ្រង់ដោយអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយទំនាស់ក្នុងរឿងនេះ ។



*ទោះជាផ្លូវលិចទឹកបង្កដោយទឹកភ្លៀងធ្លាក់ខ្លាំងក៏ដោយ ក៏អ្នកបោះឆ្នោតនៅកំពង់ស្ពឺ ធ្វើដំណើរទៅកាន់កន្លែងបោះឆ្នោតដែរ ។*

ជារួម ក្រុមស្រាវជ្រាវបានរកឃើញថា ទំនាស់នៅឆ្នាំ២០០៣ មានកំរិតទាបជាងកាលពីឆ្នាំ១៩៩៨ ច្រើន ។ គេគិតថារឿងនេះកើតចេញពីការវិវត្តន៍ជាវិជ្ជមានដូចតទៅៈ ការចូលរួមច្រើនជាងមុនពីសំណាក់គណបក្សធំៗ និងអង្គការក្រៅរដ្ឋាភិបាលក្នុងការងាររៀបចំការបោះឆ្នោត ដូចជា ការតាក់តែងក្របខ័ណ្ឌនិងបទប្បញ្ញត្តិច្បាប់ គ្រឹះច្បាប់កាន់តែលំអិតនិងល្អប្រសើរសំរាប់ការបោះឆ្នោត ការបើកចំហនិងលទ្ធភាពទាក់ទងបានកាន់តែច្រើនក្នុងរបៀបរបបធ្វើការងាររបស់បណ្តាស្ថាប័នបោះឆ្នោតកំរិតជាតិនិងមូលដ្ឋាន និងការចូលរួមកាន់តែច្រើនពី SRP និង FUNCINPEC ក្នុងការងារនយោបាយនៅមូលដ្ឋានតាមរយៈតួនាទីរបស់ពួកគេក្នុងក្រុមប្រឹក្សាឃុំ ។ម្យ៉ាងទៀត ដំនើរការពិគ្រោះយោបល់ ក្នុងនេះមានទាំងក្រុមការងារបង្ការទំនាស់ក្នុងយន្តការបោះឆ្នោតនៅកម្ពុជា (COPCEL) ដែលបានទាក់ទាញការប្តេជ្ញាចិត្តពីអ្នក

* របាយការណ៍ពេញលេញនៃការសិក្សានេះ ដែលផ្តល់ទុនដោយរដ្ឋាភិបាលអូស្ត្រាលី (AusAid) វិបសអ នឹងបោះពុម្ពផ្សាយជាឯកសារ ពិភាក្សានៅខែមករា ២០០៤ ។ ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជារបស់ វិបសអ ទេ ។

## មាតិកា

ការវិវត្តន៍នៃការគ្រប់គ្រងទំនាស់ក្នុងរយៈពេលបោះឆ្នោត.....១
ប្រហុក និងសន្តិសុខស្បៀង.....៦
អ្នកភូមិក្លងសំបេខ្លួនតាមការថយចុះធនធានធម្មជាតិ.....១០
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស.....១៤
— ស្ថានភាពក្នុងប្រទេស.....១៦
— សន្ទស្សន៍សេដ្ឋកិច្ច.....១៧
សទ្ទានុក្រម.....១៩
ព័ត៌មានថ្មីៗពី វិបសអ.....២០

នយោបាយក្នុងជួររដ្ឋាភិបាល គណបក្សប្រឆាំង និង NGOs, ធ្វើឱ្យមជ្ឈដ្ឋានអ្នកនយោបាយកំរិតជាតិមានឆន្ទៈកាន់តែច្រើន ដើម្បីធ្វើការពិភាក្សាដោយចំហ និងមានវិធានការបង្ការទំនាស់ក្នុងការបោះឆ្នោតឆ្នាំ២០០៣ ។

ទោះបីមានការរីកចំរើនដូច្នេះក្តី ក៏នៅតែមានទំនាស់ផុសឡើងនៅឆ្នាំ២០០៣ ជាពិសេសក្រោយពេលផ្សព្វផ្សាយលទ្ធផលបោះឆ្នោត ។ អត្ថបទសង្ខេបនេះបង្ហាញពីការសន្និដ្ឋានមួយចំនួនក្នុងការសិក្សាឆ្នាំ២០០៣ ដែលជាប់ទាក់ទិននឹងការកសាងគំរូមួយនៃការរីករាលដាលទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ។ ដោយប្រើគំរូដែលកសាងបាន ក្រុមស្រាវជ្រាវបានធ្វើការវាយតំលៃលើកម្មវិធីពីរនៃកំណែទំរង់ស្ថាប័ន (គឺកំណែទំរង់ គជប និងវិមជ្ឈការអំណាចទៅឱ្យក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត) និងផលប៉ះពាល់ទៅលើការបោះឆ្នោតឆ្នាំ២០០៣ ។

## ការកសាងគំរូនៃការរីករាលដាលទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា

ការសិក្សាឆ្នាំ១៩៩៨ របស់ វិបសអ បានផ្តល់មតិថា ការរីករាលដាលទំនាស់បានកើតមានឡើងដោយសារកត្តាពីរដែលជាប់ទាក់ទងគ្នាៈ ភាពទន់ខ្សោយនៃស្ថាប័ននានា និងកង្វះស្មារតីជាសហគមន៏នយោបាយក្នុងចំណោមគូភាគីទំនាស់ ។ ការទន់ខ្សោយខាងស្ថាប័នកើតមានឡើងនៅពេលស្ថាប័នរដ្ឋនានា ឬមួយខ្វះសមត្ថភាពបច្ចេកទេស (បណ្តាលពីកង្វះបទពិសោធន៏ កង្វះធនធានឬការដឹកនាំខ្សោយ) ឬមួយខ្វះភាពពេញលក្ខណៈច្បាប់ខាងនយោបាយ (ដោយសារចំណាប់អារម្មណ៏ថាមានការលំអៀងអំពើពុករលួយ ការរំលោភបំពាន ឬភាពមិនតំណាង) ។ កង្វះស្មារតីជាសហគមន៏នយោបាយក្នុងចំណោមគូភាគីទំនាស់ កើតមានឡើងនៅពេលពួកគេមិនទុកចិត្តគ្នា មិនព្រមសហការគ្នា មើលឃើញគ្នាថាជាអ្នកចូលរួមមិនពេញលក្ខណៈច្បាប់ក្នុងដំណើរការនយោបាយ និងជារឿយៗមានការយល់ឃើញផ្ទុយគ្នាជាមូលដ្ឋានអំពីព្រឹត្តិការណ៏នយោបាយនានា ។ ចំណុចទាំងនេះបានគួបផ្សំគ្នាបង្កើនការមិនទុកចិត្តទៅវិញទៅមក និងអឆន្ទៈដើម្បីស្វែងរកដំណោះស្រាយសំរុះសំរួលគ្នាលើការខ្វែងមតិ ។

ទំនាក់ទំនងរវាងភាពទន់ខ្សោយខាងស្ថាប័ន និងស្មារតីជាសហគមន៏នយោបាយក្នុងចំណោមអ្នកនយោបាយ វាមានលក្ខណៈស្មុគស្មាញ ។ កត្តាទាំងពីរនេះអាចជួយពង្រឹងគ្នាទៅវិញទៅមក ឬក៏អាចគួបផ្សំគ្នាបង្កើតជាអន្ទាក់វិលវង់មួយ (vicious circle) ។ ក្នុងនេះសកម្មភាពដ៏មានប្រសិទ្ធភាពពីសំណាក់ស្ថាប័នមានអំណាចនានា អាចជួយផ្តល់ដំណោះស្រាយមានយុត្តិធម៌ និងលើកកំពស់ជំហរផ្សារភ្ជាប់ និងភក្តីភាពចំពោះសហគមន៏នយោបាយ ។ ក្នុងពេលជាមួយគ្នា អារម្មណ៏ដ៏រឹងប៉ឹងនៃទំនុកចិត្ត និងសហប្រតិបត្តិការក្នុងចំណោមសមាជិកនៃសហគមន៏នយោបាយ នឹងអនុញ្ញាតឱ្យមានការផុសឡើងនូវស្ថាប័នដ៏មានអំណាចនានាដែលអាចធ្វើសកម្មភាពបានយ៉ាងមានប្រសិទ្ធភាព (ក្រាហ្វិក១) ។ ផ្ទុយទៅវិញ ទំនុកចិត្តខ្សោយ និងកិច្ចសហប្រតិបត្តិការខ្សោយ ច្រើនតែធ្វើឱ្យខូចខាតដល់លទ្ធភាពធ្វើការងាររបស់ស្ថាប័ននានា ហើយស្ថាប័ននានាដែលទន់ខ្សោយ និងធ្វើប្រតិបត្តិការតាមបែបបទមិនរលូនល្អនិងគ្មានប្រសិទ្ធភាព ច្រើនតែបង្កើនភាពមិនទុកចិត្តគ្នារវាងតួអង្គនានាខាងនយោបាយ និងកាត់បន្ថយកំរិតនៃកិច្ចសហប្រតិបត្តិការខាងនយោបាយ (ក្រាហ្វិក២) ។ ក្នុងករណីសិក្សានានាពីទំនាស់ដែលផុសឡើងនៅឆ្នាំ២០០៣ មានការប្រើគំរូនេះ សំរាប់ធ្វើវិភាគដោយយកចិត្តទុកដាក់ជាពិសេសដល់បែបបទដែល ការគ្រប់គ្រងទំនាស់មិនសមស្របដោយស្ថាប័នមួយចំនួន បានបង្កការរីករាលដាលទំនាស់ដូចមានបង្ហាញក្នុងក្រាហ្វិក២ ។

ការគ្រប់គ្រងទំនាស់មានសារៈសំខាន់ណាស់ក្នុងដំណើរការនេះ ។ ទាំងការសិក្សាឆ្នាំ២០០៣ និង ១៩៩៨ បានបង្ហាញថា យន្តការសំរាប់គ្រប់គ្រងទំនាស់ដែលមិនសក្តិសិទ្ធិឬមិនពេញលក្ខណៈច្បាប់ ច្រើនតែបង្កើនការមិនទុកចិត្តគ្នា និងការរីករាលដាលទំនាស់ ។ ផ្ទុយទៅវិញ យន្តការសំរាប់គ្រប់គ្រងទំនាស់ដែលសក្តិសិទ្ធិ និងពេញលក្ខណៈច្បាប់ អាចជួយជំរុញទំនាក់ទំនងដ៏មានផ្លែផ្ការវាងគូភាគីនានានៃទំនាស់ និងរវាងគណបក្ស និងស្ថាប័នរដ្ឋនានា ។ បែបបទដែលយន្តការមិនសក្តិសិទ្ធិសំរាប់គ្រប់គ្រងទំនាស់ ធ្វើឱ្យចុះខ្សោយដល់អារម្មណ៏ផ្សារភ្ជាប់របស់គណបក្សរងគ្រោះ ជាមួយនឹងតួអង្គស្ថាប័ននានា (និងបង្កើនការមិនទុកចិត្តគ្នារវាងគណបក្សនយោបាយនានា) គឺមានបង្ហាញក្នុងក្រាហ្វិក៣ ។ ទាំងការសិក្សាឆ្នាំ២០០៣ និង ១៩៩៨ បានបង្ហាញថា មានការខុសគ្នាជារឿយៗក្នុងវិធីដែលបណ្តាគណបក្សនយោបាយបកស្រាយបញ្ហានានានៅក្នុងដំណើរការបោះឆ្នោត ។ ខណៈដែលតួអង្គមួយក្រុម តែងមើលឃើញការលំបាកផ្សេងៗខាងនីតិវិធីថាជាការខ្វះខាតខាងបច្ចេកទេស ប៉ុន្តែមួយក្រុមទៀតតែងមើលឃើញថាជា "ល្បិចកលខាងនយោបាយ" ។ ចំណាប់អារម្មណ៏ខុសគ្នាជាមូលដ្ឋានបែបនេះអំពីព្រឹត្តិការណ៏នានា ធ្វើឱ្យគេពិបាកនឹងរកបាននូវយន្តការគ្រប់គ្រងទំនាស់ដែលអាចដោះស្រាយការព្រួយបារម្ភរបស់ភាគីទាំងពីរបាន ។ នៅពេលស្ថាប័នរដ្ឋ មិនអាចរកបានយន្តការគ្រប់គ្រងទំនាស់ដែលអាចដោះស្រាយគំនិតយល់ឃើញទាំងពីរបែប ប៉ុន្តែដោះបានតែមួយ, ទំនាស់វាច្រើនតែរីករាលដាល ។ ដោយសារដំណើរការខាងស្ថាប័នបានដោះស្រាយតែការបកស្រាយមួយបែប ដូច្នេះវាធ្វើឱ្យភាគីឯទៀតៗយល់ឃើញថា ការព្រួយបារម្ភរបស់ខ្លួនមិនត្រូវបានយកមកពិចារណាទេ ។ រឿងនេះនាំឱ្យមានការថយចុះអារម្មណ៏ផ្សារភ្ជាប់ជាមួយបណ្តាស្ថាប័ននិង ដំណើរការបោះឆ្នោត ការមិនទុកចិត្តកាន់តែខ្លាំងចំពោះគូប្រឆាំងខាងនយោបាយ និងការកាត់បន្ថយទំហំឆន្ទៈល្អដែលត្រូវមាន ដើម្បីចរចារកដំណោះស្រាយសំរុះសំរួល ។

**ក្រាហ្វិក១. ស្ថាប័ននានា និងសហគមន៏នយោបាយៈ បែបបទល្អនៃការគ្រប់គ្រងទំនាស់ដ៏សក្តិសិទ្ធិ**




**ក្រាហ្វិក២. ស្ថាប័ននានា និងសហគមន៏នយោបាយៈ អន្ទាក់វិលវង់នៃការគ្រប់គ្រងទំនាស់មិនសក្តិសិទ្ធិ**



គំរូនេះផ្តល់ការទស្សន៍ទាយពីលទ្ធភាពមានជោគជ័យនៃយន្តការគ្រប់គ្រងទំនាស់ សំរាប់ទំនាស់ដ៏ជាក់លាក់នានា ។ ផ្អែកលើការសិក្សាពីការរីករាលដាលទំនាស់ពីឆ្នាំ១៩៩៨ ដល់ ២០០៣, ការសិក្សាឆ្នាំ២០០៣ បង្ហាញថា លក្ខណៈវិនិច្ឆ័យដូចខាងក្រោមអាចជួយជំរុញឱ្យមានការគ្រប់គ្រងទំនាស់ដ៏សក្តិសិទ្ធិ:

- មានការឯកភាពគ្នាពីចរិតនៃទំនាស់
- មានការឯកភាពគ្នាពីយន្តការសមស្របដើម្បីគ្រប់គ្រងទំនាស់
- អ្នកគ្រប់គ្រងទំនាស់មានសិទ្ធិអំណាចគ្រប់គ្រាន់សំរាប់អនុវត្តដំណើរការគ្រប់គ្រងទំនាស់, ក្នុងនេះមានទាំងការដាក់ទោសអ្នកប្រព្រឹត្តខុសដែលមកពីស្ថាប័នឯទៀតៗផង
- មានការឯកភាពគ្នាពីលក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងជោគជ័យ
- យន្តការសំរាប់គ្រប់គ្រងទំនាស់គឺ មានដាក់អនុវត្តយ៉ាងសក្តិសិទ្ធិ មានតំលាភាព និងអាចទាក់ទងប្រើប្រាស់បាន ។

បើសិនមានលក្ខណៈវិនិច្ឆ័យណាមួយបំពេញមិនបាន ការគ្រប់គ្រងទំនាស់ប្រហែលមិនបានសក្តិសិទ្ធិល្អទេ ។

ការសិក្សាពីទំនាស់ក្នុងការបោះឆ្នោតឆ្នាំ២០០៣ បង្ហាញថា ចំពោះទំនាស់ធំៗបំផុតក្នុងឆ្នាំនោះ (ទំនាស់ពីក៏រិតសន្តិសុខសំរាប់ការបោះឆ្នោត ទំនាស់ពីតួនាទីរបស់ប្រធានភូមិ ទំនាស់ទាក់ទិននឹងការចុះបញ្ជីអ្នកបោះឆ្នោត និងទំនាស់ពីចំណាត់ការរបស់ គជប លើពាក្យបណ្តឹង) គំរូនេះបានពិពណ៌នាយ៉ាងត្រឹមត្រូវពីដំណើរការរីករាលដាលទំនាស់ ដែលនាំទៅដល់ការមិនទទួលស្គាល់លទ្ធផលដោយគណបក្សប្រឆាំងនៅក្រោយពេលបោះឆ្នោត ។ ដូច្នេះគំរូនេះមានប្រយោជន៍ សំរាប់ការវាយតំលៃពីវិភាគទាននៃបណ្តាកម្មវិធីផ្លាសប្តូរស្ថាប័នដើម្បីជួយពង្រឹងការគ្រប់គ្រងទំនាស់ក្នុងពេលបោះឆ្នោត ។

### *ការកែប្រែខាងស្ថាប័ន: កំណែទំរង់ គជប*

ការសិក្សាឆ្នាំ១៩៩៨ របស់ វបសអ បានរកឃើញថា ដំណើរការបង្កើត គជប, អាណត្តិ គជប, និងបែបបទធ្វើប្រតិបត្តិការរបស់ គជប, គឺជាឧបសគ្គដ៏ធំចំពោះការគ្រប់គ្រងទំនាស់ឱ្យបានសក្តិសិទ្ធិក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ ។ គជប ត្រូវបានបង្កើតឡើងក្នុងពេលដែលគណបក្សនយោបាយខ្លះស្ថិតនៅក្រៅប្រទេស, អាណត្តិ និងអំណាចនៃ គជប កំណត់មិនច្បាស់, សមាជិកនៅក៏រិតជាតិមានលក្ខណៈនយោបាយយ៉ាងចំហ, និងសមាជិកនៅក៏រិតមូលដ្ឋានទទួលការចោទប្រកាន់ជាទូទៅថាលំអៀង, វិធីធ្វើប្រតិបត្តិការមានចោទទាំងបញ្ហាបច្ចេកទេស និងកង្វះការយកចិត្តទុកដាក់ពីតំលាភាព ការបានចូលរួម ឬភាពរលូនល្អ ។ ដោយមូលហេតុនេះ គជប នៅតែទន់ខ្សោយ មានដំណើរការមិនរលូនល្អ ហើយក្នុងការសិក្សារបស់ វបសអ មានអ្នកឆ្លើយសំភាសន៍ជាច្រើនយល់ថា គជប គ្មានភាពពេញលក្ខណៈច្បាប់ទេ ។

**ក្រាហ្វិក៣. គំរូនៃការរីករាលដាលទំនាស់: ការគ្រប់គ្រងទំនាស់អន់ខ្សោយបង្កើនការមិនទុកចិត្តគ្នា**




ពីឆ្នាំ១៩៩៨-២០០៣ មានការអនុម័តកំណែទំរង់មួយចំនួនដើម្បីឆ្លើយតបនឹងការទិតៀននៅឆ្នាំ១៩៩៨ ហើយក៏នាំឱ្យមានការជជែកវែកញែកថ្មីៗទៀត ។ ការសិក្សាពីការបោះឆ្នោតឆ្នាំ២០០៣ បានរកឃើញបញ្ហាចោទបីប្រភេទ គឺភាពមិនលំអៀង ស្វ័យភាព និងចរិតនៃរបៀបរបបធ្វើការងារ ដែលនៅលេចធ្លោជាងគេសំរាប់យកមកវែកញែកវិភាគលើកំណែទំរង់ គជប ក្នុងឆ្នាំ២០០២-០៣ ។

## ភាពមិនលំអៀងរបស់ គជប

ការទិតៀនពីភាពមិនលំអៀងរបស់ គជប នៅឆ្នាំ១៩៩៨ ផ្តោតលើទាំងដំណើរការជ្រើសរើស ដែលធ្វើឱ្យសមាជិកមានលក្ខណៈតំណាងយ៉ាងចំហនូវគណបក្សឬផលប្រយោជន៍តាមផ្នែក, និងលើការចោទប្រកាន់កាន់តែច្រើនថា គជប គឺត្រួតត្រាដោយគណបក្សប្រជាជនកម្ពុជា (CPP) ហើយទទួលបញ្ជាផ្ទាល់ពីគណបក្សនេះ ទាំងនៅក៏រិតជាតិ និងក៏រិតមូលដ្ឋាន ។ ការផ្លាស់ក្នុងសមាសភាព គជប នៅឆ្នាំ២០០២ មានជាអាទិ៍ ការជ្រើសយកសមាជិកឯករាជ្យ ជាជាងយកបេក្ខជនរបស់គណបក្ស ។ វិសោធនកម្មច្បាប់បោះឆ្នោតបានតំរូវថា សមាជិកនៃ គខប និង គឃប ត្រូវជ្រើសរើសឡើងវិញស្របតាមលក្ខណៈវិនិច្ឆ័យខាងសមត្ថភាពដែលមានចែងច្បាស់ ។ ប្រភេទមន្ត្រីនៅមូលដ្ឋាន ដែលត្រូវហាមចូលបំរើក្នុងគណៈកម្មាធិការបោះឆ្នោតនៅមូលដ្ឋាន ត្រូវបានពង្រីកបន្ថែម ។

ទាក់ទិននឹងការផ្លាស់ប្តូរទាំងនេះ មានការទិតៀនថ្មីៗទៀតបានផុសឡើងដែលចោទថា ដំនើរការជ្រើសរើសថ្មីសំរាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) គណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត (គខប) និងគណៈកម្មាធិការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃប) គ្មានតម្លាភាពគ្រប់គ្រាន់ទេ ។ សមាជិក គជប ត្រូវស្នើឈ្មោះឡើងដោយក្រសួងមហាផ្ទៃ ហើយគណបក្សប្រឆាំង និងបណ្តាអង្គការតាមដានការបោះឆ្នោតបានចោទថា ដោយសារក្រសួងមហាផ្ទៃ គឺត្រួតត្រាដោយគណបក្សនៅក្នុងរដ្ឋាភិបាល (CPP និង FUNCINPEC) ដូច្នេះដំណើរការជ្រើសរើសបែបនេះ មិនអាចធានាភាពមិនលំអៀងរបស់ គជប បានទេ ។ ការទិតៀនចំពោះនីតិវិធីក៏រិតមូលដ្ឋានមានដូចជាការចោទថា ពុំមានការផ្សព្វផ្សាយគ្រប់គ្រាន់ទេនូវមុខតំណែងត្រូវជ្រើសរើស ដែលច្រើនតែធ្វើឱ្យបុគ្គលដដែលត្រូវបានជ្រើសរើសឱ្យបំរើការម្តងទៀត គឺវាបំផ្លាញចោលអស់នូវឥទ្ធិពលល្អនៃកំណែទំរង់ និងមានស្ត្រីតិចពេកក្នុងគណៈកម្មាធិការបោះឆ្នោត ធ្វើឱ្យគណៈកម្មាធិការគ្មានភាពតំណាងឱ្យប្រជាជន ។

## ស្វ័យភាពរបស់ គជប

ការទិតៀនពីស្វ័យភាពរបស់ គជប នៅឆ្នាំ១៩៩៨ ផ្តោតលើការអះអាងថាទី១ ដែនសមត្ថកិច្ចរបស់ គជប មិនច្បាស់លាស់ ឬមិនសមស្រប និង ទី២

ទោះបី គជប មានសមត្ថកិច្ចក្នុងករណីជាក់លាក់អ្វីមួយ ប៉ុន្តែស្ថាប័នឯទៀតៗបានរារាំង គជប ក្នុងការធ្វើប្រតិបត្តិការឱ្យបានសក្តិសិទ្ធិ និងមានសិទ្ធិអំណាច ។ ចំពោះ គខប និង គឃប ក៏មានការទិតៀនដូច្នេះដែរ ។ នៅឆ្នាំ២០០៣ សិទ្ធិអំណាចរបស់ គជប មានចែងកាន់តែលំអិតនៅក្នុងច្បាប់វិសោធនកម្មនៃច្បាប់បោះឆ្នោត ។ ជាពិសេសមានការយកចិត្តទុកដាក់កាន់តែច្រើនចំពោះតួនាទីផ្សេងៗរបស់អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការបោះឆ្នោតថ្នាក់មូលដ្ឋាន ។ ការប្រើក្រមសីលធម៌ដើម្បីតំរែតំរង់ឥរិយាបទតួអង្គផ្សេងៗខាងនយោបាយ និងខាងស្ថាប័នរដ្ឋ បានញុំាងឱ្យតួនាទីរបស់ភាគីនានាបានកាន់តែច្បាស់លាស់ថែមទៀត ។

ថ្វីបើកិច្ចប្រឹងប្រែងទាំងនេះបានជួយកែលំអស្ថានការណ៍ ប៉ុន្តែនៅមានការយល់ខុសច្រើនណាស់ពីដែនសមត្ថកិច្ចពិតរបស់ គជប និងមានការឈ្លោះគ្នាច្រើនណាស់ពីរឿងនេះ ។ ក្នុងវិស័យខ្លះ ដូចជាបញ្ហាសន្តិសុខជាដើម សមត្ថកិច្ចរបស់ គជប គឺមានកំរិត ។ បទល្មើសព្រហ្មទណ្ឌគឺជាដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ ។ ប៉ុន្តែការស្រាវជ្រាវក្នុងឆ្នាំ២០០៣ បង្ហាញថា ជួនកាល គឃប បានខិតខំគ្រប់គ្រងទំនាស់ ដែលគួរតែទុកឱ្យប៉ូលីសដោះស្រាយ ពីព្រោះមានបទឧក្រិដ្ឋ ។ ក្នុងករណីខ្លះទៀតតួអង្គខាងនយោបាយបានទិតៀន គជប ចំពោះការមិនបានចាត់វិធានការក្នុងព្រឹត្តិការណ៍ ដូចជាមានឃាដកម្មនយោបាយជាដើម ដែលត្រូវហួសពីសមត្ថកិច្ចរបស់ គជប ។ ដូចគ្នាដែរ តួនាទី គជប ក្នុងការដោះស្រាយបណ្តឹងតវ៉ាក្រោយការបោះឆ្នោត គឺជាបញ្ហាជំទាស់គ្នាក្តៅគគុក ។ តួអង្គខាងនយោបាយមួយចំនួនអះអាងថា គជប មិនគួរមានតួនាទីដោះស្រាយការតវ៉ាប្រឆាំងនឹងបុគ្គលិករបស់ គជប ខ្លួនឯងផ្ទាល់នោះទេ ។

បញ្ហាផ្សេងទៀតទាក់ទិននឹងដែនសមត្ថកិច្ច គជប មានដូចជា គជប ខ្វះលទ្ធភាពដាក់បង្ខំឱ្យអនុវត្តក្រមសីលធម៌របស់ប្រព័ន្ធផ្សព្វផ្សាយ ។ ច្បាប់មិនបានផ្តល់អំណាចឱ្យ គជប ដាក់ទណ្ឌកម្មអ្នករំលោភក្រមសីលធម៌ទេ ធ្វើឱ្យក្រមនេះ មិនសូវសក្តិសិទ្ធិល្អក្នុងការគ្រប់គ្រងសកម្មភាពរបស់តួអង្គខាងនយោបាយ ។ ច្បាប់ក៏មិនបានចែងឱ្យ គជប មានសិទ្ធិអំណាចលើប្រធានភូមិដែរ ហើយជាលទ្ធផល គជប ត្រូវស្នើសុំឱ្យក្រសួងមហាផ្ទៃជួយដោះស្រាយពីការចោទប្រកាន់លើប្រធានភូមិពីបទទិញសន្លឹកឆ្នោត ឬធ្វើការបំភិតបំភ័យ ។

លើសពីនេះទៀត មានការបន្តចោទប្រកាន់ថា គជប ទទួលបញ្ជាពី គបក ហើយតួអង្គខាងនយោបាយខ្លះបន្តចោទថា សឹងតែគ្រប់កង្វះខាតក្នុងប្រតិបត្តិការរបស់ គជប គឺកើតមានឡើងដោយសារតែរឿងនេះ ។ នៅកំរិតមូលដ្ឋាន មានការទិតៀនពីការពឹងផ្អែករបស់ គជប ទៅលើប្រធានភូមិ ដើម្បីផ្សព្វផ្សាយពត៌មានដល់ប្រជាជន និងមានការអះអាងថា ការជ្រើសរើសគ្រូបង្រៀនឱ្យបំរើការក្នុង គឃប បានធ្វើឱ្យមន្ត្រី គឃប ងាយទទួលរងការបំភិតបំភ័យពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលជាអ្នកប្រើប្រាស់ពួកគេស្ទើរពេញៗមួយឆ្នាំ ។ អ្នកតាមដានការបោះឆ្នោត ក៏អះអាងដែរថា ឃើញមានច្រើនហួសពេកនូវពួកមន្ត្រី គខប និង គឃប ដែលមានខ្សែរយៈជាប់ជាមួយ គបក ។

## សមត្ថភាពបច្ចេកទេសរបស់ គជប

សមត្ថភាពបច្ចេកទេសរបស់ គជប គឺជាបញ្ហាចំបងមួយនៅឆ្នាំ១៩៩៨ (ឆ្នាំមានការបោះឆ្នោតលើកទី១ ដែលរៀបចំដោយស្ថាប័នរដ្ឋកម្ពុជា គិតតាំងពីពេលមានសង្គ្រាមមក) ប៉ុន្តែនៅឆ្នាំ២០០៣ បញ្ហានេះបានថយចុះវិញ ។ បទពិសោធន៍កាន់តែច្រើនរបស់មន្ត្រីបោះឆ្នោត ធ្វើឱ្យសមត្ថភាពកើនឡើងដូច្នេះហើយបើសិនមានកំហុសឆ្គងអ្វីមួយ គេច្រើនតែចោទថា បង្កដោយកត្តាខាងនយោបាយ ។ ការតវ៉ានៅឆ្នាំ១៩៩៨ អំពីដំណើរការគ្មាន តម្លាភាព ឬការបើកចំហឱ្យចូលរួម, គជប អាចដោះស្រាយបានមួយកំរិតនៅឆ្នាំ២០០៣ តាមការប្រឹងប្រែងបើកចំហឡើង ។ នៅកំរិតជាតិ គឺមានការជួបប្រជុំប្រចាំសប្តាហ៍ជាមួយគណបក្សនយោបាយ NGOs និងតំណាងប្រព័ន្ធផ្សព្វផ្សាយ, ការចូលរួមយ៉ាងទៀងទាត់របស់ គជប ក្នុងវេទិកា COPCEL, និងការយកចិត្តទុកដាក់កាន់តែច្រើនដល់ការផ្តល់ពត៌មានឱ្យបានរហ័ស ទៅឱ្យមជ្ឈដ្ឋានសារពត៌មាន ។ នៅកំរិតមូលដ្ឋាន គឺមានការជួបប្រជុំប្រចាំសប្តាហ៍ជាមួយអ្នកឃោសនារបស់គណបក្សនៅឯការិយាល័យ គឃប ដើម្បីបញ្ជូនពត៌មានពីថ្នាក់លើ ទទួលបណ្តឹងតវ៉ា និងពិភាក្សាពីបញ្ហានានាដែលផុសឡើងទាក់ទិននឹងការឃោសនា ឬការបោះឆ្នោត ។

អ្នកឆ្លើយសំភាសន៍ជាទូទៅក្នុងការសិក្សានេះ បានកោតសរសើរដល់ការប្រឹងប្រែងនេះនៅមុនពេលបោះឆ្នោត ។ ប៉ុន្តែនៅក្រោយពេលបោះឆ្នោត មានការទិតៀនជាទូទៅដល់សមត្ថភាពរបស់ គជប ក្នុងការដោះស្រាយបណ្តឹងតវ៉ា ។ ដូចឆ្នាំ១៩៩៨ដែរ ដំណើរការប្តឹងតវ៉ា គឺជារឿងមួយដ៏ស្មុគស្មាញបំផុតក្នុងការបោះឆ្នោត ។ ថ្វីបើនីតិវិធីប្តឹងតវ៉ា មានចែងក្នុងច្បាប់នឹងបទប្បញ្ញត្តិនៅឆ្នាំ២០០៣យ៉ាងលំអិត ច្រើនជាងកាលពីឆ្នាំ១៩៩៨ក្តី ប៉ុន្តែនៅតែមានអ្នកបន្តទិតៀនពីការលំបាកក្នុងការដាក់ពាក្យបណ្តឹង ដោយសារជំហររឹងរូសជាផ្លូវការ ឬការទាមទារមិនសមរម្យទាក់ទិននឹងការផ្តល់ភស្តុតាងបញ្ជាក់ការតវ៉ា ។ មានការទិតៀន គជប ផងដែរពីកង្វះភាពទន់ភ្លន់និងតំលាភាពទាក់ទិននឹងការសំរេចយល់ព្រមទទួលយកពាក្យបណ្តឹង និងអំណាចរបស់ គជប ក្នុងការបដិសេធពាក្យបណ្តឹងប្រឆាំងនឹង គជប ខ្លួនឯង ។

## លទ្ធផលនៃកំណែទំរង់ គជប

ថ្វីបើមានការកែលំអច្រើនណាស់ហើយក៏ដោយ ប៉ុន្តែ នៅមានការមិនពេញចិត្តច្រើនណាស់ចំពោះ គជប ជាពិសេសទាក់ទិននឹងសកម្មភាពក្រោយពេលបោះឆ្នោត ។ ប្រតិបត្តិការរបស់ គជប នៅមុនពេលបោះឆ្នោតបានទទួលការកោតសរសើរច្រើនជាងឆ្នាំ១៩៩៨ខ្លាំងណាស់ ។ គណបក្សប្រឆាំង និងអង្គការតាមដានការបោះឆ្នោតនានា នៅតែបន្តមិនទុកចិត្តចំពោះភាពមិនលំអៀង និងស្វ័យភាពរបស់ គឃប ថ្វីបើនៅកំរិតមូលដ្ឋាន គណបក្សធំៗទាំងអស់បានចូលពាក់ព័ន្ធក្នុងកម្មវិធីសកម្មភាពរបស់ គឃប ក្តី ។

ប្រតិបត្តិការនៃ គជប នៅតែមានការប៉ះពាល់មិនល្អដោយសារកង្វះភាពច្បាស់លាស់ ទាក់ទិនជាមួយនឹងស្ថាប័នឯទៀតៗ ។ ដោយឡែក សកម្មភាពរបស់ក្រសួងមហាផ្ទៃ (ដែលមានភារកិច្ចជ្រើសរើសសមាជិក គជប រក្សាសន្តិសុខ និងដាក់វិន័យលើមន្ត្រីមូលដ្ឋាន) ត្រូវធ្វើឱ្យមានតំលាភាព និងគណនេយ្យភាពខ្ពស់ថែមទៀត ដើម្បីឱ្យស៊ីគ្នានឹងការខំប្រឹងប្រែងរបស់ គជប ក្នុងរឿងនេះ ។ ដូចគ្នាដែរ ការជួយទ្រទ្រង់ដ៏ច្បាស់លាស់របស់ក្រសួងពត៌មានក្នុងការចាត់ចែងជាមួយប្រព័ន្ធផ្សព្វផ្សាយ នឹងធ្វើឱ្យ គជប មានជំហរកាន់តែរឹងប៉ឹង និងសក្តិសិទ្ធិ ។ ការចូលរួមច្រើនថែមទៀតពីសំណាក់ស្ថាប័នទាំងពីរនៅក្នុងដំណើរការកសាងតំលាភាព និងគណនេយ្យភាពរបស់ គជប នឹងជួយរួមចំណែកយ៉ាងសំខាន់ដល់ការគ្រប់គ្រងទំនាស់ក្នុងពេលបោះឆ្នោត ។

### *ការផ្លាស់ប្តូរខាងស្ថាប័នៈ វិមជ្ឈការ*

ការធ្វើវិមជ្ឈការអំណាចទៅឱ្យក្រុមប្រឹក្សាឃុំ គឺជាជំហានមួយដ៏សំខាន់គួរកត់សំគាល់ ពីព្រោះអាជ្ញាធរមូលដ្ឋានបានទទួលការទិតៀនខ្លាំងណាស់នៅឆ្នាំ១៩៩៨ ថាបានធ្វើសកម្មភាពខុសច្បាប់ ដូចជា ការទិញសន្លឹកឆ្នោត ការបំភិតបំភ័យ ការដកហូតប័ណ្ណបោះឆ្នោត ការរៀបចំពិធីស្បថស្បែរផ្សេងៗ

ដើម្បីប្រមូលសមាជិកថ្មីចូល CPP និងការប្រើធនធានរដ្ឋដើម្បីធ្វើការឃោសនា ។ ជាគោលការណ៍ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំមានគណបក្សច្រើនចូលរួម ត្រូវបង្កើតបាននូវស្ថានភាពនយោបាយពហុបក្សនៅអាជ្ញាធរកំរិតមូលដ្ឋាន ដែលនឹងទប់ស្កាត់ការរំលោភអំនាចបែបនេះបាន ។ ក្រុមស្រាវជ្រាវបានស៊ើបអង្កេតពីរឿងនេះតាមរយៈករណីសិក្សាលើ ៩ឃុំ ក្នុងខេត្តតាកែវ កំពត បាត់ដំបង និងកំពង់ចាម ។

ក្នុងករណីសិក្សាលើឃុំទាំងនេះ បានរកឃើញថា ផលប៉ះពាល់នយោបាយជាវិជ្ជមាននៃវិមជ្ឈការមានជាអាទិ៍ តួនាទីតាមច្បាប់កំណត់ នៃគណបក្សធំៗទាំងបីនៅក្នុងឃុំភាគច្រើន ហើយតួនាទីនេះបានអនុវត្តយ៉ាងហោចណាស់ ១៨ខែមុនការបោះឆ្នោតឆ្នាំ២០០៣ ។ នេះជាចំណុចកែលំអមួយធំណាស់ បើធៀបនឹងឆ្នាំ១៩៩៨ ។ តួនាទីជាអ្នកឈ្នះឆ្នោតក្នុងក្រុមប្រឹក្សាឃុំ បានផ្ដល់ភាពពេញច្បាប់ដល់វត្តមានសកម្មជនរបស់គណបក្សធំៗទាំងបីនៅក្នុងឃុំ និងអនុញ្ញាតឱ្យគណបក្សពង្រីកបណ្ដាញរបស់ខ្លួន ។ រឿងនេះបានបង្កើនជាពិសេសនូវកំលាំងខាងស្ថាប័ននៃគណបក្សប្រឆាំង SRP ។ គេបានកត់សំគាល់ដែរថា ក្នុងឃុំខ្លះ បទពិសោធន៍ធ្វើការងាររួមគ្នាជាដៃគូចំនួន ១២ខែ ជាមួយគណបក្សនយោបាយប្រជែងគ្នា បានកាត់បន្ថយការមិនទុកចិត្តគ្នា និងជំរុញទំនាក់ទំនងមិត្តភាពរវាងគណបក្សនានា ប៉ុន្ដែវិសាលភាព និងភាពរឹងប៉ឹងនៃទំនាក់ទំនងនេះ គេពិបាកវាស់វែងឱ្យបានច្បាស់ ។

មានកំហិតសំខាន់ៗមួយចំនួន ចំពោះផលប៉ះពាល់ខាងនយោបាយនៃវិមជ្ឈការ ។ ទី១ សមាជិកក្រុមប្រឹក្សាឃុំជាច្រើន ជាពិសេសមកពីគណបក្ស FUNCINPEC និង SRP និងពី CPP ផងដែរ, ខ្វះបទពិសោធន៍ ដូច្នេះមិនបាន កាន់កាប់អំណាចទៅតាមបែបបទដែលគួរធ្វើនោះទេ ទាំងទាក់ទិននឹងសមាជិកក្រុមប្រឹក្សាឃុំផងគ្នា ទាំងទាក់ទិននឹងអ្នកក្រៅ ដូចជា ប្រធានភូមិជាដើម ។ ក្រុមប្រឹក្សាឃុំនានាមិនទាន់ចាប់ផ្ដើមអនុវត្តគោលនយោបាយទេ ពីព្រោះមិនទាន់បានទទួលមូលនិធិបែងចែកឱ្យ ដូច្នេះមានបទពិសោធន៍តិចតួចក្នុងការដោះស្រាយបញ្ហាជាក់ស្ដែង ។ រឿងនេះបានកាត់បន្ថយលទ្ធភាពកសាងរបៀបរបបធ្វើការរឹងប៉ឹង និងទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន បើធៀបនឹងទំនាក់ទំនងជាមួយគណបក្សរៀងៗខ្លួន ។ ក្រុមប្រឹក្សាឃុំមានធនធានតិចតួច សំរាប់ធ្វើសកម្មភាពក្នុងការងារទាក់ទិននឹងការបោះឆ្នោត ។ ក្នុងឃុំខ្លះ សមាជិកក្រុមប្រឹក្សាឃុំដែលមកពី FUNCINPEC និង SRP បានរាយការណ៍ថា ខ្លួនត្រូវសហសេវិកមកពី CPP ផាត់ចេញពីតួនាទីមានឥទ្ធិពល ។ ក្នុងឃុំខ្លះទៀត ប្រធានភូមិហាក់ដូចរាយការណ៍ឡើងផ្ទាល់ទៅថ្នាក់ស្រុក ឬទៅគណបក្សនយោបាយរបស់ខ្លួន ដោយរំលងចោលក្រុមប្រឹក្សាឃុំ ។

លទ្ធផលវិជ្ជមានអាចកត់សំគាល់បាននៃវិមជ្ឈការនៅក្នុងដំណើរការបោះឆ្នោតឆ្នាំ២០០៣ គឺមានសេរីភាពធំទូលាយជាងកាលពីឆ្នាំ១៩៩៨ ដើម្បីធ្វើការឃោសនាក្នុងឃុំ (ប៉ុន្ដែមានការទិតៀនច្រើនឡើងពីអាជ្ញាធរមូលដ្ឋានឯទៀត ជាពិសេសប្រធានភូមិ) ។ ប៉ុន្ដែកង្វះបទពិសោធន៍នៃក្រុមប្រឹក្សាឃុំ បានប៉ះពាល់ដល់លទ្ធភាពបំពេញតួនាទីថ្មីនៃការចុះបញ្ជីអ្នកបោះឆ្នោត ហើយរឿងនេះក៏ក្លាយជាប្រភពទំនាស់យ៉ាងច្រើននៅក្រោយថ្ងៃបោះឆ្នោត ។ម្យ៉ាងទៀតកង្វះបទពិសោធន៍នៃសមាជិកក្រុមប្រឹក្សាឃុំមកពី FUNCINPEC និង SRP និងរបស់គណបក្សទាំងពីរនេះក្នុងការកសាងបណ្ដាញរឹងមាំនៅកំរិតមូលដ្ឋាន បានកាត់បន្ថយលទ្ធភាពរបស់ពួកគេក្នុងការប្រជែងជាមួយយុទ្ធសាស្ត្ររៀបចំអង្គការចាត់តាំងក្នុងឃុំដ៏ជំនាញរបស់ CPP ។ រឿងនេះសំខាន់ណាស់ ពីព្រោះ FUNCINPEC និង SRP ក្រោយមកបានអះអាងថាអ្នកគាំទ្ររបស់ខ្លួន មិនបានទទួលពត៌មានគ្រប់គ្រាន់ពីភ្នាក់ងាររដ្ឋអំពីការចុះបញ្ជី និងការទៅបោះឆ្នោត ។ នៅថ្ងៃបោះឆ្នោត ខាង CPP អាចកេណ្ឌបានយ៉ាងសក្ដិសិទ្ធិនូវអ្នកគាំទ្ររបស់ខ្លួន ប៉ុន្ដែខាង FUNCINPEC និង SRP ខ្វះជំនាញច្រើនណាស់ក្នុងការងារនេះ ។

ដោយមូលហេតុខាងលើ ទំនាស់មួយចំនួននៅតែមិនអាចដោះស្រាយបាននៅកំរិតមូលដ្ឋាន គឺការតវ៉ាថាមាន ការចុះបញ្ជីអ្នកបោះឆ្នោត "បរទេស" ខុសច្បាប់ដោយស្មៀនឃុំ ការចែកចាយពត៌មានមិនស្មើភាពទៅដល់អ្នកគាំទ្រគណបក្សខុសៗគ្នា, អ្នកភូមិត្រូវបានប្រធានភូមិបំភិតបំភ័យ ហើយក៏ខ្លាចរអាក្នុងការពិភាក្សាដោយចំហពីរឿងនយោបាយ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនបានឆ្លើយតបសមស្របទេចំពោះបញ្ហាចោទ និងការតវ៉ា ។

ពេលនេះវាឆាប់ពេកហើយ ដើម្បីធ្វើការវាយតំលៃពីផលប៉ះពាល់រយៈពេលវែងនៃវិមជ្ឈការ ប៉ុន្ដែឥទ្ធិពលរយៈពេលខ្លីដ៏សំខាន់បំផុតគឺ ការពង្រីកសេរីភាពឱ្យសកម្មជនគណបក្សនយោបាយក្នុងឃុំភាគច្រើន ។ ប៉ុន្ដែការស្រាវជ្រាវបានរកឃើញថា សមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សខុសៗគ្នានៅមានការខ្វែងមតិគ្នាជ្រាលជ្រៅណាស់ពីរឿង បំភិតបំភ័យ អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការបោះឆ្នោត កាន់ជើងគណបក្សនយោបាយ, ការទិញសន្លឹកឆ្នោត និងលទ្ធភាពទទួលបានពត៌មាន ។ រឿងនេះបានផ្ដល់គំនិតថា តំណាងគណបក្សកំរិតមូលដ្ឋានខ្វះខាតទឹកចិត្តរឹងប៉ឹង ដើម្បីលើកកម្ពស់សហគមន៍នយោបាយ និងកិច្ចសហប្រតិបត្តិការ ហើយទៅអនាគតអាចមានបញ្ហាចោទ ក្នុងការស្វែងរកការមូលមតិរវាងគណបក្សខុសៗគ្នាអំពីបញ្ហានានាក្នុងឃុំ ។

ការតវ៉ាពីសមត្ថភាពមិនស្មើគ្នានៃគណបក្សនយោបាយផ្សេងៗក្នុងការផ្ដល់ពត៌មាន ជួយទ្រទ្រង់ និងកេណ្ឌអ្នកគាំទ្រទៅបោះឆ្នោត បានតានតឹងខ្លាំងក្លាយជាទំនាស់ធ្ងន់ធ្ងរនៅក្រោយថ្ងៃបោះឆ្នោត ។ សមាជិកក្រុមប្រឹក្សាឃុំដែលមិនសូវមានបទពិសោធន៍ ជាពិសេសអ្នកមកពីគណបក្សថ្មីៗ ត្រូវការជំនួយទ្រទ្រង់ដើម្បីក្លាយជា អ្នកដឹកនាំនៅមូលដ្ឋានដែលត្រូវជួយផ្ដល់ពត៌មាន និងកៀងគរពួកអ្នកភូមិ ទោះបីមានការខ្វះខាតធនធានក្ដី, ហើយអង្គការឯទៀតៗ ក៏គួរទទួលបានការលើកទឹកចិត្តឱ្យចូលរួមក្នុងការងារនេះដែរ ។ គជប ត្រូវដោះស្រាយបញ្ហាកាន់ជើងគណបក្សនៅក្នុងលំហូរពត៌មានទៅកាន់ពួកអ្នកភូមិតាមរយៈការពង្រីកកម្មវិធីអប់រំអ្នកបោះឆ្នោតរបស់ខ្លួន ។

**សេចក្ដីសន្និដ្ឋានៈ កំណែទំរង់ស្ថាប័ន និងការបោះឆ្នោតឆ្នាំ២០០៣** ធៀបនឹងឆ្នាំ១៩៩៨ ការសិក្សាបានរកឃើញថា ទិដ្ឋភាពដូចខាងក្រោមខាងស្ថាប័នបានកែលំអឡើង ហើយបានពង្រឹងអារម្មណ៍ផ្សារភ្ជាប់រវាងតួអង្គខាងនយោបាយ និងខាងស្ថាប័ន និងកាត់បន្ថយការមិនទុកចិត្តគ្នារវាងគណបក្សនយោបាយនានាៈ

១. ការចូលរួមកាន់តែធំទូលាយក្នុងការតាក់តែង និងអនុម័តបទប្បញ្ញត្តិ និងច្បាប់បោះឆ្នោត ដែលបានបង្កើនយ៉ាងខ្លាំងនូវភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយនៃក្របខ័ណ្ឌច្បាប់ ហើយតាមនេះបានជួយពង្រឹងដល់ភាពពេញលក្ខណៈច្បាប់នៃស្ថាប័ន និងដំណើរការនានា

២. សេចក្ដីថែងកាន់តែលំអិតក្នុងបទប្បញ្ញត្តិនិងច្បាប់បោះឆ្នោត បានបង្កើនយ៉ាងខ្លាំងនូវតំលាភាពក្នុងការធ្វើសេចក្ដីសំរេចផ្សេងៗ ព្រមទាំងកាត់បន្ថយសកម្មភាពតាមទំនើងចិត្តរបស់ស្ថាប័ននានាដែលបង្កការមិនទុក

តទៅទំព័រទី ១៣

# ប្រហុក និងសន្តិសុខស្បៀងៈ ការវាយតំលៃនៅតាមដាយត្រី

*លោក Bruce McKenney និងព្រុំ តុលា អ្នកស្រាវជ្រាវ វិបសអ បានពិនិត្យអំពីសារៈសំខាន់នៃប្រហុក ដែលជាប្រភពប្រូតេអ៊ីនក្នុងសន្តិសុខស្បៀងរបស់អ្នកក្រីក្រនៅកម្ពុជា ។*

ប្រហុកត្រូវបានចាត់ជាអាហារមូលដ្ឋានសំខាន់បំផុត សំរាប់ប្រជាជនកម្ពុជានៅជនបទ បន្ទាប់ពីស្រូវអង្ករ ។ ប្រហុកដែលធ្វើពីត្រីតូចថោកៗ និងអាចបរិភោគឆៅ ឬឆ្អិន ឬបង់ក្នុងសម្ល គឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់នៅក្នុងរបបហូបចុករបស់ប្រជាជនកម្ពុជា។ ម្យ៉ាងទៀត ដោយសារវាជាអាហារផ្អាប់ទុក គេអាចស្តុកទុកបានជាច្រើនខែដោយមិនខូចគុណភាព ។ ដូច្នេះវាជាប្រភពប្រូតេអ៊ីនដែលគេទុកចិត្តបានថា អាចមានពេញៗមួយឆ្នាំ (និងធ្វើរួចជាស្រេច) ទោះបីផុតរដូវសំបូរត្រីហើយក្តី ។ ទោះបីប្រហុកមានតួនាទីសំខាន់នៅក្នុងសន្តិសុខស្បៀងបែបនេះក្តី ក៏ការសិក្សាស្រាវជ្រាវក្នុងប្រធានបទនេះ មានតិចតួចបំផុត (ជាពិសេសបើធៀបនឹងស្រូវអង្ករ)។ ក្នុងនេះបញ្ហាសំខាន់ៗមួយចំនួនគឺៈ ការស្វែងយល់ឱ្យបានកាន់តែច្រើនពីបែបបទដែលប្រហុកមានចំណែកនៅក្នុងយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតនៅជនបទ, ការវាយតំលៃពីនិន្នាការនៃការធ្វើពាណិជ្ជកម្មប្រហុក, និងការរកមើលពីការគំរាមកំហែងក្នុងពេលបច្ចុប្បន្ន និងទៅអនាគតចំពោះការផ្គត់ផ្គង់ និងលទ្ធភាពមានប្រហុកតំលៃថោកសមរម្យ ។

ដើម្បីពិនិត្យពីបញ្ហានេះ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាននៃវិបសអ បានធ្វើការស្រាវជ្រាវនៅតាមដាយត្រី[១] នៅកំពង់លួងក្នុងខេត្តកំពង់ឆ្នាំង កាលពីខែមករា-មីនា ២០០៣ ។ ជារៀងរាល់ឆ្នាំ ក្នុងរដូវត្រីចុះ, ដាយត្រី នៅតាមដងទន្លេសាប (៥-៣០គ.ម ខាងជើងក្រុងភ្នំពេញ) ចាប់ត្រីបានប្រហែល ១៥.០០០តោន ដែលភាគច្រើនជាត្រីរៀល ត្រីស្លឹកឫស្សី ឬត្រីផ្សេងទៀតសំរាប់ធ្វើប្រហុក ។ កសិករជាច្រើនពាន់នាក់ធ្វើដំណើរមកដាយត្រី ជាពិសេសក្នុងខែមករា ដើម្បីទិញត្រីធ្វើប្រហុកសំរាប់ហូបប្រចាំឆ្នាំ ។ វិបសអ បានធ្វើអង្កេតលើអ្នកធ្វើប្រហុកតាមគ្រួសារ ៥៥នាក់នៅកន្លែងដាយ និងបានធ្វើសំភាសន៍អ្នកផ្តល់ពត៌មានគន្លឹះៗជាច្រើននាក់ទៀត ដែលជាប់ពាក់ព័ន្ធនឹងផលិតកម្ម និងពាណិជ្ជកម្មប្រហុក ដូចជា អ្នកធ្វើប្រហុកជាលក្ខណៈពាណិជ្ជកម្ម អ្នកធ្វើទឹកត្រីជាលក្ខណៈពាណិជ្ជកម្ម និងអ្នកដឹកជញ្ជូនតាមទូក និងតាមរថយន្ត ។ ដោយការស្រាវជ្រាវមានទ្រង់ទ្រាយតូច ការសិក្សាមានគោលដៅដ៏សាមញ្ញ ដើម្បីផ្តល់ការវាយតំលៃជាដំបូងមួយពីបញ្ហាសំខាន់ៗមួយចំនួន និងគូសរំលេចនូវចំណុចផ្សេងៗដែលគួរមានអន្តរាគមន៍ខាងគោលនយោបាយ និង/ឬការស្រាវជ្រាវស៊ីជំរៅថែមទៀតទៅអនាគត ។

## កសិករនៅកន្លែងដាយ

អ្នកធ្វើប្រហុកទាំង ៥៥នាក់ដែលត្រូវបានធ្វើអង្កេតនៅកន្លែងដាយសំរាប់ការសិក្សានេះ បានសំគាល់ខ្លួនឯងថាជាកសិករ ។ ជាមធ្យមពួកគេមានដីស្រែ ១ហិកតា និងផលិតស្រូវបាន ១តោន/ឆ្នាំ សំរាប់ក្រុមគ្រួសារមានគ្នា ៦នាក់ ។ ពួកគេភាគច្រើនមកពីបណ្តាខេត្តជិតៗគឺ កណ្តាល កំពង់ស្ពឺ និង កំពង់ឆ្នាំង ប៉ុន្តែ អ្នកខ្លះធ្វើដំណើរមកតាំងពីខេត្តព្រៃវែង និងស្វាយរៀង ដែលនៅឆ្ងាយ ។ ដំណើរប្រចាំឆ្នាំមកធ្វើប្រហុកនៅកន្លែងដាយ គឺជាប្រពៃណីយូរមកហើយ ហើយភាគច្រើនបានមកជារៀងរាល់ឆ្នាំ អស់ជាង ១០ឆ្នាំហើយ ។

តាមធម្មតា សមាជិក ២ ឬ ៣នាក់ក្នុងគ្រួសារនិមួយៗ ធ្វើដំណើរមកកន្លែងដាយត្រី ក្រោយពេលប្រមូលផលស្រូវបានរួចរាល់ ។ អ្នកមកពីខេត្តជិតៗច្រើនស្នាក់នៅ ២-៣ថ្ងៃ, ប៉ុន្តែអ្នកមកពីព្រៃវែង ស្វាយរៀង ច្រើនស្នាក់នៅយូរជាង ដើម្បីប្រឹងប្រែងរកចំណូលដោយលក់ពលកម្មនៅកន្លែងដាយ ។ កាលពីដើម កសិករធ្វើដំណើរតាមរទេះគោមកកន្លែងដាយ និងយកស្រូវអង្ករដូរយកត្រី ប៉ុន្តែបច្ចុប្បន្នពួកគេច្រើនធ្វើដំណើរជាក្រុមតាមរថយន្តធំ និងទិញត្រីដោយក្រដាសប្រាក់តែម្តង ។ មានកសិករតែ ២០%ទេដែលរាយការណ៍ថាទិញត្រីដោយយកស្រូវអង្ករមកដូរទាំងអស់ និងមាន ២០% ទៀតរាយការណ៍ថាទិញត្រីជាប្រាក់ផង និងដូរជាស្រូវអង្ករផង ។

សន្តិសុខស្បៀងនៅតែជាមូលហេតុចំបងដែលកសិករធ្វើដំណើរមកដាយ ក្នុងនេះមានប្រហែល១ភាគ៣ រាយការណ៍ថា ពួកគេគ្រោងលក់ប្រហុកខ្លះ ប៉ុន្តែមិនច្រើនទេ (ប្រហែល ៥០គ.ក ជាមធ្យម) ។ ដូចមានបង្ហាញក្នុងតារាង១ កសិករ ៨០-៩០% បញ្ជាក់ថា ពួកគេមកកន្លែងដាយ ពីព្រោះនៅឯភូមិខ្វះត្រីធ្វើប្រហុក ហើយពួកគេចង់ធ្វើយ៉ាងណាឱ្យមានប្រហុកសំរាប់ហូបក្នុងគ្រួសារបានពេញមួយឆ្នាំ ។ កសិករប្រហែលពាក់កណ្តាលប្រាប់ថា ពួកគេមកធ្វើប្រហុកខ្លួនឯង ព្រោះអស់សោហ៊ុយតិចជាងការទិញប្រហុកពីឈ្មួញនៅក្នុងភូមិ ។ ទោះបីកសិករប្រហែល ៤០% និយាយថា ពួកគេបានសប្បាយរីករាយ ដោយសារប្រពៃណីមកកន្លែងដាយត្រីជារៀងរាល់ឆ្នាំ ប៉ុន្តែរឿងនេះមិនមែនជាកត្តាចំបងនៃការសំរេចចិត្តធ្វើដំណើររបស់ពួកគេទេ ។

### *ការធ្វើប្រហុក និងការបរិភោគ*

ការធ្វើប្រហុកមានច្រើនដំណាក់កាល ។ ទី១ កសិករទិញត្រីស្រស់ពីឈ្មួញ (អ្នកទទួលត្រីពីដាយដែលធ្វើប្រតិបត្តិការនៅក្នុងទន្លេ ដើម្បីយកមកលក់នៅច្រាំងទន្លេ) ។ ក្រោយទិញបានហើយ កសិករកាត់ក្បាលត្រី រួចដាក់វាក្នុងកញ្ជើឫស្សី ។ កសិករយកកញ្ជើត្រីនេះទៅទន្លេ ដើម្បីជាន់វា និងជ្រមុជជ្រាវលាងវាយកខ្លាញ់ និងគ្រឿងក្នុងពោះចេញ ។ ការចោលក្បាល ខ្លាញ់ និងអ្វីៗផ្សេងទៀត ធ្វើឱ្យត្រីបាត់ទំងន់ប្រហែលពាក់កណ្តាល (ឧ. ១០០គ.កត្រីស្រស់ ក្លាយជា ៥០គ.ក ត្រីកែច្នៃសំរាប់ធ្វើប្រហុក) ។ ដំណាក់កាលចុងក្រោយគឺយកត្រីកែច្នៃប្រឡាក់អំបិល និងញាត់ក្នុងពាងទុកប្រហែលមួយខែឱ្យវាកាច់ ទើបបរិភោគបាន ។ ជាមធ្យម អំបិលតំណាងឱ្យប្រហែល ៣០% នៃទំងន់ប្រហុក (ឧ. ៥០គ.ក ត្រីកែច្នៃក្លាយជា ៦៥គ.ក ប្រហុកក្រោយប្រឡាក់អំបិលហើយ) ។ បុរសនិងស្ត្រីពាក់ព័ន្ធទាំងអស់គ្នាក្នុងការធ្វើប្រហុក ប៉ុន្តែស្ត្រីដើរតួនាទីចំបងជាង ។ តាមធម្មតា ស្ត្រី (ជួនកាលមានកូនជួយផង) ជាអ្នកធ្វើសកម្មភាពកែច្នៃត្រី ចំណែកបុរសដើរតួនាទីចំបងក្នុងការផ្ទុកត្រី និងយកត្រីចុះឡើងពីច្រាំងទន្លេ ។

**តារាង១ៈ ហេតុអ្វីកសិករធ្វើដំណើរមកដាយត្រី**

| កត្តានាំឱ្យមានសេចក្តីសំរេចធ្វើដំណើរមកដាយត្រី | % អ្នកឆ្លើយសំភាសន៍ * |
|---|---|
| មានត្រីប្រហុកច្រើននៅទីនេះ ខ្វះត្រីធ្វើប្រហុកក្នុងភូមិខ្ញុំ | 89 |
| ដើម្បីឱ្យក្រុមគ្រួសារខ្ញុំមានប្រហុកហូបពេញមួយឆ្នាំ | 82 |
| ប្រហុកមានតំលៃថោកជាងបើធៀបនឹងថ្លៃទិញពីឈ្មួញក្នុងភូមិ | 55 |
| រីករាយនឹងឱកាសល្អប្រចាំឆ្នាំខាងសង្គមកិច្ច និងវប្បធម៌ | 38 |
| គ្រោងលក់ប្រហុកខ្លះ – ការបង្កើតប្រាក់ចំណូល | 33 |

** ផ្អែកលើអង្កេតកសិករ ៥៥នាក់ៈ ធ្វើឱ្យមានចម្លើយច្រើនយ៉ាង*

មានការសាកសួរកសិករនៅដាយត្រីពីការបរិភោគប្រហុកក្នុងឆ្នាំ២០០២ និងចំនួនប្រហុកដែលពួកគេផលិតក្នុងឆ្នាំ២០០៣ ។ ទាំងអស់គ្នាធ្វើប្រហុកឱ្យបានគ្រប់គ្រាន់សំរាប់ហូបពេញមួយឆ្នាំ ។ ជាការកំរណាស់ដែលពួកគេត្រូវទិញប្រហុកបន្ថែមនៅក្នុងឆ្នាំ (ប៉ុន្តែកសិករអាចមានហូបត្រី និងធនធានជលផលផ្សេងទៀតដែលចាប់បានក្នុងស្រែ) ។ ជាមធ្យមក្នុងឆ្នាំ២០០២ មួយគ្រួសារហូបប្រហុកអស់ ៦២គ.ក (ឬ ១០,១គ.ក/នាក់) ។ ដូចមានបង្ហាញក្នុងក្រាហ្វិក១ ការហូបប្រហុកសឹងតែថេរក្នុងពេញមួយឆ្នាំ លើកលែងតែនៅរដូវដកស្ទូង និងច្រូតកាត់ដែលការហូបឡើងខ្ពស់បំផុត ពីព្រោះកសិកររវល់ខ្លាំងណាស់ក្នុងរយៈពេលនេះ ហើយប្រហុកគឺជា "អាហាររហ័ស" មានតំលៃថោក ។ ប្រហុកស្រួលយកធ្វើម្ហូបក្នុងពេលកសិករប្រវាស់ដៃគ្នា (ម្ចាស់ស្រែត្រូវដកស្ទូង ឬច្រូតកាត់ ទទួលបន្ទុកដោះស្រាយបាយទឹក) ។ ក្នុងឆ្នាំ២០០៣ កសិករធ្វើប្រហុកជាមធ្យម ៩៥គ.ក សំរាប់ប្រើប្រាស់ក្នុងគ្រួសារ (ឬ ១៥,៧គ.ក/នាក់) គឺច្រើនជាងបរិមាណហូបក្នុងឆ្នាំ២០០២ ។ ដូច្នេះវាអាចជាតួលេខប៉ាន់ស្មានខ្ពស់បំផុតនៃតំរូវការប្រើប្រាស់សំរាប់មួយឆ្នាំ ពីព្រោះកសិករខ្លះប្រហែលត្រូវការលក់ប្រហុកមួយចំនួននៅក្នុងឆ្នាំ ប៉ុន្តែពេលនេះមិនទាន់មានគំរោងអ្វីទេ ។

ក្រាហ្វិក១. ការប្រើប្រាស់ប្រហុកប្រចាំឆ្នាំក្នុងគ្រួសារក្នុងឆ្នាំ២០០២




## តំលៃប្រហុក

ប្រហុកនៅតែជាម្ហូបអាហារតំលៃថោក និងជាប្រភពប្រូតេអ៊ីនដ៏សំខាន់ដដែល ។ នៅឆ្នាំ២០០៣ តំលៃជាមធ្យមសំរាប់កសិករធ្វើប្រហុកនៅដាយគឺ ៣៦០៛/គ.ក ប្រហុក (ឬ ០,០៩ដុល្លារ) ។ ទោះបីគិតបញ្ចូលបន្ទុកចំណាយផ្សេងទៀតរបស់កសិករដូចជា ការដឹកជញ្ជូនទៅមកដាយត្រីផងក្ដី ក៏ប្រហុកមានតំលៃត្រឹមតែ ៥១៥៛/គ.ក (ឬ ០,១៣ដុល្លារ) ប៉ុណ្ណោះ គឺថ្លៃជាងស្រូវ ១គ.កតែបន្តិច ឬថោកជាងថ្លៃអង្ករបន្តិច ។ សំរាប់កសិករកម្ពុជាភាគច្រើនប្រភពប្រូតេអ៊ីនផ្សេងទៀត ក្រៅពីប្រហុកមានថ្លៃខ្ពស់ហួសលទ្ធភាពរបស់ពួកគេ ។ ឧ. សាច់ជ្រូកជាប់ខ្លាញ់តាមធម្មតាថ្លៃ ៤០០០-៨០០០៛/គ.ក (១-២ដុល្លារ) ហើយមាន់ក៏ថ្លៃប្រហែលគ្នាដែរ ។ ដូច្នេះ ទាល់តែប្រហុកឡើងថ្លៃខ្លាំងណាស់ ទើបកសិករពិចារណាផ្លាស់ប្ដូរទៅរកប្រភពសាច់ផ្សេងទៀត ។ រឿងនេះកាន់តែពិតថែមទៀត បើផ្អែកតាមទស្សនៈជាទូទៅដែលថាកសិករចូលចិត្តរសជាតិប្រហុក ជាជាងសាច់ផ្សេងទៀត ។

តារាង២: បន្ទុកចំណាយរបស់កសិករអ្នកធ្វើប្រហុកនៅដាយត្រី

| *បន្ទុកចំណាយធ្វើប្រហុក* | 2003 | | 2002 | | 2001 | |
|---|---|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ | រៀល | ដុល្លារ |
| ថ្លៃត្រី (គ.ក)[ក] | 201 | | 155 | | 126 | $0.03 |
| ចំណាយទិញត្រី – ប្រហុក ៦៥គ.ក[ខ] | 20,100 | | 15,500 | | 12,600 | $3.19 |
| ថ្លៃអំបិល (គ.ក) | 218 | | 507 | | 521 | $0.13 |
| ចំណាយអំបិល -ប្រហុក ៦៥គ.ក | 3,270 | | 7,605 | | 7,815 | $1.98 |
| សរុបចំណាយលើប្រហុក[គ] | 23,370 | | 23,105 | | 20,415 | $5.17 |
| ចំណាយលើប្រហុក/គ.ក | 360 | | 355 | | 314 | $0.08 |
| ត្រីជាភាគរយនៃចំណាយលើប្រហុក | 86% | 67% | 62% | | | |

[ក] *កសិករច្រើនទិញត្រីស្លឹកឬស្សីមកធ្វើប្រហុកនៅឆ្នាំ២០០៣ ពីព្រោះដាយចាប់បានត្រីនេះភាគច្រើន ។ កាលពីឆ្នាំ ២០០១ និង ២០០២ ដាយចាប់បានត្រីរៀលភាគច្រើន ។ កសិករចូលចិត្តប្រើត្រីរៀលបើសិនអាចរកបាន ។*

[ខ] *ជាមធ្យមកសិករធ្វើប្រហុក ៦៥គ.ក/គ្រួសារក្នុងឆ្នាំ២០០៣ ។ ចំនួននេះត្រូវការត្រីស្រស់ ១០០គ.ក (ស្មើនឹង ៥០គ.កត្រីកែច្នៃ) និងអំបិល ១៥គ.ក ។*

[គ] *កសិករក៏ត្រូវចំណាយលើការដឹកជញ្ជូនទៅមកដាយត្រី ការស្នាក់នៅតាមមាត់ទន្លេមួយយប់ និងសំភារបរិក្ខារ ។ នៅឆ្នាំ២០០៣ ចំណាយទាំងអស់នេះគឺប្រហែល ១០.០០០រៀល/គ្រួសារ (ឬ ២,៥០ដុល្លារ) ។ នៅពេលបូក*

កំណើនតំលៃប្រហុក និងកង្វះប្រភពប្រូតេអ៊ីនផ្សេងទៀតដែលថោកគួរសមអាចឱ្យកសិកររកហូបបាន វាបង្ហាញពីលទ្ធភាពមានបញ្ហាចោទចំពោះសន្តិសុខស្បៀងក្នុងពេលខាងមុខ ។ នៅឯដាយត្រី ថ្លៃត្រីប្រហុកបានកើន ៦០% ពីឆ្នាំ២០០១ ដល់ ២០០៣ (តារាង២) ។ ទោះបីថ្លៃអំបិលដែលធ្លាក់ចុះយ៉ាងខ្លាំង បានជួយសំរាលផលប៉ះពាល់នៃការឡើងថ្លៃត្រីក្នុងឆ្នាំ២០០៣ ក្ដី ប៉ុន្តែវាប្រហែលមិនអាចធ្លាក់ចុះច្រើនយ៉ាងដូច្នេះទៀតបានទេ ។ ថ្លៃអំបិលគឺប្រហែល ៥០០៛/គ.ក ទាំងក្នុងឆ្នាំ២០០១ និង ២០០២ ប៉ុន្តែធ្លាក់ចុះដល់ ២២០៛/គ.ក ជាមធ្យមនៅឆ្នាំ២០០៣ ។ រឿងនេះប្រហែលផុសចេញពីអំបិលនាំចូលដ៏ថោក (ប្រហែលគ្មានដាក់ជាតិអ៊ីយ៉ូដទេ) មកពីវៀតណាមដែលមកប្រជែងថ្លៃជាមួយអំបិលមានដាក់អ៊ីយ៉ូដរបស់ផលិតករអំបិលនៅខេត្តកំពត[២] ។ កសិករបញ្ជាក់ទៀតថា ក្រោយពីបានឃើញអំបិលមានថ្លៃខ្ពស់នៅកន្លែងដាយកាលពីមុន ឥឡូវនេះជាច្រើននាក់បានយកអំបិលតំលៃថោកមកពីភូមិរបស់ខ្លួន ។

## ការផ្គត់ផ្គង់ត្រីកំពុងថយចុះ?

ផ្អែកតាមទិន្នន័យរបស់នាយកដ្ឋានជលផល បរិមាណត្រីចាប់បានតាមដាយត្រីមានស្ថិរភាពក្នុងទសវត្សរ៍កន្លងមក (ប្រហែលពី ១១.០០០ ទៅ ១៧.០០០តោន) ។ មានតែក្នុងឆ្នាំ ១៩៩៨-៩៩ទេ ដែលត្រីចាប់បានមានចំនួនតិចជាងនេះ គឺចុះទាបបន្តិចជាង ៩.០០០តោន (តារាង៣) ។ ប្រភេទត្រីចាប់បានសំរាប់ធ្វើប្រហុកជាទូទៅ វាដើរតាមបរិមាណត្រីចាប់បានសរុប ពីព្រោះវាតំណាងឱ្យប្រហែល ៤០-៦០% នៃត្រីចាប់បាន លើកលែងតែនៅឆ្នាំ២០០១-០២ និង ២០០២-០៣ ។ ក្នុងពីរឆ្នាំចុងក្រោយ អត្រាខាងលើចុះដល់ ២០-២៥% ។ ការធ្លាក់ចុះគួរឱ្យភ្ញាក់ផ្អើលនៃប្រភេទត្រីប្រហុក ហាក់ដូចជាកត្តាចំបងនៃការឡើងថ្លៃត្រីក្នុងរយៈពីរឆ្នាំចុងក្រោយ ។ ប៉ុន្តែរឿងនេះ ក៏អាចមិនមែនដូច្នេះដែរ ។ អ្នកជីវសាស្ត្រខាងត្រីបានផ្ដល់គំនិតថា ប្រហែលគ្មានការធ្លាក់ចុះលឿនបែបនេះក្នុងប្រភេទត្រីប្រហុកទេ ពីព្រោះវាជាប្រភេទត្រីតូចៗដែលបន្តកូនបានយ៉ាងលឿន និងច្រើនតែអាចប្រជែងរស់បានយ៉ាងល្អក្នុងតំបន់ធ្វើនេសាទខ្លាំង បើធៀបនឹងត្រីប្រភេទធំដែលមានវដ្តបន្តពូជវែងជាង ។ និន្នាការជាតួយ៉ាងក្នុងប្រភេទត្រីចាប់បាន គឺច្រើនតែត្រីប្រភេទធំថយចុះ និងត្រីប្រភេទតូចកើនឡើង ។

ដូច្នេះគេ ផ្ដល់គំនិតថា ពុំមានការធ្លាក់ចុះបរិមាណត្រីប្រហុកចាប់បាននោះទេ ប៉ុន្តែ មានចោទបញ្ហាក្នុងការប្រមូលទិន្នន័យ ។

តើការផ្គត់ផ្គង់ប្រភេទត្រីធ្វើប្រហុកបានថយចុះពិតមែនឬយ៉ាងណា គឺជាចំណុចត្រូវជជែកវែកញែកទៀត ប៉ុន្តែគ្មានអ្វីត្រូវសង្ស័យច្រើនទេដែលថា តំរូវការត្រីប្រភេទនេះដោយតួអង្គធ្វើពាណិជ្ជកម្ម និងអ្នកនាំចេញ កំពុងកើនឡើងនិងបានរួមចំណែកក្នុងកិរិតណាមួយធ្វើឱ្យត្រីឡើងថ្លៃ ។ ដូចមានបង្ហាញក្នុងក្រាហ្វិក២ អ្នកមានផលប្រយោជន៍ដែលប្រជែងគ្នាយកត្រីពីដាយ មានជាអាទិ៍ កសិករ អ្នកកែច្នៃជាលក្ខណៈពាណិជ្ជកម្ម អ្នកធ្វើទឹកត្រីជាលក្ខណៈពាណិជ្ជកម្ម អ្នកដឹកជញ្ជូនត្រីបំរើឱ្យទីផ្សារក្នុងស្រុក និងអ្នកនាំចេញត្រីទៅវៀតណាម ។ ម្ចាស់ដាយអាចលក់ត្រីដោយផ្ទាល់ទៅឱ្យទូកអ្នកនាំចេញ និងអ្នកធ្វើទឹកត្រី (ដែលមានទីតាំងនៅតាមដងទន្លេ) ឬលក់តាមរយៈឈ្មួញដែលទទួលត្រីយកទៅច្រាំងទន្លេដើម្បីលក់ទៅឱ្យកសិករ អ្នកដឹកជញ្ជូន និងអ្នកកែច្នៃជាលក្ខណៈពាណិជ្ជកម្ម ។ នៅពេលកាត់ក្បាល និងសំអាតខ្លាញ់ត្រីចេញអស់ហើយ អ្នកកែច្នៃត្រីជាលក្ខណៈពាណិជ្ជកម្ម លក់ត្រីទៅឱ្យអ្នកធ្វើប្រហុកជាលក្ខណៈពាណិជ្ជកម្ម និងអ្នកដឹកជញ្ជូន ។

សកម្មភាពពាណិជ្ជកម្មនៅកន្លែងដាយត្រី កើនឡើងគួរកត់សំគាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ឧទាហរណ៍ នៅដាយកំពង់លួង ចំនួនអ្នកកែច្នៃត្រីជាលក្ខណៈពាណិជ្ជកម្មដោយមានប្រើម៉ាស៊ីនកាត់ក្បាល និងជំរះខ្លាញ់ បានកើនយ៉ាងខ្លាំងពីត្រឹម ២-៣នាក់នៅពាក់កណ្ដាលទសវត្សរ៍១៩៩០ មកដល់ ៣០-៣៥នាក់នៅឆ្នាំ២០០៣ ។ ក្នុងពេលសំបូរត្រីបំផុត ម៉ាស៊ីនទាំងនេះអាច កែច្នៃត្រីបាន ៥-១៥តោន/ថ្ងៃ/គ្រឿង ។ ស្របតាមកំណើនសមត្ថភាព កែច្នៃត្រី អ្នកដឹកជញ្ជូនប្រាប់ថា ចំនួនរថយន្តដឹកត្រី (ទាំងត្រីកែច្នៃ និងមិន កែច្នៃ) ពីដាយទៅទីផ្សារក្នុងស្រុក កើនឡើងយ៉ាងទៀងទាត់ក្នុងពីរ-បីឆ្នាំ ចុងក្រោយ ។ អ្នកដឹកជញ្ជូនជាច្រើនដឹកត្រីទៅដល់ទីផ្សារតាមភូមិក្នុងខេត្តនានាដែលនៅជុំវិញកន្លែងដាយដោយផ្ទាល់តែម្ដង ដើម្បីលក់ទៅឱ្យកសិករ ។ ដោយសារការចែកចាយបានទៅដល់ទីផ្សារ និងអ្នកប្រើប្រាស់ថ្មីៗទៀត វាក៏មានឥទ្ធិពលពង្រីកតំរូវការត្រីសរុប ។ តំរូវការត្រីកាន់តែច្រើនសំរាប់ធ្វើផលិតផលផ្សេងៗទៀតក្រៅពីប្រហុក (សំខាន់គឺទឹកត្រី) ក៏អាចបង្កើនសំពាធផងដែរលើថ្លៃត្រី ប៉ុន្តែការសិក្សានេះមិនអាចកំណត់ពីនិន្នាការក្នុងវិស័យនេះបានទេ ។ ម្យ៉ាងទៀត តំរូវការនាំចេញត្រីហាក់ដូចកំពុងកើនឡើង ។ អ្នកផ្ដល់ពត៌មានសំខាន់ៗជាច្រើននាក់បានកត់សំគាល់ពីកំណើនទូកនាំចេញត្រីពីដាយទៅវៀតណាម ។ ទូកទាំងនេះដែលដឹកត្រីបាន ២០-៧០ តោន អាចមើលឃើញនៅឯកំពង់លួង ក្នុងរយៈពេលធ្វើការស្រាវជ្រាវ ប៉ុន្តែមិនអាចប៉ាន់ស្មានពី ចំនួនទូក ឬបរិមាណត្រីនាំចេញបានទេ ។

ក្រាហ្វិក២. ការលក់ត្រីតូចៗមានតំលៃថោក ចេញពីដាយត្រី




ទោះបីមានកំណើនសកម្មភាពពាណិជ្ជកម្ម និងការចែកចាយត្រីចេញពីដាយទៅតំបន់ជនបទនានាក្ដី ក៏កសិករប្រហែលបន្តធ្វើដំណើរប្រចាំឆ្នាំមកកាន់ដាយត្រីជាច្រើនឆ្នាំតទៅមុខទៀត ។ ទី១ កសិករកត់សំគាល់ថា ពួកគេមកដាយត្រី ក្រោយពេលច្រូតស្រូវរួច គឺពេលមិនសូវមានអ្វីធ្វើ ឬមានច្រកអ្វីផ្សេងដើម្បីប្រើប្រាស់ពេលវេលាឱ្យមានផលិតភាព ។ ទី២ ថ្វីបើការចែកចាយត្រីមានការកែលំអ ប៉ុន្តែកសិករជាច្រើនបញ្ជាក់ថា ពួកគេនឹងអាចធានាការផ្គត់ផ្គង់ប្រហុកប្រចាំឆ្នាំបានលុះត្រាតែធ្វើដំណើរមកដាយ ។ ម្យ៉ាងទៀត កសិករចង់ធ្វើប្រហុកដោយខ្លួនឯង ដើម្បីធានាគុណភាព ។ ពួកគេកត់សំគាល់ថា គុណភាពនិងរស់ជាតិប្រហុកពាណិជ្ជកម្មច្រើនតែអន់ ដោយសារប្រើអំបិលច្រើនហួស និងប្រើត្រីគុណភាពអន់ (ឧ. ការកាត់ក្បាល និងជំរះខ្លាញ់ធ្វើមិនបានល្អ) ។

## ការសន្និដ្ឋាន និងអនុសាសន៍

ទោះបីក្នុងពីរឆ្នាំកន្លងមក ត្រីប្រហុកបានឡើងថ្លៃគួរកត់សំគាល់ក្ដី ក៏គេមិនទាន់ឃើញមានវិបត្តិអ្វីទេក្នុងពេលបច្ចុប្បន្ន ។ ប៉ុន្តែបើនិន្នាការឡើងថ្លៃនេះត្រូវបន្តទៅមុខក្នុងរយៈពេលវែង ប្រជាជនកម្ពុជានៅជនបទនឹងត្រូវប្រឈមមុខនឹងប្រហុកថ្លៃខ្ពស់ ហើយគេហាក់ដូចមិនឃើញមានប្រភពប្រូតេអ៊ីនអ្វីផ្សេងដែលថោក និងមានប្រជាប្រិយភាពប្រហាក់ប្រហែលនឹងប្រហុកទេ ។ ពាណិជ្ជភាវូបនីយកម្មនៃសកម្មភាពនានានៅដាយត្រី អាចមានលក្ខណៈវិជ្ជមានសំរាប់សន្តិសុខស្បៀង (ជួយសំចៃប្រាក់កសិករ) បើសិនការកែច្នៃទ្រង់ទ្រាយធំធ្វើឱ្យតំលៃថយចុះ ការត្រួតពិនិត្យគុណភាពអាចកែលំអ

តារាង៣: បរិមាណត្រីប្រហុកចាប់បាន ធៀបនឹងបរិមាណត្រីចាប់បានសរុបនៅដាយ

| | ត្រីចាប់បាននៅតាមដាយត្រី (ជាតោន) គិតតាមឆ្នាំ[ក] | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ត្រីចាប់បាននៅដាយ | 1994-95 | 1995-96 | 1996-97 | 1997-98 | 1998-99 | 1999-00 | 2000-01 | 2001-02 | 2002-03 |
| ត្រីប្រហុក (សំរាប់តែខែមករា)[គ] | 8,396 | 2,881[ខ] | 5,741 | 4,044 | 2,349 | 5,344 | 3,291 | 1,712 | 1,887 |
| ត្រីប្រហុក (មួយរដូវ) | N/A | 9,041 | 8,534 | 5,880 | 4,183 | 5,799 | 7,095 | 2,906 | 3,189 |
| ត្រីចាប់បានសរុបនៅដាយ (រដូវ) | N/A | 14,429 | 16,835 | 14,605 | 8,894 | 11,438 | 14,974 | 14,332 | 12,427 |
| ភាគរយត្រីប្រហុកក្នុងត្រីចាប់បានសរុប (រដូវ) | N/A | 63% | 51% | 40% | 47% | 51% | 47% | 20% | 26% |

*[ក] ទិន្នន័យសំរាប់ឆ្នាំ និងរដូវ ឆ្លុះបញ្ចាំងបរិមាណចាប់បានក្នុងរយៈ ៦ខែ ពីតុលា ដល់ មីនា ។ ទិន្នន័យត្រីចាប់បានសំរាប់ឆ្នាំ១៩៩៤-៩៥ ផ្អែកលើការសិក្សាមួយរបស់នាយកដ្ឋានជលផល និងគណៈកម្មាធិការទន្លេមេគង្គ (Lieng et al. 1995) ។ សំរាប់ឆ្នាំឯទៀតៗទាំងអស់ គឺតាមតួលេខប៉ាន់ស្មានរបស់នាយកដ្ឋានជលផល (១៩៩៥-២០០៣)*

*[ខ] ទិន្នន័យទាំងនេះឆ្លុះបញ្ចាំងបរិមាណចាប់បាននៅខែធ្នូ និង មករា គួបគ្នា*

ឡើង ហើយច្រកចែកចាយអាចបានទៅដល់តំបន់ជនបទនានាដែលនៅជុំវិញ ឱ្យបានសព្វគ្រប់ល្អ ។ ក្នុងពេលបច្ចុប្បន្ន វាសុទ្ធសឹងជាបញ្ហាប្រឈមដ៏ធំៗ ពីព្រោះបន្ទុកចំណាយធ្វើប្រហុកពាណិជ្ជកម្ម វាប្រហាក់ប្រហែលគ្នានឹងបន្ទុកចំណាយរបស់កសិករ ឯការត្រួតពិនិត្យគុណភាពមានតិចតួចបំផុត ហើយកសិករជាច្រើនបញ្ជាក់ថា ពួកគេត្រូវតែមកកន្លែងដាយ ពីព្រោះនៅឯភូមិគ្មានត្រីធ្វើប្រហុកទេ ។

ដោយហេតុថាការសិក្សានេះជាការវាយតំលៃជាដំបូងមួយ ដូច្នេះអនុសាសន៍ផ្តោតលើវិស័យនានាដែលគួរមានការស្រាវជ្រាវ និងការយកចិត្តទុកដាក់ថែមទៀតក្នុងប៉ុន្មានឆ្នាំខាងមុខ គឺមានៈ

- **តាមដានថ្លៃត្រីប្រភេទផ្សេងៗដែលសំរាប់ធ្វើប្រហុក ជាពិសេសក្នុងរយៈពេលសំបូរត្រីបំផុតនៅខែមករា** ។ បើសិនថ្លៃត្រីបន្តកើនឡើង គួរមានការស្រាវជ្រាវច្រើនថែមទៀត ដើម្បីកំណត់ពីកំរិតនាំចេញ ពីព្រោះការនាំចេញកាត់បន្ថយការផ្គត់ផ្គង់ក្នុងស្រុក ដែលអាចធ្វើឱ្យថ្លៃត្រីក្នុងស្រុកកើនឡើង ។ ដូចគ្នាដែរ គួរមានការត្រួតពិនិត្យថែមទៀត អំពីវិធីសាស្ត្រប្រមូលទិន្នន័យក្នុងពីរ-បីឆ្នាំខាងមុខនេះ ដើម្បីធានាគុណភាពទិន្នន័យ និងជួយបំភ្លឺថាតើការថយចុះការផ្គត់ផ្គង់ត្រី វាអាចប៉ះពាល់កំរិតណាដល់ថ្លៃត្រី ។ ដោយសារសារៈសំខាន់នៃប្រហុកចំពោះសន្តិសុខស្បៀង ដូច្នេះត្រូវមានវិធានការធានាឱ្យបានលើគុណភាពនៃការតាមដាន និងប្រមូលទិន្នន័យ ។ ដូចគ្នានឹងការយកឱនភាពស្រូវអង្ករ មកតាមដានរកមើលតំបន់មានអសន្តិសុខស្បៀងដែរ គេគួរមានវិធានការដើម្បីរកមើលការគំរាមកំហែងផ្សេងៗចំពោះការផ្គត់ផ្គង់ និងតំលៃថោករបស់ប្រហុក ។
- **ធ្វើយ៉ាងណាឱ្យមានឧបសគ្គតិចបំផុតចំពោះពាណិជ្ជកម្ម និងការចែកចាយប្រហុក និងប្រភេទត្រីធ្វើប្រហុក (កែច្នៃ និងមិនទាន់កែច្នៃ)** ។ ក្នុងវិស័យផ្សេងទៀតដែលសកម្មភាពពាណិជ្ជកម្ម បានរីកលូតលាស់ល្អ គេឃើញមាននិន្នាការក្នុងចំណោមស្ថាប័នរដ្ឋាភិបាល និងមន្ត្រី/អាជ្ញាធរនានា ក្នុងការតំរូវឡើងនូវអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងប្រាក់កំរៃ (សូមអានឯកសារពិភាក្សារបស់ វបសអ លេខ២៧ និង ២៨ ស្តីពីការនាំចេញត្រី និងពាណិជ្ជកម្មជ័រទឹក) ។ ការតំរូវបែបនេះចំពោះពាណិជ្ជកម្មប្រហុក ទោះបីជាពាណិជ្ជកម្មផ្លូវការ ឬមិនផ្លូវការក្តី មិនត្រូវបង្កើតឡើង ឬអនុញ្ញាតសោះឡើយ ។ ដើម្បីធានាសន្តិសុខស្បៀងនៅប្រទេសកម្ពុជា ថ្លៃប្រហុកត្រូវនៅថោកជាចាំបាច់ ។ រឿងនេះទាមទារការរក្សាបន្ទុកចំណាយម៉ាឃីទីង និងចែកចាយឱ្យនៅទាប ។
- **សិក្សាស្រាវជ្រាវពីឱកាសល្អដើម្បីប្រយុទ្ធបញ្ហាកង្វះជាតិអ៊ីយ៉ូដ តាមរយៈការប្រើអំបិលមានដាក់អ៊ីយ៉ូដនៅក្នុងប្រហុក** ។ ប្រហុកគឺជាប្រភពអំបិលដ៏សំខាន់មួយដែលមានពេញៗមួយឆ្នាំសំរាប់ប្រជាជនកម្ពុជា ។ លទ្ធផលរកឃើញក្នុងការសិក្សានេះបង្ហាញថា កសិករ (និងសមាជិកគ្រួសាររបស់គេ) បរិភោគប្រហុកប្រហែល ១០-១៥គ.ក/ឆ្នាំ ។ ក្នុងចំនួននេះអំបិលមានប្រហែល ៣,០-៤,៥គ.ក ឬប្រហែល ៨-១២ក្រាម/ថ្ងៃជាមធ្យម ។ ជារឿយៗគេសន្មតថា ស្តង់ដាបរិភោគអំបិលក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀតគឺ ១០ក្រាម/ថ្ងៃ ហើយគេក៏ដឹងច្បាស់ថា អំបិលមានប្រើតិចទេក្នុងការចំអិនអាហារនៅជនបទកម្ពុជា ក្រៅពីអំបិលដែលមានដាក់នៅក្នុងប្រហុក ដូច្នេះគេអាចនិយាយយ៉ាងត្រឹមត្រូវថា មួយភាគធំនៃអំបិលហូបចូលនៅក្នុងតំបន់ជនបទ គឺបានមកពីប្រហុក ។ ដោយមូលហេតុនេះ ការប្រើអំបិលដាក់អ៊ីយ៉ូដធ្វើប្រហុក វាមានសារៈសំខាន់ខ្លាំងណាស់ បើសិនគេចង់កាត់បន្ថយបញ្ហាកង្វះជាតិអ៊ីយ៉ូដនៅកម្ពុជា ។ នៅកន្លែងដាយក្នុងរយៈពេលមួយសប្តាហ៍នៃខែមករា កសិករជាច្រើនពាន់នាក់ត្រូវធ្វើការសំរេចចិត្តថាតើត្រូវប្រើអំបិលអ្វី (សំរាប់បរិភោគពេញមួយឆ្នាំ) ។ ការធ្វើប្រហុកនៅកន្លែងដាយ គឺជាឱកាសល្អមួយសំរាប់លើកទឹកចិត្តដល់ការប្រើអំបិលមានដាក់អ៊ីយ៉ូដ និងបំផុសការយល់ដឹងពីអត្ថប្រយោជន៍របស់វាចំពោះសុខភាព ។ មានការប្រឹងប្រែងយ៉ាងច្រើនដែលផ្តោតលើការធានាឱ្យមានការដាក់ជាតិអ៊ីយ៉ូដនៅក្នុងអំបិលផលិតចេញ ប៉ុន្តែប្រទេសកម្ពុជាមានចំណុចល្អពិសេសលើសគេមួយ ពីព្រោះតាមការជំរុញឱ្យប្រើអំបិលមានជាតិអ៊ីយ៉ូដនៅក្នុងគ្រឿងបរិភោគដ៏មានប្រជាប្រិយភាពតែមួយមុខ (ប្រហុក) គេអាចទទួលលទ្ធផលជាវិជ្ជមានយ៉ាងធំទូលាយបាន ។

## ឯកសារយោង


1. Department of Fisheries (1995-2003), “Total Catch (Ton) by Species of Dai Fisheries in Kandal/Phnom Penh in the Open Season”, (Phnom Penh: Department of Fisheries)
2. Lieng, S., C. Yim, and N.P. Van Zalinge (1995), “Freshwater Fisheries of Cambodia, I: The Bagnet (Dai) Fishery in the Tonle Sap River, *Asian Fisheries Science* 8 (1995): 255-262


## កំណត់សំគាល់

១. ដាយគឺជាទូកអួសត្រីមួយដែលចងជាប់នៅមួយកន្លែងក្នុងទន្លេ សំរាប់ចាប់ត្រីដែលធ្វើបម្លាស់ទីចុះតាមទឹក ។

២. ជាតិអ៊ីយ៉ូដ បានដាក់បន្ថែមក្នុងអំបិលនៅកំពត ក្នុងប្រព័ន្ធគ្រប់គ្រងត្រួត ត្រាមួយដែលគេវាយការណ៍ថាមានលក្ខណៈផ្តាច់មុខ ។ គេគិតថា ការ ត្រួតត្រាផ្តាច់មុខនេះមានលក្ខណៈចាំបាច់ ដើម្បីធានាឱ្យមានការបរិភោគ អំបិលមានជាតិអ៊ីយ៉ូដនៅកម្ពុជា ។ ការដាក់ជាតិអ៊ីយ៉ូដក្នុងអំបិល អាច ជាមធ្យោបាយដ៏សក្តិសិទ្ធិមួយដើម្បីប្រយុទ្ធនឹងបញ្ហាសុខភាពផ្សេងៗ បង្កឡើងដោយកង្វះជាតិអ៊ីយ៉ូដ ។ បញ្ហាមានដូចជា ជំងឺពកក កង្វះស្មារតី ផ្តោតមូលល្អ ចលនារាងកាយមិនសូវរៀបរយ និងកំរិតបញ្ញាទាប ។

៣. ដោយបានដឹងពីកំណើនការនាំចេញប្រភេទត្រីសំរាប់ធ្វើប្រហុក នាយកដ្ឋានជលផលបានណែនាំពួកម្ចាស់ដាយ ឱ្យលក់តែត្រីដែលចាប់បាននៅ ពេលយប់ទៅឱ្យអ្នកនាំចេញ ហើយរឿងនេះហាក់ដូចជាជំហានទី១ ដែល អាចអនុវត្តបានជាក់ស្តែង។ កាលពីមុន ម្ចាស់ដាយភាគច្រើន មិនធ្វើ ប្រតិបត្តិការនៅពេលយប់ទេ ហើយត្រីវាចុះហួសអស់ទៅ ។ គេបិទដាយ នៅពេលយប់ ពីព្រោះការលក់ពេលយប់ដូចជាសំរាប់ធ្វើចំណីសត្វជាដើម មិនអាចផាត់ចំណាយពលកម្មបានទេ ហើយត្រីក៏មិនអាចស្តុកទុកសំរាប់លក់នៅថ្ងៃបន្ទាប់ដែរ ។ អ្នកនាំចេញសុខចិត្តបង់ថ្លៃខ្ពស់ជាងសំរាប់ត្រីចាប់នៅពេលយប់ ដូច្នេះមានដាយច្រើនជាងមុនបានធ្វើប្រតិបត្តិការ ពេលយប់ក្នុងឆ្នាំ២០០២-០៣ ។ ដោយសារត្រីវាចុះតាមទឹកហូរ ដូច្នេះ គេមិនដឹងច្បាស់ទេថា តើការចាប់ត្រីនៅពេលយប់ វាប៉ះពាល់ដល់បរិមាណត្រីចាប់បាននៅពេលថ្ងៃដែរឬយ៉ាងណា ។

# អ្នកភូមិភ្នងសំរបខ្លួនតាមការថយចុះធនធានធម្មជាតិ

**ការធ្វើអាជីវកម្មលើធនធានធម្មជាតិក្នុងទសវត្សរ៍កន្លងទៅ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះខេត្តមណ្ឌលគិរី ។ ក្នុងការសិក្សាមួយរបស់អង្គការស៊ីដសេកម្ពុជា លោក Jonh P. McAndrew, ម៉ម-សម្បត្តិ ហុង-គីមលី និង គី-ប៊ុនថៃ បានពិនិត្យពីឥទ្ធិពលនៃការថយចុះធនធានធម្មជាតិទៅលើជីវភាពអ្នកភូមិភ្នងក្នុងឃុំពីរ ។***

តាំងពីដើមទសវត្សរ៍១៩៩០ ការបើកចំហសេដ្ឋកិច្ចកម្ពុជា និងការប្រឹងប្រែងរកថវិកាសំរាប់ពង្រឹងមូលដ្ឋានខាងនយោបាយ និងយោធា មានផលប៉ះពាល់យ៉ាងច្រើនចំពោះខេត្តមណ្ឌលគិរីនៅភាគឦសាននៃប្រទេសកម្ពុជា ។ ការកាប់ឈើទាំងស្របច្បាប់ និងមិនស្របច្បាប់ និងការប្រមាញ់សត្វព្រៃដោយគ្មានច្បាប់គ្រប់គ្រង បានកាត់បន្ថយធនធានធម្មជាតិដ៏សំបូរនៅក្នុងខេត្ត ។ ម្យ៉ាងទៀតចំណាកស្រុកចូលយ៉ាងលឿន អាចធ្វើឱ្យការធ្លាក់ចុះនេះកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ។ ដោយធនធានធម្មជាតិកាន់តែមានកំរិត ប្រជាជនដើមត្រូវបង្ខំចិត្តសំរបខ្លួនតាម ដែលអាចប៉ះពាល់ដល់ការគង់វង្សនៃរបៀបរស់នៅរបស់ពួកគេតែម្តង ។ អត្ថបទនេះផ្តោតលើការផ្លាស់ប្តូរដែលកើតមានឡើងក្នុងឃុំភ្នងពីរនៅខេត្តមណ្ឌលគិរី (ឃុំដាក់ដាំ ក្នុងស្រុកអូររាំង និងឃុំស្រែព្រះ ក្នុងស្រុកកែវសីមា) និងដែលជាលទ្ធផលនៃកំណើនសកម្មភាពទីផ្សារ និងការថយចុះធនធានធម្មជាតិ ។

## វិធីស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់ទីកន្លែងសំរាប់ការសិក្សានេះ បានធ្វើជាច្រើនលើកពីខែវិច្ឆិកា ២០០២ ដល់មីនា ២០០៣ ។ មានប្រើវិធីស្រាវជ្រាវបីចំបងៗ: អង្កេតតាមគ្រួសារ, ការសំភាសន៍អ្នកផ្តល់ពត៌មានសំខាន់ៗ និងការវាយតំលៃជនបទមានការចូលរួម (PRAs) ។ ក្រុមស្រាវជ្រាវ រួមមាន បុគ្គលិកស៊ីដសេកម្ពុជា ៤នាក់ សមភាគីជាបុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ១នាក់, និងអ្នកសួរសំភាសន៍ជនជាតិភ្នង ៧នាក់, សរុបមកគឺមានបុរស ៨នាក់ និងស្ត្រី ៤នាក់, ប៉ុន្តែមិនមែនចុះធ្វើការទាំងអស់គ្នារាល់ៗលើកនោះទេ ។ បុគ្គលិកស៊ីដសេនៅខេត្តផ្សេងទៀត បានមកជួយធ្វើ PRAs នៅស្រែព្រះ ។ អង្កេតតាមគ្រួសារបានធ្វើនៅគ្រប់ភូមិក្នុងឃុំទាំងពីរ តាមរបៀបជ្រើសរើសគំរូតាងដោយចៃដន្យ ២៥% ។

## លទ្ធផលរកឃើញសំខាន់ៗ

### *ការថយចុះធនធានធម្មជាតិ*

ក្នុងការប្រឹងប្រែងកសាងជីវិតឡើងវិញនៅក្រោយរបបខ្មែរក្រហម និងនៅក្នុងការប្រែប្រួលផ្សេងៗបង្កឡើងដោយសេដ្ឋកិច្ចទីផ្សារ, ប្រជាជននៅឃុំដាក់ដាំ និងស្រែព្រះ បានជួបនឹងការធ្វើអាជីវកម្មទៅលើបរិស្ថានធម្មជាតិរបស់ខ្លួនយ៉ាងលឿន ដែលមានទាំងការកាប់ឈើស្របច្បាប់ និងមិនស្របច្បាប់ ការបរបាញ់ដោយគ្មានច្បាប់គ្រប់គ្រង, និងការនេសាទបំផ្លិចបំផ្លាញ ។ នៅឃុំដាក់ដាំ មានការកាប់ឈើខុសច្បាប់ជាទ្រង់ទ្រាយធំ ។ អ្នកភូមិ នៅចងចាំថា មានរថយន្តធុនធ្ងន់ទាំងខ្សែៗដឹកឈើហ៊ុបឆ្លងកាត់ឃុំ ចេញទៅវៀតណាម ។ អ្នកកាប់ឈើខុសច្បាប់ មានកាន់អាវុធ ហើយពេលខ្លះមានប៉ូលីសព្រំដែន និងកងទ័ពជូនដំណើរផង ។ នៅខែធ្នូ ១៩៩៩ យុទ្ធនាការកំចាត់ការកាប់ឈើខុសច្បាប់នៅមណ្ឌលគិរី បានបំផុសការយកចិត្តទុកដាក់ដល់បញ្ហាមួយដែលបានកើតមានពាសពេញខេត្តជាច្រើនឆ្នាំមកហើយ ប៉ុន្តែមិនបានកាត់បន្ថយវាទេ ។ តាមពិត ការបញ្ចូលក្នុងមុខតំណែងវិញនូវមន្ត្រីរាជការដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពខាងលើ បានធ្វើឱ្យអ្នកឯទៀតកាន់តែហ៊ានថែមទៀតក្នុងការបន្តសកម្មភាពកាប់ឈើខុសច្បាប់ ។

នៅស្រែព្រះ មន្ត្រីក្នុងកងយោធពលខេមរភូមិន្ទកម្ពុជា (RCAF) បានធ្វើការកាប់ឈើទ្រង់ទ្រាយធំប្រហែលពីឆ្នាំ១៩៩៣-៩៦ ។ នៅឆ្នាំ១៩៩៧-៩៨ ក្រុមហ៊ុន Samling ដែលមានសម្បទានលើឃុំស្រែព្រះទាំងអស់ ឬសឹងតែទាំងអស់ បានបង្កើនល្បឿនកាប់ឈើក្នុងឃុំ ហើយក្នុងប្រតិបត្តិការនេះបានកាប់យកដើមឈើផ្តល់ជ័រធំៗជាច្រើន ។ នៅពេលក្រុមហ៊ុន Samling បញ្ឈប់ប្រតិបត្តិការនៅឆ្នាំ១៩៩៩ ការបាត់បង់ដើមឈើផ្តល់ជ័រក្នុងឃុំស្រែព្រះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រាក់ចំណូលរបស់អ្នកមូលដ្ឋានភាគច្រើន ។ ការយកជ័រទឹក គឺជាប្រភពចំណូលធំបំផុតរបស់គ្រួសារភាគច្រើនក្នុងឃុំ ។ តួលេខប៉ាន់ស្មានមធ្យមនៃការបាត់បង់ដើមឈើផ្តល់ជ័រក្នុង ៦ភូមិនៅស្រែព្រះ គឺប្រហែល ៥០% ។

នៅដាក់ដាំ ទាហាន និងប៉ូលីសដែលឈរជើងនៅទីរួមខេត្តសែនមនោរម្យ មានកាំភ្លើង និងបានធ្វើប្រមាញ់ ដើម្បីរកម្ហូប និងប្រាក់ចំណូលបន្ថែម ។ អ្នកកាប់ឈើខុសច្បាប់ក៏បរបាញ់សត្វព្រៃដែរ ។ នៅស្រែព្រះ ការកាប់ឈើយ៉ាងខ្លាំងពីឆ្នាំ១៩៩៣-៩៨ បានបង្កការខូចខាតធ្ងន់ធ្ងរ ពិសេសដល់សត្វព្រៃ ។ RCAF និងអ្នកកាប់ឈើនៃក្រុមហ៊ុន Samling មានកាន់កាំភ្លើង ហើយបានធ្វើការបរបាញ់សត្វព្រៃមកធ្វើម្ហូប ។ កងទ័ព និងប៉ូលីសក៏បានចូលមកក្នុងឃុំជាក្រុម ដើម្បីបរបាញ់សត្វព្រៃធំៗ ។ នៅដាក់ដាំ និងស្រែព្រះ ធនធានត្រីក៏ទទួលការគំរាមកំហែងពីកងទ័ព និងប៉ូលីស ដែលបានចូលមកក្នុងឃុំដើម្បីឆក់យកត្រីដែរ ។

## យុទ្ធសាស្ត្ររកចិញ្ចឹមជីវិត

ក្នុងឃុំនិមួយៗ ការរកចិញ្ចឹមជីវិតក្នុងគ្រួសារធ្វើតាមរយៈសកម្មភាពផលិតកម្មច្រើនបែបយ៉ាង ។ គ្រួសារគំរូតាងសឹងតែទាំងអស់នៅដាក់ដាំ និងមួយភាគធំនៅស្រែព្រះ ប្រកបរបរធ្វើចំការ ឬកសិកម្មកាប់ព្រៃដុតដាំដំណាំ ។ ឃុំដាក់ដាំមានដីខ្ពស់ និងមានគ្រួសារតិចតួចទេដែលធ្វើស្រែមានភ្លឺទប់ទឹក ប៉ុន្តែឃុំស្រែព្រះមានដីទំនាបជាង ហើយជាងពាក់កណ្តាលនៃ គ្រួ-សារក្នុងឃុំនេះធ្វើស្រែមានភ្លឺទប់ទឹក ។ ក្នុងឃុំទាំងពីរមានចិញ្ចឹមជ្រូក និងមាន់យ៉ាងច្រើន ។ គួរកត់សំគាល់ថា គ្រួសារភាគច្រើនណាស់ក្នុងឃុំទាំងពីរតែងទៅរកម្ហូប និងផលិតផលផ្សេងទៀតពីព្រៃ ព្រមទាំងធ្វើការបរបាញ់ និងដាក់អន្ទាក់ ។ រឿងនេះបញ្ជាក់ពីសារៈសំខាន់នៃធនធានព្រៃឈើចំពោះជីវិតរស់នៅរបស់ប្រជាជនក្នុងមូលដ្ឋាន ។ ការនេសាទក៏មានជាទូទៅដូចគ្នាក្នុងឃុំទាំងពីរ ។ ជាការប្រៀបធៀបការផលិតនិងលក់ទំនិញ ឬការទិញនិងលក់ទំនិញ មិនសូវមានអ្នកភូមិធ្វើច្រើនទេក្នុងឃុំទាំងពីរ ។ ការងារស៊ីប្រាក់កំរៃឃើញមានច្រើនជាងនៅដាក់ដាំ បើធៀបនឹងស្រែព្រះ ប៉ុន្តែ វាមិនមែនជាយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតនាំមុខគេទេក្នុងឃុំទាំងពីរនេះ (សូមមើលតារាង១) ។

* របាយការណ៍ពេញលេញមានចំណងជើងថា *ការសំរបខ្លួនរបស់ប្រជាជនដើមតាមការថយចុះធនធានធម្មជាតិ: បទពិសោធន៍ក្នុងឃុំពីរនៅភាគឦសានកម្ពុជា* អាចរកបានជាភាសាខ្មែរ និងអង់គ្លេសពីអង្គការស៊ីដសេកម្ពុជា ។

ក្រាហ្វិក១. ចំណូលគ្រួសារគិតតាមប្រភព វិច្ឆិកា ២០០២-មករា ២០០៣




ការប្រៀបធៀបចំណូលគ្រួសារគិតតាមប្រភពសំរាប់ឃុំទាំងពីរ បានបង្ហាញពីលក្ខណៈស្រដៀងគ្នា និងខុសគ្នាក្នុងរចនាសម្ព័ន្ធនៃចំណូលគ្រួសារ ។ នៅដាក់ដាំ ចំនែកធំៗបំផុតក្នុងចំណូលគ្រួសារគំរូតាង គឺបានមកពីការបរបាញ់ ដាក់អន្ទាក់ និងធ្វើចំការ ។ ផ្ទុយទៅវិញនៅស្រែព្រះ ចំណែកធំៗបំផុតក្នុងចំណូលគ្រួសារគំរូតាង គឺបានមកពីការប្រមូលផលព្រៃឈើ (ជាពិសេសការដងជ័រទឹក) និងការធ្វើស្រែទប់ទឹក ។ ថ្វីបើមានការខុសប្លែកគ្នាបែបនេះ ប៉ុន្តែសារៈសំខាន់នៃព្រៃឈើ និងធនធានដីធ្លីចំពោះជីវភាពរបស់ប្រជាជនក្នុងឃុំទាំងពីរ នៅតែអាចមើលឃើញយ៉ាងច្បាស់ (សូមមើលក្រាហ្វិក១) ។

ភាពក្រីក្រក្នុងឃុំទាំងពីរក៏មានកំរិតខ្ពស់គួរកត់សំគាល់ដែរ ។ របាយការណ៍មួយផ្សព្វផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) និងកម្មវិធីស្បៀងអាហារពិភពលោក (WFP) នៅខែមីនា ២០០៣ បានបញ្ជាក់ថា បន្ទាត់ក្រីក្រសំរាប់តំបន់ជនបទនៅកម្ពុជា[៣] ត្រូវបានកំនត់ត្រឹម ១.០៣៦រៀល/នាក់/ថ្ងៃ ឬ ៣៧៨.១៤០៛/នាក់/ឆ្នាំ ។ នៅដាក់ដាំក្នុងចំណោម ៦៥គ្រួសារគំរូតាង មាន ៣៥គ្រួសារ ឬ ៥៤% ធ្លាក់ក្រោមបន្ទាត់ក្រីក្រនេះ ។ នៅស្រែព្រះ ក្នុងចំណោម ៧៤គ្រួសារគំរូតាង មាន ៤៧គ្រួសារ ឬ ៦៣% ធ្លាក់ក្រោមបន្ទាត់ក្រីក្រ ។ ភាពក្រីក្រនេះ វាខ្ពស់យ៉ាងខ្លាំងជាងកំរិត ៤០,១% សំរាប់គ្រួសារជនបទកម្ពុជាទាំងអស់ដែលក្រសួងផែនការ បានកំណត់ថា ស្ថិតក្រោមបន្ទាត់ក្រីក្រនៅក្នុងឆ្នាំ១៩៩៩[៤] ។

## ផលប៉ះពាល់

### *យុទ្ធសាស្ត្រលើកកំពស់ជីវភាពរស់នៅ*

ទោះបីមានការបំផ្លិចបំផ្លាញធនធានព្រៃឈើ ដោយសារការកាប់ឈើស្របច្បាប់ និងមិនស្របច្បាប់ និងការបរបាញ់គ្មានច្បាប់គ្រប់គ្រងក្តី ក៏ប្រជាជនដើមជាជនជាតិភាគតិចក្នុងឃុំដាក់ដាំ និងស្រែព្រះ នៅតែពឹងផ្អែកយ៉ាងច្រើនលើធនធានព្រៃឈើដើម្បីទ្រទ្រង់ជីវភាព ។ ការសំរបខ្លួនតាមការថយចុះធនធានធម្មជាតិ ធ្វើឡើងជាសំខាន់ តាមការខំរកចិញ្ចឹមជីវិតឱ្យរស់រាននៅលើធនធានតិចជាងមុន ដោយទាញយកផលកាន់តែខ្លាំងពីមូលដ្ឋានធនធានដែលរួមតូច ។ រឿងនេះនាំឱ្យមានការបរបាញ់កាន់តែមមាញឹកនៅដាក់ដាំ និងការយកជ័រពីដើមឈើមិនទាន់គ្រប់អាយុនៅស្រែព្រះ ។ ការបាត់បង់ចំណូលបានពីព្រៃឈើ វាជំរុញឱ្យមានការពឹងផ្អែកកាន់តែច្រើនថែមទៀតលើការដាំដំណាំ និងការចិញ្ចឹមសត្វ (ជ្រូកនិងមាន់) ។ ប៉ុន្តែការថយចុះដីជាតិដី និងការធ្លាក់ភ្លៀងមិនទៀងទាត់ដែលជាប់ទាក់ទិននឹងការបាត់បង់ព្រៃឈើ បានកាត់បន្ថយសក្តានុពលសំរាប់ការផលិតផលដំណាំ ។ រីឯតំរូវការទីផ្សារនូវផលដំណាំលក់យកប្រាក់ ដូចជា គ្រាប់ស្វាយចន្ទីជាដើម ក៏មានកំរិតទាបជាងការរំពឹងទុក ។ ក្នុងពេលជាមួយគ្នា កំណើនសកម្មភាពទីផ្សារក៏មិនបានប្រែក្លាយប្រជាជនមូលដ្ឋានឱ្យទៅជាសហគ្រិន ឬអ្នកជំនួញ ឬក៏ផ្តល់ការងារមានប្រាក់កំរៃសមរម្យ និងមានលក្ខណៈជាប់លាប់នោះដែរ ។

ដោយសារ យុទ្ធសាស្ត្រទ្រទ្រង់ជីវិតតាមគ្រួសារដែលត្រូវផ្តោតលើលទ្ធភាពខាងក្នុង និងកង្វះមធ្យោបាយផ្សេងដែលមានរយៈពេលខ្លីនិងអាចរស់រានបាន, ដូច្នេះលទ្ធភាពប្រើប្រាស់ និងការត្រួតត្រាគ្រប់គ្រងធនធានធម្មជាតិ នៅតែមានសារៈសំខាន់បំផុត ។ បើសកម្មភាពកាប់ឈើកើតមានឡើងវិញក្នុងឃុំទាំងពីរ វានឹងបំផ្លិចបំផ្លាញដល់សហគមន៍នៅមូលដ្ឋានខ្លាំងណាស់ ជា-ពិសេសគ្រួសារអ្នកដងជ័រនៅស្រែព្រះ ។ ដោយសារដើមឈើផ្តល់ជ័រស្ទើរតែទាំងអស់ គេកំពុងយកជ័រវាទៅហើយនៅឃុំស្រែព្រះ ដូច្នេះគ្រួសារអ្នកភូមិប្រហែលមិនអាចប៉ះប៉ូវការខូចខាតដោយសារការកាប់ឈើក្នុងពេលអនាគតតាមរយៈការពង្រីកសកម្មភាពទៅក្នុងកន្លែងថ្មីទៀតបានទេ ។ កំរិតប្រាក់ចំនូល និងសន្តិសុខស្បៀងដែលធ្លាក់ចុះស្រាប់ហើយ នឹងត្រូវថយចុះថែមទៀត ។ ដូច្នេះ ជាការមួយចាំបាច់បំផុតដែលរដ្ឋាភិបាល ដោយមានការគាំទ្រពីប្រជាពលរដ្ឋផង ត្រូវពង្រឹងការអនុវត្តច្បាប់ហាមឃាត់ការកាប់ឈើផ្តល់ជ័រ ។ ម្យ៉ាងទៀត ពាណិជ្ជកម្មជ័រទឹកត្រូវតែការពារឱ្យមានដំណើរការតទៅមុខទៀត ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងបទឧទ្ទេសនាមកាលពីខែឧសភា ២០០៣ បានប្រកាសយ៉ាងច្បាស់ថា "យើងត្រូវផ្តល់អាទិភាពទី១ ទៅឱ្យប្រជាជន... ខ្ញុំសូមផ្តល់អនុសាសន៍យ៉ាងច្បាស់ថា មិនត្រូវអនុញ្ញាតឱ្យកាប់ព្រៃដែលប្រជាជនដងយកជ័រនោះទេ"[៥] ។

ក្រៅពីការពង្រឹងច្បាប់ហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រ គេចាំបាច់ត្រូវពិចារណាឡើងវិញពីលទ្ធភាពអាចរស់រានបាននៃសម្បទានព្រៃឈើ[៦] ។ សម្បទានកាប់ឈើរបស់ក្រុមហ៊ុន Samling នៅភាគខាងត្បូងខេត្តមណ្ឌលគិរី គ្មានសកម្មភាពទេតាំងពីឆ្នាំ១៩៩៩ មក ។ ប៉ុន្តែ ក្រុមហ៊ុន Samling បានដាក់ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រមួយជូនរាជរដ្ឋាភិបាលហើយ ហើយបើសិនជាទទួលបានការអនុម័តយល់ព្រម ក្រុមហ៊ុនអាចចាប់ផ្តើមធ្វើប្រតិបត្តិការកាប់ឈើឡើងវិញ ។ អ្នកអភិរក្សមួយចំនួនបានទទួលស្គាល់ថា សម្បទានកាប់

**តារាង១. យុទ្ធសាស្ត្ររកចិញ្ចឹមជីវិតតាមគ្រួសារក្នុងឆ្នាំកន្លងមក, វិច្ឆិកា**

| | ដាក់ដាំ | ស្រែព្រះ |
|---|---|---|
| ការដាំដុះដោយកាប់ព្រៃដុត | 64 | 61 |
| ការធ្វើស្រែមានភ្លឺទប់ទឹក | 3 | 43 |
| ការចិញ្ចឹមជ្រូក | 59 | 54 |
| ការចិញ្ចឹមមាន់ | 63 | 68 |
| ការចិញ្ចឹមទា | 22 | 10 |
| ការរកឃ្មុំពីព្រៃ | 60 | 69 |
| ការរកផលិតផលផ្សេងទៀតពីព្រៃ | 57 | 71 |
| ការបរបាញ់ ឬដាក់អន្ទាក់ | 45 | 52 |
| ការនេសាទ | 60 | 69 |
| ការផលិតនិងលក់ទំនិញ | 28 | 23 |
| ការទិញនិងលក់ទំនិញ | 9 | 13 |
| ការងារស៊ីប្រាក់កំរៃ | 36 | 31 |
| | n = 65 សំរាប់ដាក់ដាំ | n = 74 សំរាប់ស្រែព្រះ |

** ទិន្នន័យប្រមូលបានក្នុងរយៈពេលនេះ*

ឈើមានចីរភាពនិងមានការគ្រប់គ្រងល្អ អាចជាជំរើសមួយប្រសើរជាងការកាប់ឈើខុសច្បាប់ដែលអាចកើតមានជាជំនួសវិញ[៧] ។ ក្នុងនេះបញ្ហាលេចធ្លោគឺតើ Sampling មានការប្ដេជ្ញាចិត្តក្នុងផលប្រយោជន៍អាជីវកម្ម ឬមានការលើកទឹកចិត្តខាងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងសម្បទានឱ្យមានចីរភាពឬទេ ។ ពិនិត្យតាមប្រវត្តិរបស់ក្រុមហ៊ុន រឿងនេះប្រហែលមិនអាចកើតមានទេ ។ ក្នុងនេះគេអាចរំកែញែកថា បើសិនមិនអាចកាប់យកដើមឈើផ្ដល់ជ័របាន ក្រុមហ៊ុនមិនអាចធ្វើអាជីវកម្មកាប់ឈើបានចំណេញទេ ។ រដ្ឋាភិបាលមិនគួរអនុម័តយល់ព្រមលើផែនការគ្រប់គ្រងយុទ្ធសាស្ត្ររបស់ Samling ទេ ពីព្រោះ ការចាប់ធ្វើប្រតិបត្តិការកាប់ឈើឡើងវិញនៅស្រែព្រះ និងឃុំផ្សេងៗទៀត នៅភាគខាងត្បូងខេត្តមណ្ឌលគិរី នឹងធ្វើឱ្យសហគមន៍មូលដ្ឋាននានាក្នុងតំបន់ព្រៃសម្បទាន កាន់តែងាយរងគ្រោះ និងចុះក្រីក្រថែមទៀត ។

ការលុបចោលកិច្ចសន្យាព្រៃសម្បទាន និងការកំចាត់ទាំងស្រុងនូវការកាប់ឈើខុសច្បាប់ គឺជាវិធានការមួយស្របគ្នាយ៉ាងច្បាស់ជាមួយនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥ របស់រដ្ឋាភិបាល ។ តាមការទទួលស្គាល់ថាភាពក្រីក្រ ធ្វើឱ្យខាតបង់សេដ្ឋកិច្ច មានលក្ខណៈអសីលធម៌ និងធ្វើឱ្យបែកបាក់សង្គម រដ្ឋាភិបាលបានកំណត់ថា ការកាត់បន្ថយភាពក្រីក្រ គឺជាគោលដៅអភិវឌ្ឍន៍ដ៏សំខាន់បំផុតរបស់ខ្លួន ពីព្រោះវានាំឱ្យកើនផលិតភាព ព្រមទាំងកាត់បន្ថយភាពងាយរងគ្រោះផង ។ នៅឃុំដាក់ដាំ និងស្រែព្រះ មានភាពក្រីក្រកំរិតខ្ពស់ ។ បើសិនរដ្ឋាភិបាលមានគោលនយោបាយជួយទ្រទ្រង់ដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងឃុំសិក្សាទាំងនេះ, រដ្ឋាភិបាលត្រូវតែទប់ស្កាត់ មិនមែនជំរុញ ឬអនុញ្ញាតពួកសម្បទានិក ឬអ្នកកាប់ឈើខុសច្បាប់ ឱ្យទាញយកផលពីធនធានព្រៃឈើដោយធ្វើឱ្យខូចប្រយោជន៍ដល់ប្រជាជនជនក្នុងមូលដ្ឋានទេ ។ ការកាត់បន្ថយភាពងាយរងគ្រោះរបស់គ្រួសារប្រជាជននៅដាក់ដាំ និងស្រែព្រះ តាមរយៈការផ្ដល់លទ្ធភាពឱ្យប្រើប្រាស់ និងត្រួតត្រាលើធនធានព្រៃឈើ គឺជាជំហានទី១ ដ៏ចាំបាច់ក្នុងការប្រយុទ្ធកំចាត់ភាពក្រីក្រ ។ ហើយការបង្កើនផលិតភាពកសិកម្មតាមរយៈការកែលំអបច្ចេកទេស និងការបង្កើនប្រាក់ចំណូលបានពីពាណិជ្ជកម្ម និងការងារស៊ីប្រាក់កំរៃ នឹងជួយបំពេញបន្ថែមបានមួយកំរិតទៀត ។

### *ការពង្រឹងការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ*

ក្នុងទសវត្សរ៍កន្លងទៅ ជនជាតិព្នងជាប្រជាជនដើមនៅឃុំដាក់ដាំ និងស្រែព្រះ បានទទួលរងគ្រោះពីការថយចុះធនធានធម្មជាតិយ៉ាងធ្ងន់ធ្ងរ ។ កំលាំងនៅពីក្រោយសកម្មភាពកាប់ឈើទាំងស្របច្បាប់ និងមិនស្របច្បាប់ និងការបរបាញ់គ្មានចាប់គ្រប់គ្រង គឺមានអំណាច និងមានការព្យាយាមខ្លាំងពេក ធ្វើឱ្យសំលេងរបស់ប្រជាជនដើមដែលរស់នៅឆ្ងាយពីសង្គមធំ ពុំអាចមានគេស្ដាប់ឮ ឬយកចិត្តទុកដាក់ទេនោះ ។ ស្ថានភាពអាចវិវត្តកាន់តែធ្ងន់ធ្ងរទៀតក្នុងសតវត្សរ៍ទី២១ ។ ការគ្រោងចាប់ផ្ដើមធ្វើប្រតិបត្តិការកាប់ឈើសម្បទានឡើងវិញ អាចធ្វើឱ្យធនធានព្រៃឈើនៅស្រែព្រះ កាន់តែខូចខាតធ្ងន់ធ្ងរថែមទៀត ។ ផ្លូវថ្មីដែលទើបធ្វើហើយទៅកាន់ទីរួមខេត្តសែនមនោរម្យ បានបើកឱកាសដល់ការជួញដីកេញយកចំណេញ និងការរំលោភកម្មសិទ្ធិដីធ្លីរបស់ប្រជាជនដើម ។ រឿងនេះ អាចធ្វើមានការដកហូតដីធ្លីថែមទៀតក៏ពិតមែន ប៉ុន្តែក៏អាចជួយផ្ដល់សិទ្ធិអំណាចឱ្យប្រជាជនដើមផងដែរ ។

មធ្យោបាយមួយដែលជួយឱ្យប្រជាជនដើម បានចូលពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានធម្មជាតិ គឺការបង្កើតសហគមន៍ព្រៃឈើ ។ នេះជាការខំប្រឹងប្រែងជួយទ្រទ្រង់ និងផ្ដល់សិទ្ធិអំណាចឱ្យសហគមន៍បន្តការប្រើប្រាស់ជាប្រពៃណីរបស់ខ្លួននូវធនធានព្រៃឈើ ដោយលើកទឹកចិត្តឱ្យមានការអនុវត្តន៍តាមរបៀបរបបមានចីរភាព ។ សហគមន៍ព្រៃឈើក៏មានគោលដៅជំរុញឱ្យប្រជាជនមូលដ្ឋានមានចំណេះដឹង និងមានជំនាញក្នុងការគ្រប់គ្រងព្រៃ ឈើ និងធានាឱ្យសហគមន៍មានសំលេងខ្លាំងឡើងនៅក្នុងសេចក្ដីសំរេចផ្សេងៗទាក់ទិននឹងវិស័យព្រៃឈើ ។ តាមធម្មតា សហគមន៍ព្រៃឈើមានសកម្មភាពក្នុងការធ្វើផែនទីការប្រើប្រាស់ដី, ការធ្វើផែនការ, និងការកសាងកិច្ចព្រមព្រៀងគ្រប់គ្រងព្រៃឈើស្ដីពីការប្រើប្រាស់ធនធាន ដែលមានការទទួលស្គាល់ពីពួកអ្នកភូមិ និងមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ។ ការសិក្សាមួយរបស់ វបសអ បានរកឃើញថា មានគំរោងសហគមន៍ព្រៃឈើចំនួន ២៣៧ នៅកម្ពុជាក្នុងនេះមាន ៧គំរោងស្ថិតនៅខេត្តមណ្ឌលគិរី[៨] ។ វិធីល្អមួយទៀតសំរាប់ជំនួសឱ្យការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិ ពីសំណាក់ក្រុមហ៊ុន ឬឯកជន គឺការផ្ដល់កម្មសិទ្ធិលើធនធានដីធ្លីដល់សហគមន៍ ។ ថ្មីៗនេះ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ បានប្រកាសប្រាប់ពីផែនការចេញលិខិតបញ្ជាក់កម្មសិទ្ធិដីសហគមន៍ ទៅឱ្យប្រជាជនដើមក្នុងគំរោងសាកល្បងមួយចំនួន ស្របតាមច្បាប់ដីធ្លីឆ្នាំ២០០១ ក្នុងនេះក៏មានភូមិមួយនៅខេត្តមណ្ឌលគិរីដែរ[៩] ។

នៅមណ្ឌលគិរី វិធីផ្សេងៗទៀតបានចាប់ផ្ដើមផុសឡើង ដោយសហគមន៍ប្រជាជនដើម បានចាប់យកសិទ្ធិអំណាច និងលើកកំពស់សិទ្ធិរបស់ខ្លួន ។ ក្នុង

**តារាង២. ចំណូលគ្រួសារជាមធ្យម គិតតាមតំលៃជាប្រាក់ និងតាមប្រភពកាលពីឆ្នាំមុន (វិច្ឆិកា ២០០២ ដល់ មករា ២០០៣*) (ជារៀល)****

| | ដាក់ដាំ | ស្រែព្រះ |
|---|---|---|
| ស្រូវចំការ | 193,292<br>10.3% | 87,986<br>4.2% |
| ដំណាំចំការ (ក្រៅពីស្រូវ) | 271,585<br>14.5% | 160,816<br>7.6% |
| ស្រូវស្រែ | 4,615<br>0.2% | 259,297<br>12.3% |
| ការចិញ្ចឹមជ្រូក | 242,308<br>12.9% | 211,149<br>10.0% |
| ការចិញ្ចឹមមាន់ | 65,077<br>3.5% | 58,784<br>2.8% |
| ការចិញ្ចឹមទា | 7,692<br>0.4% | 2,567<br>0.1% |
| អាហាររកបានពីព្រៃ | 46,769<br>2.5% | 42,239<br>2.0% |
| ផលិតផលផ្សេងរកបានពីព្រៃ | 252,376<br>13.5%<br>(34,415ជ័រទឹករាវ) | 870,799<br>41.2%<br>(600,845ជ័រទឹករាវ) |
| សត្វបរបាញ់ ឬដាក់អន្ទាក់បាន | 527,405<br>28.2% | 133,755<br>6.3% |
| ត្រីចាប់បាន | 32,412<br>1.7% | 51,342<br>2.4% |
| ការផលិត និងលក់ទំនិញ | 40,708<br>2.2% | 35,270<br>1.7% |
| ការទិញ និងលក់ទំនិញ | 26,069<br>1.4% | 67,635<br>3.2% |
| ការងារស៊ីប្រាក់កំរៃ | 161,323<br>8.6% | 132,486<br>6.3% |
| **សរុប** | **1,871,631<br>99.9%** | **2,114,125<br>100.1%** |
| | n = 65 | n = 74 |

**ទិន្នន័យប្រមូលបានក្នុងរយៈពេលនេះ ។ **៤.០០០រៀល ស្មើនឹង ១ដុល្លារអាមេរិក*

ប៉ុន្មានឆ្នាំថ្មីៗ ប្រជាជនដើមបានបង្កើនការយល់ដឹងពីច្បាប់និងបទប្បញ្ញត្តិខាងព្រៃឈើ, បានចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈ និងសកម្មភាពសហគមន៍ ទាក់ទិននឹងបញ្ហានានាដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ខ្លួន ។ម្យ៉ាងទៀតកំណែទំរង់វិមជ្ឈការក៏អនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំនិយាយបានព្ខ្លាំងជាងមុន ពីបញ្ហានានាដែលជាចំណុចព្រួយបារម្ភរបស់ប្រជាជនក្នុងឃុំខ្លួន ។ NGOs នានាខាងអភិរក្ស អភិវឌ្ឍន៍ និងសិទ្ធិមនុស្ស បានធ្វើការជាមួយគ្នា ជួយទ្រទ្រង់ដល់ដំណើរការផ្តល់សិទ្ធិអំណាច ។ ច្បាស់ហើយ គេត្រូវធ្វើការងារច្រើនណាស់ ដើម្បីរុញបញ្រ្ចាសទៅវិញនូវនិន្នាការក្រសោបយកផលក្នុងទសវត្សរ៍១៩៩០ ។ ប៉ុន្តែកិច្ចប្រឹងប្រែងរួមគ្នាមួយដើម្បីពង្រឹងការចូលរួមរបស់ប្រជាជនដើមក្នុងការគ្រប់គ្រងធនធានធម្មជាតិបានចាប់ផ្តើមហើយ ។

**កំណត់បញ្ជាក់:**


1. Global Witness, *Chainsaws Speak Louder Than Words*, May 2000, 19; Global Witness, *The Credibility Gap – and the Need to Bridge It: Increasing the Pace of Forestry Reform*, May 2001, 21-22.
2. តួលេខប៉ាន់ស្មាននេះ ខ្ពស់ជាងតួលេខក្នុងការសិក្សាថ្មីមួយធ្វើដោយ Wildlife Conservation Society ដែលបានកត់ត្រាការបាត់បង់ដើមឈើផ្តល់ជ័រ ២០% នៅភូមិមួយនៅស្រែព្រះ និង ២៦% ក្នុងភូមិមួយទៀត: See Tom D. Evans, Hout Piseth, Phet Phaktra, and Hang Mary, *A Study of Resin-Tapping and Livelihoods in Southern Mondulkiri, Cambodia, with Implications for Conservation and Forest Management*, (Phnom Penh: Wildlife Conservation Society, 2003), 40-41 ។
3. Ministry of Planning, Royal Government of Cambodia and the United Nations World Food Programme, *Poverty and Vulnerability Analysis Mapping in Cambodia: Mapping Poverty, Malnutrition, Educational Need, and Vulnerability to Natural Disasters in Cambodia*, March 2003.
4. Royal Government of Cambodia, National Poverty Reduction Strategy 2003-2005, 24.
5. "បទឧទ្ទេសនាមកិត្តិយសៈ រដ្ឋាភិបាលសេដ្ឋកិច្ច និងយុទ្ធសាស្ត្រលើកកំពស់ជីវភាពនៅជនបទ" ថ្លែងដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងសិក្ខាសាលាអភិវឌ្ឍន៍សំរាប់ថ្នាក់ដឹកនាំខេត្ត-ក្រុង រៀបចំដោយ វបសអ ដោយរួមសហការជាមួយក្រសួងមហាផ្ទៃនៅភ្នំពេញ កាលពីថ្ងៃទី១២-១៥ ឧសភា ២០០៣ ។
6. See Bruce McKenney, "Questioning Sustainable Concession Forestry in Cambodia," *Cambodia Development Review*, January – March 2002, 6,1.
7. J, Walston, P. Davidson, and Men Soriyun, *A Wildlife Survey in Southern Mondulkiri Province, Cambodia*, (Phnom Penh: Wildlife Conservation Society, 2001) cited in Evans et al, *A Study of Resin-Tapping and Livelihoods in Southern Mondulkiri*,19.
8. Bruce McKenney and Prom Tola, *Natural Resources and Rural Livelihoods in Cambodia: A Baseline Assessment*, Working Paper 23 (Phnom Penh: Cambodia Development Resource Institute, 2002), 86-89.
9. Michael Coren, "Landgrabs Loom for Mondolkiri Minorities," *Phnom Penh Post*, August 15-28, 2003, 7.


---

*តពីទំព័រទី ៥* **ការវិវត្តន៍នៃ ...**

ចិត្តពីសំណាក់គណបក្សនយោបាយផ្សេងៗ

៣. របៀបរបបធ្វើការរបស់ គជប នៅកំរិតជាតិ ជាពិសេសនៅមុនថ្ងៃបោះឆ្នោត និងការបង្កើនលទ្ធភាពឱ្យគណបក្សនយោបាយ និង NGOs បានជួបទាក់ទង គឺជាកត្តាដ៏សំខាន់ជួយពង្រឹងអារម្មណ៍ផ្សារភ្ជាប់រវាងតួអង្គនានាខាងនយោបាយ និងខាងស្ថាប័ន

៤. រឿងនេះបានកើតមានដូចគ្នា ប៉ុន្តែក្នុងកំរិតតូចជាងនៅថ្នាក់មូលដ្ឋានក្នុងឃុំនានាដែលបានចុះសិក្សា

៥. ការកកើតក្រុមប្រឹក្សាឃុំមានគណបក្សច្រើនចូលរួម បានជួយឱ្យ SRP មានវត្តមានច្រើននៅកំរិតមូលដ្ឋាន ដែលលើកទឹកចិត្តឱ្យគណបក្សនេះមានអារម្មណ៍ផ្សារភ្ជាប់ល្អទៅនឹងដំណើរការបោះឆ្នោត ។

ការសិក្សាបានរកឃើញថា ទិដ្ឋភាពខាងស្ថាប័នដូចខាងក្រោមបានធ្វើឱ្យខូចខាតដល់អារម្មណ៍ផ្សារភ្ជាប់រវាងតួអង្គខាងនយោបាយ និងខាងស្ថាប័ន បានបង្កើនការមិនទុកចិត្តគ្នា និងបានកាត់បន្ថយលទ្ធភាពគ្រប់គ្រងទំនាស់ឱ្យបានសក្តិសិទ្ធិ:

១. ភាពទន់ខ្សោយដែលមានជាបន្តនិងធ្ងន់ធ្ងរដដែល នៅក្នុងស្ថាប័ននានាក្រៅពី គជបៈ ឧទាហរណ៍ កង្វះទំនុកចិត្តចំពោះក្រសួងមហាផ្ទៃ ជាពិសេសពីសំណាក់គណបក្សប្រឆាំង, ភាពមិនពេញលក្ខណៈច្បាប់នៃពួកប្រធានភូមិដែលគ្មានការបោះឆ្នោតជ្រើសរើសសោះក្នុងរយៈ ២០ឆ្នាំ, សមាជិកក្រុមប្រឹក្សាឃុំខ្វះបទពិសោធន៍ ។ បញ្ហាចោទធំមួយ គឺតួអង្គខាងនយោបាយជាច្រើន នៅតែមានចំណាប់អារម្មណ៍ថា ស្ថាប័នរដ្ឋនានាដូចជា ប៉ូលីស និងតុលាការជាដើម ប្រើសិទ្ធិអំណាចដោយរំលោភ មានការលំអៀងខាងនយោបាយ និងពុករលួយ

២. គជប មានដែនសមត្ថកិច្ច និងសិទ្ធិអំណាចតិចតួចណាស់ក្នុងវិស័យខ្លះៈ ឧទាហរណ៍ ក្នុងការពាក់ព័ន្ធជាមួយ ប្រព័ន្ធផ្សព្វផ្សាយ និងពួកប្រធានភូមិ និងបណ្តាស្ថាប័ន ឬមន្ត្រីដែលរំលោភបំពានលើក្រមសីលធម៌បោះឆ្នោត ។ រឿងនេះកាន់តែធ្ងន់ធ្ងរឡើងដោយសារ គជប និង គឃប តែងមាននិន្នាការអនុវត្តយុទ្ធសាស្ត្រដោះស្រាយទំនាស់ដែលផ្តោតលើការសំរុះសំរួល ជាជាងលើការដាក់ទណ្ឌកម្ម

៣. កង្វះខាតជាបន្តនូវការត្រួតពិនិត្យលើ គជប ខ្លួនឯងតែម្តង ឧទាហរណ៍ តាមរយៈការបង្កើតអង្គភាពឯករាជ្យមួយសំរាប់ដាក់ស្នើឈ្មោះសមាជិក គជប និងអង្គភាពឯករាជ្យមួយទៀតសំរាប់ដោះស្រាយបណ្តឹងតវ៉ា

៤. កង្វះតំលាភាពក្នុងទិដ្ឋភាពដ៏សំខាន់ៗខ្លះនៃនីតិវិធីបោះឆ្នោត ឧទាហរណ៍

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

នៅត្រីមាសទី៣ ឆ្នាំ២០០៣ ការរំពឹងទុកពីការថយចុះហានិភ័យខាងភូមិសាស្ត្រ- នយោបាយ ដូចជានៅមជ្ឈឹមបូពាជាដើម បាននាំឱ្យមានកំណើនចំនាយអាជីវកម្ម/ចំនាយប្រើប្រាស់ និងជំរុញការលូតលាស់នៅក្នុងសេដ្ឋកិច្ចធំបង៧ ជាពិសេសសហរដ្ឋអាមេរិក (US) ។ ការផុតរលត់ជំងឺ SARS ក៏ជាកត្តាវិជ្ជមានមួយដែរសំរាប់តំបន់អាស៊ីខាងកើត ។

## កំណើនសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ច US មានកំនើនកាន់តែលឿននៅត្រីមាសទី៣ ឆ្នាំ២០០៣ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣,៣% ដែលជាកំរិតខ្ពស់បំផុតក្នុង ៧ត្រីមាសចុងក្រោយ ។ អ្នកប្រើប្រាស់ដែលបានធូរធារដោយសារ ការកាត់បន្ថយពន្ធ ៣៥០ពាន់លានដុល្លារដោយប្រធានាធិបតី George W. Bush និងអត្រាការប្រាក់ទាបអស្ចារ្យ បានចាយវាយយ៉ាងច្រើនក្នុងត្រីមាសទី៣នេះ និងបានជំរុញសេដ្ឋកិច្ចឱ្យមានកំណើនលឿនបំផុតក្នុងប៉ុន្មានខែចុងក្រោយ (ពត៌មាន Channel News Asia) ។ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួនពិត កើន ៦,៩% នៅត្រីមាសទី៣ ធៀបនឹងកំណើន ៣,៣% នៅត្រីមាសទី២, ចំណែកឯវិនិយោគជាប់លាប់ពិតសង់គេហដ្ឋាន ស្ទុះឡើង ២១,៩% ធៀបនឹងកំណើន ៤,៥% នៅត្រីមាសទី២(ពត៌មានពីការិយាល័យវិភាគសេដ្ឋកិច្ច) ។ ស្ថានភាពពាណិជ្ជកម្មអន្តរជាតិរបស់ US បានកែលំអ ដែលជួយឱ្យមានកំណើនកាន់តែលឿន ។ ការនាំចេញពិតនូវទំនិញនិងសេវា កើនលឿនជាងមុនតាមអត្រា ៩,៩% នៅត្រីមាសទី៣ ធៀបនឹងការធ្លាក់ចុះ ១,១% នៅត្រីមាសទី២ ។ ក្នុងពេលជាមួយគ្នា អត្រាកំណើននៃការនាំចូលពិតនូវទំនិញនិងសេវា ធ្លាក់ចុះយ៉ាងខ្លាំងពី ៩,១% មកត្រឹម ០,៨% ។

លទ្ធផលសេដ្ឋកិច្ចតំបន់អឺរ៉ូ នៅតែខ្សោយ ។ នៅត្រីមាសទី៣ ឆ្នាំ២០០៣ វាកើនឡើង ០,៣% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០២ ឬ ត្រឹម ០,១% លើសពីកំណើនក្នុងត្រីមាសមុន ។ រឿងនេះបណ្តាលជាសំខាន់ពីការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចនៅអាល្លឺម៉ង់ និងបារាំង ដែលមានចំណែកធំជាងគេក្នុងសេដ្ឋកិច្ចតំបន់អឺរ៉ូ ។ នៅខែកញ្ញា ២០០៣ ផលិតកម្មឧស្សាហកម្មអាល្លឺម៉ង់ធ្លាក់ចុះ ៣,៦% ធៀបនឹងខែដូចគ្នានៅឆ្នាំ២០០២ ។ ក្នុងពេលជាមួយគ្នា បរិមាណការលក់រាយថយចុះ ៣,១% ។ តាមទស្សនាវដ្តី The Economist អង្កេតថ្មីៗលើអាជីវកម្ម បានបង្ហាញកំណើនខ្ពស់ជាងក្នុងត្រីមាសទី៤ ២០០៣ ប៉ុន្តែរឿងនេះត្រូវជាប់ទាក់ទងជាសំខាន់នឹងកំលាំងប្រាក់អឺរ៉ូ ។

សេដ្ឋកិច្ចជប៉ុនកើន ១,៨% នៅត្រីមាសទី៣ ២០០៣ គឺយឺតជាងត្រីមាសទី២ ដែលមានអត្រាកំណើន ៣,០% ។ ការបញ្ជាទិញគ្រឿងម៉ាស៊ីនបានចុះខ្សោយ ហើយចំណាយប្រើប្រាស់ឯកជន និងវិនិយោគសាធារណៈក៏ធ្លាក់ចុះដែរ ជាពិសេសក្នុងចន្លោះពេលពីត្រីមាសទី២ ទៅត្រីមាសទី៣ ។ នៅខែកញ្ញា ២០០៣ បរិមាណការលក់រាយនៅជប៉ុន ធ្លាក់ចុះ ១,៨% ធៀបនឹងខែកញ្ញា ២០០២ ។ កំណើនសេដ្ឋកិច្ចជប៉ុន ១,៨% នៅត្រីមាសទី៣ ២០០៣ (ធៀបនឹងត្រីមាសទី៣ ២០០២) បណ្តាលឡើងដោយការកែលំអក្នុងផលិតកម្មឧស្សាហកម្ម (កំណើន ៤,១% នៅខែកញ្ញា ២០០៣), ការស្ទុះឡើងនៃវិនិយោគជាមូលធន (កំណើន ១៤,២%) និងកំណើនអតិរេកជញ្ជីងពាណិជ្ជកម្ម (៩៧,៧ពាន់លានដុល្លារនៅខែកញ្ញា ២០០៣) ។

នៅត្រីមាសទី៣ ២០០៣ អត្រាកំណើនប្រចាំឆ្នាំនៃ ផសស នៅចិនឡើងដល់ ៩,១% ក្រោយមានការថយល្បឿននៅត្រីមាសទី២ ដែលមានអត្រាកំនើនត្រឹម ៦,៧% ។ មូលហេតុចំបងនៃការរើបឡើងវិញនេះ គឺការរីកលូតលាស់ក្នុងវិស័យសេវាកម្មដែលមានអត្រាកំណើន ៧,៦%នៅត្រីមាសទី៣ ។ តាមការិ. ស្ថិតិជាតិចិន ចំនួលនៃកសិដ្ឋានក៏បានរើបវិញដែរ ដោយមានអត្រាកំនើន ៦,៥% នៅត្រីមាសទី៣ ទោះបីមានការធ្លាក់ចុះ ៣,៣% នៅត្រីមាសទី២ក្តី ។ រឿងនេះដោយសារកំណើនយ៉ាងច្រើននៃកសិករដែលបានទៅធ្វើការនៅតំបន់ទីក្រុង។

ផលិតកម្មសេដ្ឋកិច្ចនៅកូរ៉េខាងត្បូងកើន ២,៣% នៅត្រីមាសទី៣ ២០០៣ បើធៀបនឹងត្រីមាសទី៣ ២០០២ ។ កំណើនលឿននេះ គឺជំរុញឡើងជាសំខាន់ដោយសារមានការនាំចេញខ្លាំងជាងមុន ។ តាមធនាគារកណ្តាលកូរ៉េខាងត្បូង ការនាំចេញទំនិញនិងសេវា ស្ទុះឡើង ១០,៨%នៅត្រីមាសទី៣ ដោយសារមានការរើបសេដ្ឋកិច្ចជាសាកល, ចំណែកឯចំនាយប្រើប្រាស់ឯកជនក៏ចាប់ផ្តើមរើបឡើងដែរ ដោយមានអត្រាកំណើន ១,២% ។

នៅត្រីមាសទី៣ ២០០៣ សេដ្ឋកិច្ចថៃ កើនលឿនបន្តិចទៀតដល់ ៦,៥% ធៀបនឹងកំណើន ៥,៨% នៅត្រីមាសទី២ ។ តាមគណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច (NESDB) វិនិយោគឯកជន និងចំណាយប្រើប្រាស់ឯកជន គឺជាកត្តាជំរុញចំបងនៃកំណើននេះ ។ កំណើនចំណាយប្រើប្រាស់ឯកជនត្រូវបានជំរុញដោយអត្រាការប្រាក់ទាប, កំណើនទំនុកចិត្តរបស់អ្នកប្រើប្រាស់, និងការរីកលូតលាស់ចំណូលនៃកសិដ្ឋាន ។ កំណើនវិនិយោគ (១០,៨%) កើតមានឡើងជាសំខាន់ដោយកំនើនការប្រើប្រាស់សមត្ថភាពទាំងក្នុងវិស័យនាំចេញ និង វិស័យឧស្សាហកម្មក្នុងស្រុកផ្សេងៗ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ២០០៣ ថ្លៃទំនិញប្រើប្រាស់នៅ US កើនឡើងតាមអត្រាប្រចាំឆ្នាំ ២,២% ធៀបនឹង ២,១% នៅត្រីមាសទី២ ទោះបីសេដ្ឋកិច្ច US បានរឹងប៉ឹងឡើងក្តី ។ រឿងនេះកើតឡើងជាសំខាន់ដោយសារកំណើនថ្លៃថាមពល ៣,០% ពីខែសីហា ដល់ កញ្ញា ២០០៣ បើតាមពត៌មានពីក្រសួងការងារ US ។ នៅតំបន់អឺរ៉ូ អតិផរណាបន្តស្ថិតនៅជិតអត្រាគោលដៅ ២% ។ នៅប្រទេសជប៉ុន សំពាធបរិត្តផរណានៅមានជាបន្តដោយសារតំរូវការប្រើប្រាស់មានសន្ទុះខ្សោយ ក្នុងនេះថ្លៃទំនិញប្រើប្រាស់ថយចុះ ០,២%នៅត្រីមាសទី៣ ២០០៣ ក្រោយមានការថយចុះប្រហាក់ប្រហែលគ្នានៅត្រីមាសទី២ ។

ប្រាក់ដុល្លារនៅនឹងត្រឹម ០,៨៨អឺរ៉ូ/ដុល្លារ នៅត្រីមាសទី៣ ២០០៣ គឺដូចគ្នានឹងត្រីមាសទី២ ។ ក្នុងពេលនេះដែរ ដុល្លារចុះថ្លៃទល់នឹងប្រាក់យ៉េនដល់ ១១៧,៧យ៉េន/ដុល្លារ ធៀបនឹង ១១៩,១យ៉េន/ដុល្លារកាលពីត្រីមាសទី២ ២០០៣ ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ ដុល្លារចុះថ្លៃគួរកត់សំគាល់អស់ ១៣,៧% ទល់នឹងប្រាក់អឺរ៉ូ, និង ១,៦%ទល់នឹង ប្រាក់យ៉េន ។

## ថ្លៃផលិតផលក្នុងទីផ្សារពិភពលោក

នៅត្រីមាសទី៣ ២០០៣ ប្រេងឆៅឡើងថ្លៃ ៨,២% ដល់ ២៦,៥ដុល្លារ/ធុង គឺកើនពី ២៤,៥ដុល្លារ/ធុងនៅត្រីមាសទី២ ។ ធៀបនឹងត្រីមាសទី៣ ២០០២ ប្រេងឆៅឡើងថ្លៃ ៤,៣% ។ អង្ករលេខ១នៅទីផ្សារអន្តរជាតិក្រុងបាងកកឡើងថ្លៃ ១% ដល់ ១៩៩,៤ដុល្លារ/តោន រីឯកៅស៊ូនៅទីផ្សារអន្តរជាតិម៉ាឡេស៊ីឡើងថ្លៃ ៤% ដល់ ១.០១៩,៤ដុល្លារ/តោន។ ផ្ទុយទៅវិញ សណ្តែកសៀងនៅទីផ្សារ US ចុះថ្លៃ ៩,៥% ដល់ ២១៤,៥ដុល្លារ/តោននៅ ត្រីមាសទី៣ ២០០៣ គឺចុះពី ២៣៧,៦ដុល្លារ/តោនកាលពីត្រីមាសទី២ ។

*ដោយបណ្ឌិត កង ច័ន្ទតារារ័ត្ន និងលោក តុង គីមស៊ុន*

## តារាង១. កំនើន GDP ពិតនៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | | | | 2003 | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | - | - | - | - | - | - | - | 4.2 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 2.5 | 3.5 | 3.9 | 3.8 | 3.4 | 3.8 | 3.9 | 3.8 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 1.1 | 3.8 | 5.6 | 5.4 | 4.0 | 4.4 | 3.5 | 5.6 |
| សិង្ហបុរី | 9.5 | -2.3 | -1.7 | 3.9 | 3.7 | 3.0 | 1.6 | -4.2 | 1.7 | 2.6 |
| ថៃ | 4.4 | 1.9 | 3.9 | 5.1 | 5.8 | 5.6 | 6.7 | 5.8 | 6.5 | 6.1 |
| វៀតណាម | | 6.0 | - | - | - | - | - | 6.9 | - | 6.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 7.6 | 8.0 | 8.1 | 8.1 | 9.9 | 6.7 | 9.1 | 8.1 |
| ហុងកុង | 10.6 | 0.3 | -0.9 | 0.5 | 3.3 | 5.0 | 4.5 | -0.5 | 4.0 | 5.0 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 5.7 | 6.3 | 5.8 | 6.8 | 3.7 | 1.9 | 2.3 | 6.1 |
| តៃវ៉ាន់ | 6.0 | -2.1 | 0.9 | 3.0 | 4.8 | 4.2 | 3.2 | -0.4 | 4.2 | 4.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ | 3.5 | 1.4 | 0.1 | 0.7 | 0.8 | 1.3 | 0.8 | 0.2 | 0.3 | 0.7 |
| ជប៉ុន | 1.6 | -1.3 | -1.6 | -0.7 | 1.3 | 2.8 | 2.6 | 3.0 | 1.8 | 0.5 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 1.5 | 2.1 | 3.2 | 2.9 | 2.1 | 2.5 | 3.5 | 2.4 |

*ប្រភព: ទស្សនាវដ្តី The Economist និង ការិយាល័យស្ថិតិជាតិ និងធនាគារកណ្តាលនានា ។*

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | | | 2003 | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.3 | -0.4 | 3.4 | 3.3 | 3.5 | 3.0 | 1.8 | 1.6 | 0.2 | 3.3 |
| ឥណ្ឌូនេស៊ី | 3.7 | 11.3 | 14.5 | 12.6 | 10.2 | 10.3 | 7.7 | 6.5 | 5.6 | 11.9 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.5 | 1.9 | 2.1 | 1.9 | 1.3 | 0.9 | 1.0 | 1.9 |
| សិង្ហបុរី | 1.4 | 1.0 | -0.9 | -0.4 | -0.4 | 0.1 | 0.7 | 0.1 | 3.2 | -0.4 |
| ថៃ | 1.6 | 1.8 | 0.6 | 0.2 | 0.3 | 1.4 | 2.0 | 1.7 | 1.8 | 0.6 |
| វៀតណាម | -1.7 | 0.0 | 2.3 | 2.7 | 2.9 | 3.7 | 2.2 | 2.3 | 3.5 | 2.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 1.0 | -0.5 | -0.7 | -0.8 | -0.6 | 0.5 | 0.6 | | -0.7 |
| ហុងកុង | -3.7 | -1.5 | -2.7 | -3.1 | -3.5 | -2.9 | -2.0 | -.25 | -3.7 | -3.1 |
| កូរ៉េខាងត្បូង | 2.3 | 4.3 | 2.5 | 2.7 | 2.5 | 3.2 | 4.1 | 3.3 | 3.1 | 2.7 |
| តៃវ៉ាន់ | 1.4 | 0.5 | -0.1 | -0.1 | -0.3 | -0.5 | 0.3 | -0.1 | - | -0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ | 2.3 | 2.6 | 2.5 | 2.0 | 2.0 | 2.3 | 2.4 | 2.0 | 2.0 | 2.2 |
| ជប៉ុន | -0.6 | -0.5 | -1.4 | -0.9 | -0.8 | -0.5 | -0.3 | - 0.2 | -0.3 | -0.9 |
| សហរដ្ឋអាមេរិក | 3.4 | 2.9 | 1.2 | 1.3 | 1.6 | 2.2 | 2.9 | 2.1 | 2.2 | 1.6 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ និងទស្សនាវដ្តី The Economist ។*

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | | | 2003 | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,871 | 3,935 | 3,910 | 3,916 | 3,935 | 3,948 | 3,948 | 4,008 | 4,015 | 3,927 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8,421 | 10,236 | 10,078 | 9,077 | 8,940 | 9,027 | 8,884 | 8,428 | 8,482 | 9,280 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.8 | 3.8 | 3.8 | 3.8 | 3.8 | 3.80 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.83 | 1.81 | 1.76 | 1.77 | 1.74 | 1.75 | 1.75 | 1.79 |
| ថៃ (បាត) | 40.1 | 44.4 | 43.77 | 42.78 | 42.09 | 43.4 | 42.7 | 42.2 | 41.5 | 43.0 |
| វៀតណាម (ដុង) | 14,083 | 14,827 | 15,142 | 15,231 | 15,314 | 15,297 | 15,427 | 15,470 | 15,693 | 15,246 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.27 | 8.28 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.79 | 7.80 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,319 | 1,273 | 1,197 | 1,214 | 1,199 | 1,206 | 1,184 | 1,251 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.8 | 34.1 | 35.1 | 33.8 | 33.8 | 34.8 | 34.7 | 35.0 | 34.2 | 34.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ (អឺរ៉ូ) | 1.08 | 1.12 | 1.15 | 1.09 | 1.02 | 1.00 | 0.93 | 0.88 | 0.88 | 1.07 |
| ជប៉ុន (យ៉េន) | 108 | 122 | 133.3 | 127.6 | 119.6 | 123.0 | 118 | 119.1 | 117.7 | 126 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ និងទស្សនាវដ្តី The Economist និងធនាគារជាតិនៃកម្ពុជា ។*

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ ២០០០-២០០៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | | | 2003 | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 190.1 | 160.1 | 137.6 | 153.0 | 178.7 | 181.2 | 186.3 | 182.1 | 183.0 | 162.5 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 599.2 | 488.3 | 479.7 | 493.0 | 536 | 565.4 | 550.4 | 552.4 | 552.0 | 518.5 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 622.3 | 754.0 | 863 | 834.1 | 945.5 | 975.8 | 1017.4 | 768.4 |
| អង្ករ - បាងកក ($/តោន) | 203.7 | 172.6 | 193.7 | 196.6 | 192.6 | 189.6 | 198.3 | 197.5 | 199.6z | 193.1 |
| សណ្តែកសៀង - សហរដ្ឋអាមេរិក ($/តោន) | 211.3 | 195.6 | 179.9 | 189.8 | 219.3 | 239.0 | 243.3 | 245.7 | 244.3 | 202.3 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 19.9 | 24.3 | 25.4 | 26.2 | 29.3 | 24.5 | 26.5 | 24.0 |
| មាស - LONDON ($/fine ounces) | 279.0 | 279.0 | 281.0 | 280.9 | 313.7 | 317.8 | 352.1 | 346.7 | 363.3 | 298.3 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ និងទស្សនាវដ្តី The Economist ។*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ច

នៅត្រីមាសទី៣ ២០០៣ ជញ្ជីងពាណិជ្ជកម្មកម្ពុជា មានអតិរេក ៥៦លានដុល្លារ ដែលជាអតិរេកលើកទី១ ចាប់តាំងពីត្រីមាសទី១ ឆ្នាំ២០០០ មក ។ ការនាំចេញមានកំណើន ២០,៥% ធៀបនឹងត្រីមាសទី២ ២០០៣ ឬកំណើន ៨,៩% បើធៀបនឹងត្រីមាសទី៣ ២០០២ ដែលជំរុញឡើងជាសំខាន់ដោយសារកំនើនការនាំចេញសំលៀកបំពាក់ ។ ការនាំចេញសំលៀកបំពាក់ទៅ US កើនជាបង្គួរត្រឹម ២,៧% ឯការនាំចេញទៅប្រទេសផ្សេងៗទៀតស្ទុះឡើងយ៉ាង ខ្លាំងដល់ ២៦% ។

យោងតាមទិន្នាការតាមរដូវ ការនាំចេញសំលៀកបំពាក់កម្ពុជា រំពឹងថានឹងធ្លាក់ចុះនៅត្រីមាសទី៤ ២០០៣ ហើយដោយសារវាមានចំណែកធំបំផុតក្នុងការនាំចេញរបស់កម្ពុជា ដូច្នេះការនាំចេញសរុបក៏រំពឹងថាធ្លាក់ចុះដែរ ។

នៅត្រីមាសទី៣ ២០០៣ តំលៃសរុបនៃការនាំចូលចុះដល់ ៤៣៦,២លានដុល្លារ ឬធ្លាក់ចុះ ១០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ ។ តួលេខនេះឆ្លុះបញ្ចាំងពីការថយចុះទំនិញនាំចូលចំបងៗ ដូចជា ប្រេងម៉ាស៊ូត (ចុះពី ៣១,៣ លានដុល្លារ ដល់ ២៥,១លានដុល្លារ) និងសំភារៈសំណង់ (ពី ៣,៧លានដុល្លារ ដល់ ២,៤លានដុល្លារ) ។ ពីខែមករា-កញ្ញា ២០០៣ ការនាំចូលសរុបនូវប្រេងសាំងមាន ២៤លានដុល្លារ ប្រេងម៉ាស៊ូតមាន ៨៣,៥លានដុល្លារ និងសំភារៈសំនង់មាន ៨,៦លានដុល្លារ ។ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០០២ ការនាំចូលប្រេងសាំងថយ-ចុះ ៥,១% ម៉ាស៊ូត ថយចុះ ១៩,៨% និងសំភារៈសំណង់ថយចុះ ៣៥,១% ។

នៅត្រីមាសទី៣ ២០០៣ ទេសចរណ៏រើបរិញខ្លះៗ បន្ទាប់ពីការធ្លាក់ចុះនៅឆមាសទី១ ២០០៣ ។ ចំនួនភ្ញៀវអន្តរជាតិសរុបមកដល់តាមផ្លូវអាកាស ផ្លូវគោកនិងទឹក ដែលភាគច្រើនជាទេសចរ កើនពី១០៣.០០០នាក់នៅត្រីមាសទី២ ២០០៣ ដល់ ១៥៨.២០០នាក់នៅត្រីមាសទី៣ ក្នុងនេះអ្នកដំនើរតាមយន្តហោះកើនពី ៥៩.៦០០នាក់ ដល់ ៩៧.៦០០នាក់ ឯភ្ញៀវចូលតាមផ្លូវគោកនិងទឹក កើនពី ៤៣.៥០០នាក់ ដល់ ៦០.៦០០នាក់ ។ ទោះបីចំនួនអ្នកដំណើរសរុបបានរើបឡើងខ្លះក្នុងត្រីមាសទី៣ ២០០៣ ក្តី ក៏វាបានថយចុះ ៨,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ ។ ជាពិសេស អ្នកដំណើរតាមយន្តហោះបានថយចុះ ១៤,៧% ដល់ ៩៧.៦០០នាក់ ក្នុងនេះ អ្នកមាន "ទិដ្ឋាការរដ្ឋការ" ធ្លាក់ចុះយ៉ាងខ្លាំងពី ៥២.០០០នាក់ ដល់ត្រឹម ៥.១០០នាក់ ប៉ុន្តែអ្នកដំណើរជាទេសចរ និងអ្នកជំនួញ កើនពី ៤៦.០០នាក់ដល់ ៧៦.២០០ នាក់ និងពី ១៥.៦០០នាក់ដល់ ១៦.៣០០នាក់ រៀងៗគ្នា ។

វិស័យសាងសង់បន្តកើនឡើងនៅត្រីមាសទី៣ ២០០៣ ។ នៅភ្នំពេញ ១៩០គំរោងសាងសង់បានទទួលការអនុម័ត ក្នុងនេះ ២៥គំរោងជាសំនង់ភូមិគ្រឹះ, ១៤៨គំរោងជាផ្ទះល្វែង, និង ១៧គំរោងជាសំណង់ផ្សេងទៀត ។ តំលៃសរុបនៃគំរោងសាងសង់ឡើងដល់ ៦៨,២លានដុល្លារ ធៀបនឹង ៥៩,៦ លានដុលារនៅត្រីមាសទី២ ។ សំណង់ផ្ទះល្វែងកើនដល់ ៤៨,៨លានដុល្លារ ធៀបនឹង ៣៤,៣លានដុល្លារនៅត្រីមាសទី២ ២០០៣ ។ ប៉ុន្តែសំណង់ភូមិគ្រឹះ និងសំណង់ផ្សេងទៀត ធ្លាក់ចុះពី ៧,៩លានដុល្លារដល់ ៥លានដុល្លារ និងពី ១៧,៤លាន ដុល្លារ ដល់ ១២,៨៥លានដុល្លាររៀងៗគ្នា ។ ទោះបីមានការរើបឡើងវិញ ខ្លះក្តី ក៏ចំនួនគំរោងសាងសង់នៅភ្នំពេញនៅត្រីមាសទី៣ ២០០៣ មានកំរិត ១០,៤% ទាបជាងត្រីមាសទី៣ ឆ្នាំ២០០២ ។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី៣ ២០០៣ អតិផរណានៅភ្នំពេញចុះដល់ ០,៨% ដែលជាអត្រាទាបបំផុតក្នុងរយៈជាង១ឆ្នាំ ។ មូលហេតុចំបងនៃការថយចុះនេះ គឺថ្លៃម្ហូបអាហារដែលកើនយឺតជាងមុនតាមអត្រា ១,៥%នៅត្រីមាសទី៣ ២០០៣ ធៀបនឹង ២,៣%នៅត្រីមាសទី២ ។ ថ្លៃសាំងនៅភ្នំពេញថយចុះ ០,៧% ដល់ ២.៣៦៧រៀល/លីត្រ ឯថ្លៃម៉ាស៊ូតនៅនឹងដដែលត្រឹម ១.៦៨៣រៀល/លីត្រ ។ បើធៀបនឹងត្រីមាសទី៣ ២០០២ ម៉ាស៊ូត និងសាំង បានឡើងថ្លៃ ៨,៦% និង ៧,៦%រៀងៗគ្នា ។ ត្រីមាសទី៣ ២០០៣ មាសឡើងថ្លៃដល់ ៤១,៥ដុល្លារ/ជី ដែលជាកំរិតខ្ពស់បំផុតក្នុង ១៨ត្រីមាសកន្លងទៅ ។

តំលៃប្រាក់រៀលសឹងតែនៅនឹងដោយប្តូរបាន ៤.០១៥ រៀល/ដុល្លារ នៅត្រីមាសទី៣ ២០០៣ ធៀបនឹង ៤.០០៨រៀល/ដុល្លារនៅត្រីមាសទី២ ។ រឿងនេះប្រហែលជាប់ទាក់ទងនឹង នយោបាយរូបិយវត្ថុត្បិតត្បៀតរបស់ធនាគារជាតិនៃកម្ពុជា ។ សាច់ប្រាក់រៀលសរុប កើន ១,៧% ពីត្រីមាសទី២ ដល់ត្រីមាសទី៣ ២០០៣ និងកើន ៥% ពីត្រីមាសទី១ ដល់ត្រីមាសទី២ ២០០៣ ។ ប៉ុន្តែធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់រៀលបានចុះថ្លៃ ២% នៅត្រីមាសទី៣ ២០០៣ ។ ប្រាក់រៀលចុះខ្សោយប្រហែលទាក់ទងនឹងសភាពការណ៏នយោបាយដែលនៅបន្តមិនច្បាស់លាស់ដោយសារបរាជ័យក្នុងការបង្កើតរដ្ឋាភិបាលថ្មី ។នាត្រីមាសទី៣ ២០០៣ ប្រាក់រៀលប្តូរបាន ៩៦,៩រៀល/បាត ឬចុះថ្លៃ ២,១% ទល់នឹងប្រាក់បាត បើធៀបនឹងត្រីមាសទី២ ។

## ការវិវត្តន៍រូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) កើនដល់ ៣.០០៧ពាន់លានរៀលនៅត្រីមាសទី៣ ២០០៣ ឬកើន ៩,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ ។ ក្នុងចំនួននេះ ៨៨៦ពាន់លានរៀលជាប្រាក់រៀល និង ២.១២០ពាន់លានរៀលជាប្រាក់ដុល្លារ ។ ឥណទានផ្តល់ដោយធនាគារពាណិជ្ជ និងនៅមិនទាន់សងមកវិញឡើងដល់ ១.២៨៧ពាន់លានរៀលនៅចុង ត្រីមាសទី៣ ២០០៣ ។ ជាទូទៅធនាគារតែងរារែកក្នុងការផ្តល់កំចីរយៈពេលវែងឱ្យវិស័យឯកជន ។ តាមពតិមានពីកម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ៧០% នៃកំចីសំរាប់សហគ្រាសធុនតូច និងមធ្យម មានរយៈពេលតិចជាង១ឆ្នាំ និង ២៩%មានរយៈពេល ១-២ឆ្នាំ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ២០០៣ ប្រតិបត្តិការថវិកាជាតិកម្ពុជា មានឱនភាពតូចជាងមុន ត្រឹម ២៦៣ពាន់លានរៀល ធៀបនឹងឱនភាព ២៨១ពាន់លានរៀលនៅត្រីមាស ទី២ ។ ក្នុងនេះមូលហេតុចំបងគឺ កំណើនក្នុងចំណូលសរុប ៥,៧% ដែលភាគច្រើនជា កំណើនក្នុងចំណូលចរន្ត ។ ប៉ុន្តែធៀបនឹងកាលពីមួយឆ្នាំមុន ឱនភាពសរុបនៅត្រី មាសទី៣ ២០០៣ មានកំរិត ៦% ខ្ពស់ជាង ។ រឿងនេះឆ្លុះបញ្ចាំងពីការធ្លាក់ចុះ ចំណូលសរុប (១២,៤%) ដែលបណ្តាលពីការថយចុះយ៉ាងខ្លាំងក្នុងចំណូលចរន្ត (១២,៤%) ។ ចំណូលពន្ធដែលមានចំណែកធំបំផុតក្នុងចំណូលចរន្តធ្លាក់ចុះ ១៥,៤% ដល់ត្រឹម ២៧៣,១ពាន់លានរៀលនៅត្រីមាសទី៣ ២០០៣ ជាពិសេស "ពន្ធគយ" ដែល-ជាសមាសភាគចំបងមួយក្នុងចំណូលពន្ធ បានធ្លាក់ចុះ ២១% ដល់ ៩១,៦ពាន់លានរៀលនៅត្រីមាសទី៣ ២០០៣ ។

## វិនិយោគឯកជន និងការងារ

នៅត្រីមាសទី៣ ២០០៣ ទ្រព្យសកម្មជាប់លាប់ អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា (CDC) ឡើងដល់ ៩៥,១លានដុល្លារ ឬកើន ៩៧%

*តទៅទំព័រទី ១៩*

# តាមដានសេដ្ឋកិច្ច ~ អាំងឌីកាទ័រ

## តារាង១. គំរោងវិនិយោគដែលបានអនុម័ត ពីឆ្នាំ១៩៩៦-២០០៣ *

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | ចំនួនគំរោងវិនិយោគ | | | | | | |
| សរុប | 300 | 136 | 140 | 96 | 96 | 188 | 9 | 11 | 8 | 20 | 14 | 17 |
| កាត់ដេរ | 144 | 48 | 84 | 44 | 52 | 76 | 4 | 5 | 2 | 6 | 7 | 12 |
| | | | | | | មូលធនដែលបានចុះបញ្ជី (លានដុល្លារ) | | | | | | |
| សរុប | 391.2 | 278 | 416.4 | 246.8 | 102.4 | 129.2 | 4.5 | 12.1 | 20.3 | 41.6 | 10.4 | 4.0 |
| កាត់ដេរ | 156.8 | 34.4 | 91.6 | 55.6 | 25.6 | 60 | 1.0 | 5 | 1 | 5 | 4.1 | 1.0 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| សរុប | 746.8 | 761.6 | 849.2 | 474 | 266.4 | 217.2 | 23.3 | 127.6 | 60.9 | 108.5 | 48.3 | 95.1 |
| កាត់ដេរ | 158.4 | 38.8 | 120.8 | 79.6 | 76.8 | 100 | 2.4 | 5.5 | 1.7 | 6.5 | 10.5 | 43.3 |

*ប្រភព: ក្រុមប្រឹក្សាវិនិយោគកម្ពុជា (១៩៩៥-២០០៣) ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

## តារាង២. គំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត (១៩៩៦-២០០៣)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ភូមិគ្រឹះ | 205 | 179 | 143 | 136 | 111 | 108 | 38 | 36 | 40 | 29 | 39 | 25 |
| ផ្ទះល្វែង | 537 | 528 | 678 | 864 | 520 | 499 | 126 | 154 | 123 | 125 | 104 | 148 |
| ផ្សេងៗ | 116 | 117 | 132 | 74 | 64 | 57 | 20 | 22 | 14 | 21 | 23 | 17 |
| សរុប | 858 | 824 | 953 | 1074 | 695 | 664 | 184 | 212 | 177 | 175 | 166 | 190 |

*ប្រភព: នាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រុងភ្នំពេញ ។*

## តារាង៣. នាំចេញ និងនាំចូល (១៩៩៦-២០០៣)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | | លានដុល្លារ | | | | | |
| នាំចេញសរុប | 387.1 | 493.4 | 784.4 | 941.1 | 1055.5 | 1267.0 | 314.1 | 451.7 | 412.9 | 331.5 | 408.5 | 492.3 |
| រួមមាន: - សំលៀកបំពាក់ | 78.8 | 227.2 | 378 | 554 | 962.1 | 1201.0 | 289.5 | 431.7 | 385.4 | 314.7 | 389.9 | 475.2 |
| • ទៅសហរដ្ឋអាមេរិក | 0.4 | 107.2 | 74.1 | 486 | 714.1 | 840.9 | 203.5 | 295.2 | 269.2 | 230.6 | 267.8 | 303.2 |
| • ប្រទេសផ្សេងទៀត | 78.4 | 120 | 82 | 68 | 248.0 | 360.1 | 86.0 | 136.5 | 116.2 | 84.1 | 122.1 | 172.0 |
| - កសិកម្ម | - | - | - | - | 90.5 | 66.0 | 24.7 | 20.1 | 27.4 | 16.8 | 18.7 | 17.0 |
| • កៅស៊ូ | - | - | - | - | 29.6 | 25.9 | 5.5 | 9.2 | 9.1 | 6.3 | 6.7 | 10.0 |
| • ឈើ | - | - | - | - | 32.5 | 22.3 | 5.3 | 4.1 | 3.3 | 2.8 | 2.8 | 2.1 |
| • ជលផល | - | - | - | - | 5.4 | 6.0 | 1.6 | 1.0 | 0.5 | 0.8 | 0.7 | 0.6 |
| • ផ្សេងៗ | - | - | - | - | 26.0 | 11.8 | 12.3 | 5.8 | 14.5 | 6.9 | 8.5 | 4.3 |
| ការនាំចូលសរុប | 1114.4 | 1094.5 | 1112.2 | 1237.4 | 1417.7 | 1501.4 | 470.4 | 484.4 | 438.7 | 393.8 | 507.3 | 436.2 |
| រួមមាន: - សាំង | - | - | - | - | - | - | 7.5 | 5.9 | 7.6 | 10.4 | 8.0 | 5.6 |
| - ម៉ាស៊ូត | - | - | - | - | - | - | 28.3 | 31.3 | 23.3 | 25.0 | 33.4 | 25.1 |
| - សំភារៈសំណង់ | - | - | - | - | - | - | 3.2 | 3.7 | 2.9 | 2.8 | 3.4 | 2.4 |
| - ផ្សេងៗ | - | - | - | - | - | - | 431.4 | 443.5 | 404.9 | 355.6 | 462.5 | 403.1 |
| ជញ្ជីងពាណិជ្ជកម្ម | -727.3 | -601.2 | -327.8 | -296.3 | -362.2 | -234.0 | -156.3 | -32.7 | -25.8 | -62.3 | -98.8 | 56.1 |
| | | | | | | ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 198 | 188 | 66 | 47 | 74 | 24.8 | 2.8 | 27.5 | 33.2 | 26.3 | 34.7 | 10.1 |
| ការនាំចេញសរុប | 2.1 | 27.5 | 58.9 | 12.4 | 19.7 | 20 | 5.5 | 28.0 | 35.3 | 20.7 | 30.0 | 9.0 |
| ការនាំចូលសរុប | 1.2 | -1.8 | 1.6 | 11.3 | 14.5 | 5.9 | 29 | 59 | 27 | 22 | 7.8 | -10.0 |

*ប្រភព: ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ទីចាត់ការគយ និងរដ្ឋាករ រួមទាំង ការលើកលែងពន្ធ ។*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ១៩៩៦-២០០៣

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | អ្នកដំណើរពាន់នាក់ | | | | | | |
| ទិដ្ឋាការទេសចរ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 24.9 | 46.9 | 58.7 | 183.7 | 83.8 | 132.0 |
| តាមយន្តហោះ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 24.9 | 46.9 | 58.7 | 124.6 | 44.4 | 76.2 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | - | - | 59.1 | 39.4 | 55.8 |
| ទិដ្ឋាការជំនួញ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 19.5 | 15.6 | 16.1 | 20.4 | 14.7 | 20.3 |
| តាមយន្តហោះ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 19.5 | 15.6 | 16.1 | 17.2 | 11.2 | 16.3 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | - | - | 3.2 | 3.5 | 4.0 |
| ទិដ្ឋាការរដ្ឋការ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 57.4 | 52.0 | 92.9 | 4.7 | 4.6 | 5.9 |
| តាមយន្តហោះ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 57.4 | 52.0 | 92.9 | 4.0 | 4.0 | 5.1 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | - | - | 0.7 | 0.6 | 0.8 |
| សរុបតាមអាកាស | | | 186.3 | 262.9 | 351.7 | 408.4 | 101.8 | 114.5 | 167.7 | 145.8 | 59.6 | 97.6 |
| សរុបតាមផ្លូវគោក និងទឹក | - | - | 100..2 | 104.8 | 114.7 | 196.5 | 62.8 | 59.3 | 69.6 | 63 | 43.5 | 60.6 |
| សរុបអ្នកដំណើរ | 260.4 | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 164.6 | 173.8 | 237.3 | 208.8 | 103.1 | 158.2 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុបអ្នកដំណើរ | 18.5 | -15.9 | 30.9 | 28.3 | 26.8 | 29.7 | 26.9 | 24.7 | 41.3 | -0.9 | -37.4 | -8.9 |

*ប្រភព: ក្រសួងទេសចរណ៍ ។*

# តាមដានសេដ្ឋកិច្ច ~ អាំងឌីកាទ័រ

## តារាង៥. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស ពីឆ្នាំ១៩៩៦-២០០៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ខេត្ត | - | 6.1 | 16.3 | 6.2 | 5.4 | 0.9 | 0.0 | 2.0 | -0.3 | 7.4 | 5.9 | -1.9 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 7.1 | 8.0 | 14.8 | 4.0 | -0.8 | -0.6 | 3.3 | 3.5 | 3.04 | 1.8 | 1.6 | 0.8 |
| - ម្ហូបអាហារ | 7.6 | 6.7 | 14.1 | 7.6 | -3.3 | -2.8 | 1.02 | 2.0 | 2.00 | 3.20 | 2.3 | 1.5 |
| - ថាមពល | 20.7 | 20.0 | 15.1 | 3.5 | 6.6 | -1.1 | -0.02 | 0.9 | 2.25 | 4.75 | 5.2 | 5.1 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 2,666 | 3,029 | 3824 | 3832 | 3,879 | 3,935 | 3,913 | 3,935 | 3,948 | 3948 | 4008 | 4015 |
| រៀលក្នុង ១ បាតថៃ | 105 | 98 | 88 | 101 | 96.3 | 88 | 91.4 | 93.5 | 90.9 | 92.4 | 94.9 | 96.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.0 | 25.6 | 28.6 | 27.8 | 27.4 | 26.6 | 25.7 | 25.7 | 25.8 | 25.6 | 25.9 | 24.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 34.0 | 33.3 | 32.7 | 36.2 | 38.0 | 38.5 | 39.8 | 40.0 | 41.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,450 | 1,550 | 1550 | 1697 | 1683 | 1683 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,167 | 2,200 | 2200 | 2433 | 2383 | 2367 |

*ប្រភព: វបសអ, IMF, NIS ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

## តារាង៦. ស្ថានភាពរូបិយវត្ថុ ពីឆ្នាំ១៩៩៦-២០០៣ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 881 | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,614 | 3,693 | 3,737 | 3,741 | 3,594 | 3627 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 31 | -114 | -496 | -576 | -759 | -876 | -965 | -943 | -849 | -737 | -641 | -621 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 128 | 54 | 178 | 103 | 3 | -75 | -165 | -106 | -119 | -72 | -19 | 18 |
| ឥណទានចំពោះផ្នែកឯកជន | 435 | 637 | 655 | 763 | 898 | 936 | 928 | 971 | 1,059 | 1,125 | 1,224 | 1287 |
| រូបិយវត្ថុទូទៅ M2 | 912 | 1,063 | 1,230 | 1,443 | 1,831 | 2204 | 2,648 | 2,751 | 2,888 | 3,004 | 2,953 | 3007 |
| រូបិយវត្ថុ M1 | 329 | 385 | 543 | 531 | 540 | 609 | 748 | 771 | 813 | 829 | 871 | 886 |
| រូបិយវត្ថុផ្សេងៗ | 583 | 678 | 687 | 911 | 1,291 | 1,594 | 1,901 | 1,979 | 2,075 | 2,175 | 2,082 | 2120 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 40.3 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 33.4 | 29.5 | 24.1 | 24.6 | 11.5 | 9.3 |
| រូបិយវត្ថុ M1 | 18.3 | 17 | 41 | -2.2 | 1.7 | 12.8 | 37.5 | 35.5 | 33.4 | 22.6 | 16.4 | 14.9 |
| រូបិយវត្ថុផ្សេងៗ | 57.1 | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 32.0 | 27.3 | 30.2 | 25.7 | 9.5 | 7.1 |

*ប្រភព: ធនាគារជាតិនៃកម្ពុជា ។*

## តារាង៧. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ពីឆ្នាំ១៩៩៦-២០០៣ (ពាន់លានរៀល)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | | 2003 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 748 | 880 | 920 | 1326 | 1528 | 1529 | 369 | 457 | 481 | 400 | 379 | 400.5 |
| ចំណូលចរន្ត | - | - | - | - | - | 1521 | 369 | 456 | 481 | 400 | 377 | 399.2 |
| ចំណូលពន្ធ | 536 | 596 | 676 | 956 | 1096 | 1096 | 302 | 323 | 339 | 273 | 287 | 273.1 |
| ពន្ធគយ | 344 | 348 | 376 | 432 | 376 | 376 | 104 | 116 | 122 | 92 | 94 | 91.6 |
| ចំណូលមិនមែនពន្ធ | 176 | 272 | 204 | 348 | 424 | 424 | 66 | 133 | 142 | 127 | 90 | 126.2 |
| អាជីវកម្មព្រៃឈើ | 28 | 36 | 20 | 36 | 28 | 29 | 1 | 9 | 5 | 1 | 1 | 4.5 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 64 | 84 | 88 | 108 | 124 | 122 | 13 | 30.7 | 44 | 19 | 18 | 33.5 |
| ចំណូលជាមូលធន | 40 | 12 | 36 | 12 | 8 | 9 | 0 | 1 | 0 | 0 | 2 | 1.3 |
| ចំណាយសរុប | 1440 | 1260 | 1296 | 1792 | 2332 | 2332 | 714 | 704 | 668 | 660 | 660 | 663.5 |
| ចំណាយជាមូលធន | 628 | 452 | 368 | 624 | 976 | 977 | 272 | 303 | 343 | 276 | 271 | 251.8 |
| ចំណាយចរន្ត | 812 | 808 | 980 | 1164 | 1356 | 1355 | 442 | 401 | 325 | 384 | 388 | 411.8 |
| អប់រំ និងសុខាភិបាល | 124 | 128 | 132 | 280 | 344 | 343 | 108 | 85 | 96 | 36 | 88 | 122.4 |
| ការពារជាតិ និងសន្តិសុខ | 408 | 420 | 448 | 464 | 404 | 405 | 117 | 105 | 110 | 70 | 119 | 75.4 |
| ក្រសួងផ្សេងៗ | 284 | 260 | 332 | 412 | 636 | 637 | 217 | 212 | 120 | 279 | 182 | 213.9 |
| ឱនភាពជាទូទៅ | -692 | -380 | -380 | -476 | -804 | -803 | -346 | -248 | -187 | -260 | -281 | -263 |
| ហិរញ្ញប្បទានក្រៅប្រទេស | 680 | 444 | 268 | 416 | 768 | 766 | 237 | 273 | 287 | 176 | 201 | 201 |
| ហិរញ្ញប្បទានក្នុងស្រុក | 12 | -64 | 112 | 60 | 36 | 37 | 110 | -25 | -100 | 84 | 80 | 62 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះ ពីឆ្នាំ១៩៩៧-២០០៣

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1997 | 2001 | 2002 | | | | 2003 | | | 2003 | | |
| | មុនកក្កដា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 12,250 | 6,262 | 9,375 | 8,900 | 8,878 | 9,200 | 9,572 | 9,380 | 9,817 | 2.10 | 5.4 | 10.58 |
| អ្នកលីសែង | 9,675 | 5,000 | 6,675 | 7,600 | 6,312 | 7,600 | 7,955 | 7,240 | 6,500 | 19.18 | -4.7 | 2.98 |
| អ្នកលក់បន្លែតូចតាច | 7,050 | 5,096 | 6,712 | 6,862 | 7,158 | 7,250 | 6,674 | 6,860 | 6,700 | -0.57 | -0.3 | -6.40 |
| អ្នករើសអេតចាយ | 4,155 | 3,393 | 4,231 | 3,440 | 4,012 | 3,875 | 3,605 | 4,900 | 3,900 | -14.80 | 42.7 | -2.79 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | – | 2,358 | 3,652 | 4,225 | 4,000 | 4,600 | 4,341 | 4,520 | 4,435 | 18.87 | 7.0 | 10.88 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | 3,618 | 5,167 | 3,833 | 4,219 | 4,180 | 3,712 | 4,600 | 4,450 | -28.15 | 20.0 | 5.48 |
| កម្មកររោងចក្រកាត់ដេរ | – | 8,968 | 8,775 | 9,800 | 10000 | 10,127 | 9,123 | 10,300 | 10000 | 3.97 | 5.1 | 0.0 |
| អ្នករត់ម៉ូតូឌុប | – | 9,791 | 11,978 | 11,300 | 12,075 | 11,400 | 9372 | 10900 | 10000 | 3.26 | 16.7 | -17.18 |
| កម្មករសំណង់គ្មានជំនាញ | – | 4,841 | 6,912 | 6,525 | 5,850 | 6,162 | 7100 | 7600 | 6200 | -17.49 | -3.5 | 5.98 |
| កម្មករសំណង់មានជំនាញ | – | 9,866 | 13,850 | 12,695 | 13,350 | 12,500 | 12,050 | 12,700 | 16,900 | -3.72 | 0.0 | 26.59 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នកម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ *ចំនួនអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់*

# សទ្ទានុក្រម ~ ពាក្យប្រើក្នុងអត្ថបទនេះ

**ការរីករាលដាលទំនាស់** (Conflict Escalation)

ពាក្យនេះពិពណ៌នាពីសភាពការណ៍នៃទំនាស់មានស្រាប់មួយ ដែលបានក្លាយជាធ្ងន់ធ្ងរឬតឹងតែងខ្លាំងជាងមុន ដោយសារបរាជ័យក្នុងការអនុវត្តន៍បច្ចេកទេសគ្រប់គ្រងទំនាស់ ឬការមិនទុកចិត្តគ្នាក្នុងចំណោមគូភាគីនៃទំនាស់ និងដែលបានរារាំងដល់ការប្រស្រ័យទាក់ទងគ្នាក្នុងជំហរកសាង ។

**ការគ្រប់គ្រងទំនាស់** (Conflict Management)

នេះជាដំណើរការចរចា និងដោះស្រាយបញ្ហា សំដៅទប់ស្កាត់ការប្រែប្រួលធ្ងន់ធ្ងរឡើងនៃទំនាស់ និងរកបានដំណោះស្រាយដោយសន្តិភាពមួយដែលគូភាគីនានានៃទំនាស់អាចទទួលយកបាន ។

**ភាពពេញលក្ខណៈច្បាប់ខាងស្ថាប័ន** (Institutional Legitimacy)

ពាក្យនេះ សំដៅដល់ភាពអាចទទួលយកបាននៃសិទ្ធិអំណាចរបស់ស្ថាប័នណាមួយ ។ ចំណាប់អារម្មណ៍ថា ការដឹកនាំមានលក្ខណៈលំអៀង ពុករលួយ ឬទន់ខ្សោយ បានធ្វើឱ្យរិចរិលដល់សិទ្ធិអំណាចរបស់ស្ថាប័នជាច្រើននៅកម្ពុជា និងធ្វើឱ្យស្ថាប័នទាំងនេះគ្មានភាពពេញលក្ខណៈច្បាប់ ។

**ការឆក់យកត្រី** (Electrofishing)

វិធីនេសាទតាមរយៈការបញ្ជូនចរន្តអគ្គិសនីឆ្លងកាត់ទឹក ដើម្បីធ្វើឱ្យសាច់ដុំសត្វត្រីមានប្រតិកម្ម និងបង្ខំឱ្យវាហែលមករកអ្នកដែលចាំដួសយកវា ។

---

*តពីទំព័រទី ១៦*

## តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុង ...

ធៀបនឹងត្រីមាសទី២ ។ ក្នុងនេះវិស័យកសិកម្មមាន ១,២លានដុល្លារ (១គំរោង) វិស័យឧស្សាហកម្មមាន ៨៩លានដុល្លារ (១៥គំរោង) និងវិស័យទេសចរណ៍ ៤,៨លានដុល្លារ (១គំរោង) ។ ប៉ុន្តែតំលៃនៃវិនិយោគឯកជននៅត្រីមាសទី៣ ២០០៣ បានធ្លាក់ចុះយ៉ាងខ្លាំងអស់ ២៥,៥% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០០២ ទោះបីមានបន្ថែម ៦គំរោងទៀតក្តី ។ តាមពតិមានពី CDC ក្នុងរយៈពេលពីខែកក្កដា-កញ្ញា ២០០៣ អ្នកបានការងារធ្វើមាន ១៣.៤៥៩នាក់ ។

### ស្ថានភាពក្រីក្រ និងប្រាក់ចំណូលរបស់ពលករងាយរងគ្រោះ

អង្កេតរបស់ វបសអ លើពលករងាយរងគ្រោះ កាលពីថ្ងៃទី ៣-២១ វិច្ឆិកា ២០០៣ បង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យម សំរាប់ ៦ក្រុម (អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករសំណង់គ្មានជំនាញ និងកម្មករសំណង់មានជំនាញ) បានកើនឡើង រីឯសំរាប់ ៣ក្រុមទៀត (អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ និងអ្នករត់ម៉ូតូឌុប) បានថយចុះ បើធៀបនឹងខែវិច្ឆិកាឆ្នាំមុន ហើយសំរាប់កម្មកររោងចក្រកាត់ដេរ គឺគ្មានការប្រែប្រួលទេ។ ជាទូទៅប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមសំរាប់គ្រប់ក្រុម មានប្រហែល ៧.៨៩០រៀល ។

ទោះបីប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ បានកើន ១០,៦%ធៀបនឹងកាលពីមួយឆ្នាំមុន ដោយឡើងដល់ ៩.៨១៧រៀលនៅខែវិច្ឆិកា ២០០៣ក្តី ក៏អ្នកធាក់ស៊ីក្លូ ៨៧% ក្នុងគំរូតាងមានអារម្មណ៍ថា ប្រាក់ចំណូលចារិករបស់ខ្លួនបានថយចុះ ។ អង្កេតបង្ហាញទៀតថា អ្នកធាក់ស៊ីក្លូ ៦៣% បានរៀនចប់បឋមសិក្សា និង ៥% រៀនចប់មធ្យមសិក្សា ។ ម្យ៉ាងទៀត ៥៨% រាយការណ៍ថា មានដីតិចជាង ១ហិកតា ។ អ្នកធាក់ស៊ីក្លូ ២២% និង ២៤% មានទីលំនៅជាប់លាប់នៅខេត្តព្រៃវែង និងតាកែវរៀងៗគ្នា ។ ពួកគេរាយការណ៍ថា ពួកគេមករកស៊ីធាក់ស៊ីក្លូប្រហែល ៦ខែ/ឆ្នាំ ជាមធ្យម។

ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់អ្នកលីសែងកើន ៣% ដល់ ៦.៥០០រៀលនៅខែវិច្ឆិកា ២០០៣ ធៀបនឹង ៦.៣១២រៀលនៅខែវិច្ឆិកាឆ្នាំមុន ទោះបីមានអ្នកលីសែង ៨៣% រាយការណ៍ថា ប្រាក់ចំណូលចារិកប្រចាំថ្ងៃរបស់ខ្លួនបានថយចុះក្តី ។ ប្រាក់ចំណូលរបស់ពួកគេក្នុងឆ្នាំ២០០៣ មានកំរិត ២% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ។

ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់ អ្នកបំរើតាមភោជនីយដ្ឋាន និងអ្នកស៊ីឈ្នួលធ្វើស្រែ កើន ១០,៨% និង ៥,៥% រៀងៗគ្នានៅខែវិច្ឆិកា ២០០៣ ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ប៉ុន្តែអ្នកបំរើតាមភោជនីយដ្ឋាន ៨០% មានអារម្មណ៍ថា ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់ខ្លួនគ្មានការប្រែប្រួលទេ ។ គួរកត់សំគាល់ថា អ្នកបំរើតាមភោជនីយដ្ឋានចំណាយតិចជាងគេ (៩២៨រៀល/ថ្ងៃ) ក្នុងចំណោមពលករងាយរងគ្រោះទាំង ១០ក្រុម ដោយសារម្ចាស់ហាងផ្តល់អាហារ និងកន្លែងស្នាក់នៅឱ្យ ។

ប្រាក់ចំនូលប្រចាំថ្ងៃចារិកជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរនៅនឹងត្រឹម ១០.០០០រៀល នៅខែវិច្ឆិកា ២០០៣ គឺដូចគ្នានឹងខែវិច្ឆិកាឆ្នាំមុន ។ ប៉ុន្តែប្រាក់ចំណូលចារិករបស់ពួកគេ បានធ្លាក់ចុះ ៣% បើធៀបនឹងអង្កេតលើកមុន (សីហា ២០០៣) ។ ចំនួនម៉ោងធ្វើការជាមធ្យមគឺ ៦២ម៉ោង/ សប្តាហ៍ ។ អង្កេតបង្ហាញដែរថា កម្មកររោងចក្រកាត់ដេរអាចសន្សំបានប្រ ហែល ១១៤.៥៣១រៀល (២៨,៦ដុល្លារ) ក្នុងមួយខែ ហើយកម្មករ ៨១% ផ្ញើប្រាក់សន្សំទៅផ្ទះដើម្បីជួយទ្រទ្រង់គ្រួសារ ។

ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់អ្នកលក់បន្លែតូចតាច និងអ្នករើសអេតចាយ ធ្លាក់ចុះ ៦,៤ និង ២,៨% រៀងៗគ្នា នៅខែវិច្ឆិកា ២០០៣ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ការធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃចារិករបស់អ្នកលក់បន្លែតូចតាច ឆ្លុះបញ្ចាំងពីការថយចុះការដាំដុះបន្លែដោយសារធាតុអាកាសមិនល្អ និងកំណើនចំនួនអ្នកលក់ ។ អង្កេតបង្ហាញដែរថា គ្រឿងអេតចាយលក់បានថោកជាងកាលពី ៣ខែមុន ដែលធ្វើឱ្យថយចុះចំណូលប្រចាំថ្ងៃចារិករបស់អ្នករើសអេតចាយ ។ ម្យ៉ាងទៀត អ្នករើសអេតចាយ ៩៥%អះអាងថា ចំនួនពួកគេបានកើនឡើង ។ ពួកគេភាគច្រើនមកពីខេត្តព្រៃវែង (៣៤%) និងស្វាយរៀង (២០%)។ ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់អ្នករត់ម៉ូតូឌុបថយចុះ ១៧% ធៀបនឹងខែវិច្ឆិកា ២០០២ ឬថយចុះ ៨% ធៀបនឹងខែសីហា ២០០៣។ គ្មានអ្នករត់ម៉ូតូឌុបណាម្នាក់គិតថា ប្រាក់ចំណូលរបស់ខ្លួនមានចំនួនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពគ្រួសារនោះទេ ។

ប្រាក់ចំណូលប្រចាំថ្ងៃចារិករបស់កម្មករសំណង់មានជំនាញកើន ២៦,៦%នៅខែវិច្ឆិកា ២០០៣ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ដោយសារកំណើនសកម្មភាពសាងសង់ជាសំខាន់ ។ ប៉ុន្តែមានកម្មករសំណង់មានជំនាញ ២២% ប៉ុណ្ណោះដែលអះអាងថា ចំណូលប្រចាំថ្ងៃរបស់ខ្លួនគ្រប់គ្រាន់សំរាប់ទ្រទ្រង់គ្រួសារ ។ តាមធម្មតា កម្មករសំណង់មានជំនាញធ្វើការ ៨ខែ/ឆ្នាំ ។ ប្រាក់ចំណូលប្រចាំថ្ងៃចារិកជាមធ្យមរបស់កម្មករសំណង់គ្មានជំនាញកើន ៦% ដល់ ៦.២០០រៀលនៅខែវិច្ឆិកា ២០០៣ គឺកើនពី ៥.៨៥០រៀលក្នុងខែដូចគ្នាឆ្នាំមុន ។ ប៉ុន្តែចំណូលនេះបានធ្លាក់ចុះ ១៨% បើធៀបនឹងខែសីហា ២០០៣ ដោយសារមានការប្រកួតប្រជែងកាន់តែច្រើន បើ-តាម ពតិមានទទួលបានពីអ្នកឆ្លើយសំភាសន៍ ។

# ព័ត៌មានថ្មីៗ ពី វបសអ

## ផ្នែកគ្រប់គ្រង

នៅខែធ្នូ ២០០៣ វបសអ បានជំរាបលាដល់លោកស្រី Eva Mysliwiec ជានាយិកាប្រតិបត្តិស្ថាបនិកពីមុនរបស់ខ្លួន និងទទួលស្វាគមន៍លោក Larry Strange ជានាយកប្រតិបត្តិថ្មី, ដែលក្នុងរយៈ ១០ឆ្នាំកន្លងមកនេះ បានបំរើការជានាយកនៅវិទ្យាស្ថានអាស៊ី-អូស្ត្រាលីនៅឯទីក្រុង Sydney ។ នៅថ្ងៃទី ១៦ ធ្នូ លោកស្រី Eva Mysliwiec បានទទួលគ្រឿងឥស្សរិយយសសហមេត្រីចំពោះការងារជួយដល់ប្រទេសកម្ពុជា ។

ការប្រជុំប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាល វបសអ នៅថ្ងៃទី៥-៦ ធ្នូ បានស្វាគមន៍សមាជិកក្រុមប្រឹក្សាភិបាលថ្មីម្នាក់គឺ ឯ.ឧ.បណ្ឌិត ហង់ ជួន ណារ៉ុន អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។ ក្រុមប្រឹក្សាភិបាលបានអនុមតិនូវក្របខ័ណ្ឌស្រាវជ្រាវថ្មីរបស់ វបសអ សំរាប់ឆ្នាំ២០០៤-០៦ "សំរេចឱ្យបាននូវសន្តិសុខសំរាប់មនុស្ស និងការកាត់បន្ថយភាពក្រីក្រ" ព្រមទាំងគោលដៅជាយុទ្ធសាស្ត្រថ្មីរបស់មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ។

នៅពាក់កណ្តាលខែធ្នូ វបសអ បានធ្វើការប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយដៃគូនានាដែលខ្លួនធ្វើការងារជាមួយយ៉ាងជិតស្និទ្ធ ព្រមទាំងអ្នកតំណាងនៃសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ ដែលផ្តល់ធនធានដល់កម្មវិធីនានារបស់ វបសអ ។ ការពិគ្រោះយោបល់បានផ្តល់ឱកាសសំរាប់រាយការណ៍ពីលទ្ធផលចំបងៗក្នុងឆ្នាំ២០០៣ និងផែនការសំរាប់ឆ្នាំ២០០៤ និងពិភាក្សាពីវិធីដែល វបសអ អាចធ្វើការបានកាន់តែសក្តិសិទ្ធិជាមួយដៃគូនានា ដើម្បីឱ្យការអភិវឌ្ឍន៍ប្រទេសកម្ពុជាបានទទួលលទ្ធផលកាន់តែប្រសើរ ។

## ផ្នែកស្រាវជ្រាវ

ក្រៅពីការងារបោះពុម្ពផ្សាយជាប្រចាំ (របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា, របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា, ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា) ការសិក្សាជាច្រើនបានធ្វើឡើងហើយ ឬកំពុងស្ថិតក្នុងដំណាក់កាលផ្សេងៗនៃការអនុវត្តន៍ ដូចជា ការសិក្សាក្នុងតំបន់ពីរដែលមានការចូលរួមពីវិទ្យាស្ថានជាដៃគូនៅថៃ វៀតណាម និងឡាវ ។ លើសពីនេះ អ្នកស្រាវជ្រាវរបស់ វបសអ បានចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលា និងសន្និសីទជាច្រើន មានទាំងសិក្ខាសាលា និងសន្និសិទថ្នាក់តំបន់ និងអន្តរជាតិផង (ឧ. នៅហាណូយ បាងកក និងអង់ការ៉ា) ។

វបសអ បានរៀបចំសិក្ខាសាលថ្នាក់តំបន់ពីរ (ក្រោម DAN 4, និងការសិក្សាពីភាពប្រកួតប្រជែងខាងកសិកម្ម) ព្រមទាំងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជានៅខែមិថុនា ។ កម្មវិធីស្រាវជ្រាវក៏បានផ្តល់ពតិមានយ៉ាងច្រើនដល់សិក្ខាសាលា សំរាប់ថ្នាក់ដឹកនាំខេត្ត-ក្រុងនៅខែឧសភា ។ ការបោះពុម្ពផ្សាយក្នុងរយៈពេលនេះ រួមមាន របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០៣, ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (ប្រចាំត្រីមាស), និងរបាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា (ប្រចាំខែ), របាយការណ៍ស្រាវជ្រាវ អំពីភាពប្រកួតប្រជែងរបស់កម្ពុជាខាងកាត់ដេរសំលៀកបំពាក់ ដែលបានធ្វើការបោះពុម្ពផ្សាយរួមគ្នាជាមួយ IDE និងជប៉ុននៅខែមិនា ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍

នៅខែធ្នូ វបសអ បានជំរាបលាដល់លោក ឱក សេរីសោភក្តិ៍ ដែលបានផ្តល់វិភាគទានដ៏វិសេសវិសាលមួយដល់ វបសអ ក្នុងឋានៈជាអ្នកសំរបសំរួលនៃមជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងក្នុងតួនាទីជាគន្លឹះក្នុងកម្មវិធីបណ្តុះបណ្តាលខាងកសាងសន្តិភាពក្នុងដំណើរការ COPCEL (ការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា) និងក្នុងសិក្ខាសាលាសំរាប់ថ្នាក់ដឹកនាំខេត្ត-ក្រុង ។

ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ។

***Cambodia Development Review*** **is also available in English.**


# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៨ លេខ១ ខែមករា-មីនា ឆ្នាំ២០០៤



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh


***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា***
បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។ ***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។ ***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សរភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។


គ្រឹះស្ថានផ្សាយ: វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
គ្រប់គ្រងកែសំរួលស្តីទី: អែម សូភ៉ា / អ្នកកែសំរួល: Andrea Struik
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា / អ្នកបកប្រែ: យូ សិទ្ធិរិទ្ធ
រោងពុម្ព: រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: Andreak Struik



**រក្សាសិទ្ធិ ២០០៤** វិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។



**ISSN 1560-7615**



ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។